**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ចាន់ គីលៀង**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ចាន់ គីលៀង**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ចាន់ គីលៀង** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១២ ក្រុមP4A2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំអោនកាយគោរពដឹងគុណយ៉ាងខ្ពង់ខ្ពស់ និង**

**ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ**

- លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់នូវភាពកក់ក្ដៅ សេចក្ដីស្រលាញ់ អនុគ្រោះ និងអប់រំទូន្មានប្រៀនប្រដៅដល់កូន ដើម្បីប្រតិបត្តិខ្លួនតាមគន្លងព្រហ្មវិហារធម៌ និងដើម្បីរស់នៅក្នុងសង្គមជាតិប្រកបដោយសេចក្ដីថ្លៃថ្នូរ។ កូនសូមលើកម្រាមដៃដប់ក្រាបប្រតិបត្តិ និងសម្ដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅបំផុតចំពោះឧបករៈគុណរបស់លោកទាំងទ្វេ ដែលមានមកលើកូន។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ថា** សាកលវិទ្យាធិការ និងគណៈគ្រប់គ្រង នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានជួយជ្រោមជ្រែងតាមរយៈការសម្របសម្រួលបើកផ្លូវ ដល់ខ្ញុំបាទបានចុះទៅធ្វើការសិក្សាស្រាវជ្រាវ ស្វែងរកឯកសារ នៅតាមបណ្ដាក្រសួង-ស្ថាប័នរដ្ឋ និងសមាគមមួយចំនួន ដើម្បីធ្វើយ៉ាងណាឲ្យសារណាបញ្ចប់ការសិក្សាមួយនេះកាន់តែមានអត្ថន័យទូលំទូលាយ។
- លោកសាស្ត្រាចារ្យ **យូ តូនី** អនុប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយលោកក៏ជាសាស្ត្រាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សាមួយនេះផងដែរ ដែលលោកសាស្ត្រាចារ្យបានចំណាយទាំងពេលវេលា ទាំងកម្លាំងកាយ និងកម្លាំងចិត្តដ៏មានតម្លៃ ក្នុងការជួយណែនាំផ្ដល់ជាគន្លឹះក្នុងការស្រាវជ្រាវ បទពិសោធន៍ល្អៗ និងចំណុចស្នូលសំខាន់ៗសម្រាប់កិច្ចការស្រាវជ្រាវមួយនេះ រហូតអាចសម្រេចបាននូវសមិទ្ធផលដ៏គ្រចះគ្រចង់ ដែលមិនអាចកាត់ថ្លៃបាន។
- សូមអរគុណដល់បណ្ដានិស្សិត និងមហាជនទូទៅ ដែលបានយកចិត្តទុកដាក់ ក្នុងការអាន វិភាគ និងការទាញយកនូវពុទ្ធិគំនិតល្អៗ ចេញពីសារណាបញ្ចប់ការសិក្សាមួយនេះ និងក៏បានជួយខិតខំថែរក្សាឲ្យឯកសារមួយនេះ ស្ថិតស្ថេរបានគង់វង្សយូរអង្វែង សម្រាប់អោយយុវជនជំនាន់ក្រោយបានយល់ដឹង និងអានបន្ត។
- ជាចុងក្រោយ ខ្ញុំបាទ សូមលំអោនកាយគោរពដឹងគុណដល់អ្នកមានគុណទាំងអស់ដែលខ្ញុំបាទបានរៀបរាប់ពីខាងលើ និស្សិតបញ្ញាវន្តជំនាន់ថ្មីរបស់កម្ពុជា និងមហាជនទូទៅ ឲ្យជួបតែសេចក្ដីសុខ និងសេចក្ដីចម្រើនដើម្បីបន្តក្នុងការជួយចូលរួមចំណែកអភិវឌ្ឍសង្គមជាតិរបស់យើងតទៅមុខទៀត និងសូមប្រសិទ្ធពរជ័យសិរីមង្គល វិបុលសុខ ឲ្យជួបតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវនេះពិតជាមានឧត្តមប្រយោជន៍ និងសារៈសំខាន់ណាស់ក្នុងវិស័យអប់រំ ដោយហេតុថា ស្នាដៃនៃសារណាបញ្ចប់ការសិក្សា បានផុសចេញពីគំនិត បញ្ញាស្មារតី តាមរយៈការវិភាគ ការស្រាវជ្រាវ ការត្រិះរិះពិចារណា ការវិនិច្ឆ័យ ការស្វែងយល់ ពិតជាផ្តល់នូវពុទ្ធិវិភាគទានដែលមានតម្លៃក្នុងការស្ថាបនាមូលដ្ឋានគ្រឹះនៃការសិក្សា។ ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវក៏អាចចាត់ទុកបានថាជាលក្ខខណ្ឌមួយទៀត ដែលប្រៀបបានដូចជាម៉ែត្រសម្រាប់វាស់ស្ទង់នូវសមត្ថភាព និងការអភិវឌ្ឍន៍នៃចំណេះវិជ្ជាលើគ្រប់វិស័យទាំងអស់ មានវិស័យនយោបាយ ការទូត វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងវិស័យសង្គមកិច្ចជាដើម។

សារណាបញ្ចប់ការសិក្សាមួយនេះ ដែលបានធ្វើការស្រាវជ្រាវ ក្រោមប្រធានបទដែលមានចំណងជើងថា "ទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន" នាពេលនេះ គឺចង់បញ្ជាក់និងបង្ហាញឲ្យបានច្បាស់ថា គ្រប់សម័យកាលទាំងអស់ ការទំនាក់ទំនងអន្តរជាតិរវាងប្រទេសមួយ និងប្រទេសមួយ គឺពិតជាដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងសង្គមអន្តរជាតិ ជាពិសេសនាពេលបច្ចុប្បន្ននេះ ភាពរឹងមាំនៃច្បាប់អន្តរជាតិ ច្បាប់ស្តីពីទំនាក់ទំនងអន្តរជាតិ ច្បាប់ស្តីទំនាក់ទំនងការទូត និងបទដ្ឋានគតិយុត្តមួយចំនួនទៀតដែលទាក់ទងទៅនឹងកិច្ចការទំនាក់ទំនងអន្តរជាតិ ក៏ជាកត្តាសំខាន់ក្នុងន័យជម្រុញឲ្យពិភពលោកទាំងមូលកាន់តែងាកខិតជិតទៅរកគ្នាបន្តិចម្តងៗ តាមរយៈកិច្ចសហប្រតិបត្តិការលើផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ។

ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានពន្លត់ភ្លើងសង្គ្រាមផ្ទៃក្នុងដ៏រ៉ាំរ៉ៃរកទីបំផុតគ្មានមក គឺចាប់ពីឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាបានចាប់ផ្តើមកសាងប្រទេសជាតិឡើងវិញ ក្រោមទម្រង់នៃកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសជាច្រើននៅលើពិភពលោក ដែលក្នុងនោះសាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូធំមួយរបស់កម្ពុជាកាលពីពេលកន្លងទៅ រហូតប្រែក្លាយជាដៃគូដ៏ធំបំផុត និងសំខាន់បំផុត ដែលមិនអាចខ្វះបានក្នុងបរិបថការអភិវឌ្ឍរបស់ប្រទេសកម្ពុជា នៅពេលបច្ចុប្បន្ននេះ។ជាការពិតដែលមិនអាចប្រកែកបាន ប្រទេសទាំងពីរបានផ្តើមចេញពីទំនាក់ទំនងមិត្តភាព ហើយក៏ក្លាយជាកិច្ចសហប្រតិបត្តិការលើវិស័យនានា រហូតប្រែក្លាយជាកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើគ្រប់វិស័យ។ តួយ៉ាងសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ការគាំទ្រដល់កម្ពុជាជារឿយៗទាំងលើវិស័យនយោបាយ ការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ការផ្តល់ហិរញ្ញប្បទានឥតសំណង ក៏ដូចជាជំនួយផ្សេងៗជាច្រើនទៀតដល់ប្រទេសកម្ពុជា ក្នុងន័យបម្រើដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការជួយបណ្តុះបណ្តាលវិជ្ជាជីវៈ

ធនធានមនុស្ស វិស័យសង្គមកិច្ច និងរួមទាំងវិស័យការពារជាតិដែលជាកត្តាជម្រុញឲ្យប្រទេសកម្ពុជាមានការអភិវឌ្ឍន៍កាន់តែឆាប់រហ័ស។

ផ្ដើមចេញពីចក្ខុវិស័យខាងលើ ដែលបានបង្ហាញយ៉ាងច្បាស់អំពីសារៈសំខាន់ចេញពីកិច្ចទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ទើបខ្ញុំបាទសម្រេចចិត្តក្នុងការសិក្សាស្រាវជ្រាវ តាមដាន និងវិភាគអំពីប្រធានមួយនេះ ដើម្បីជាការចែករំលែកនូវចំណេះដឹង និងជាការជំនួយស្មារតីបន្ថែមដល់មហាជនទូទៅ ឲ្យយល់ដឹងឲ្យកាន់តែច្បាស់ថែមមួយកម្រិតទៀត ទាក់ទងទៅនឹងបរិបថនៃការអភិវឌ្ឍន៍ កាលានុវត្តភាពដែលសម្រេចបានចេញពីទំនាក់ទំនងរវាងប្រទេសទាំងពីរនេះ កាលពីពេលកន្លងទៅ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា តាមរយៈសារណាបញ្ចប់ការសិក្សាមួយនេះ នឹងក្លាយទៅជាប្រទីបដ៏តូចមួយ ដើម្បីជួយបំភ្លឺដល់បណ្ដានិស្សិត និងមហាជនទូទៅយ៉ាងពិតប្រាកដ។ ទន្ទឹមនឹងនេះផងដែរខ្ញុំបាទក៏បានគិតទុកជាមុនផងដែរថា នៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ រមែងនឹងជួបប្រទះនូវចំណុចខ្វះខាតមួយចំនួនដែលមិនបានគ្រោងទុក ទាំងការចងក្រង ការទាញយកនូវព័ត៌មាន ការវិភាគ និងការផ្ដល់ជាអនុសាសន៍ ដែលមិនងាយនឹងអាចជៀសផុតបាននោះ ខ្ញុំបាទសូមអធ្យាស្រ័យ និងអភ័យទោសទុកជាមុន ចំពោះរាល់កំហុសឆ្គងទាំងអស់នោះ ហើយប្ដេជ្ញានឹងទទួលយកនូវរាល់មតិយោបល់ល្អៗ ពុទ្ធិគំនិតជាវិជ្ជមាន និងការបំពេញបន្ថែមលើចំណុចខ្វះខាត ដោយសេចក្ដីគោរពស្រឡាញ់ រាប់អានក្នុងនាមជាកូនខ្មែរតែមួយ៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......១
**ជំពូកទី១៖ អតីតកាលនៃទំនាក់ទំនងកម្ពុជា-ចិន**......៤
**ផ្នែកទី១៖ សងនាដែលនាំឲ្យមានទំនាក់ទំនង**......៤
**កថាខណ្ឌទី១៖ ទំនាក់ទំនងមុន និងក្នុងសម័យអង្គរ**......៤
១. ទំនាក់ទំនងក្នុងសម័យហ្វូណន និងសម័យចេនឡា......៤
២. ទំនាក់ទំនងក្នុងសម័យអាណាចក្រអង្គរ......៨
**កថាខណ្ឌទី២៖ ជនជាតិភាគតិចចិននៅកម្ពុជា**......៩
១. ប្រវត្តិនៃជនជាតិភាគតិចចិន......៩
២. លំហូរជនជាតិភាគតិចចិនមកកម្ពុជា......១១
**ផ្នែកទី២៖ ទំនាក់ទំនងក្នុងអំលុងសម័យសង្គមរាស្ត្រនិយម**......១៣
**កថាខណ្ឌទី១៖ ដំណើរការទទួលបានឯករាជ្យជាតិ**......១៣
១. ចិនបានរួមចំណែកក្នុងការទាមទារឯករាជ្យឲ្យកម្ពុជា......១៤
២. សម័យសង្គមរាស្ត្រនិយមត្រូវបានបង្កើតឡើង......១៥
**កថាខណ្ឌទី២៖ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ**......១៦
១. ការចាប់ផ្តើមនៃទំនាក់ទំនងការទូត......១៦
២. ការពង្រឹងទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ......១៧
**ជំពូកទី២៖ បច្ចុប្បន្នកាលនៃទំនាក់ទំនងកម្ពុជាចិន**......១៩
**ផ្នែកទី១៖ កិច្ចសហប្រតិបត្តិការកម្ពុជា-ចិន (១៩៩៣-២០១០)**......១៩
**កថាខណ្ឌទី១៖ កិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ**......១៩
១. វិស័យយោធា......១៩
២. ដំណើរទស្សនកិច្ចផ្លូវការ......២១
**កថាខណ្ឌទី២៖ កិច្ចសហប្រតិបត្តិលើវិស័យសេដ្ឋកិច្ច ហិរញ្ញប្បទាន ឥណទានផ្សេងៗ**......២២
១. វិស័យពាណិជ្ជកម្ម និងវិនិយោគ......២៣
២. ការផ្តល់ហិរញ្ញប្បទាន និង ឥណទាន......២៤
**ផ្នែកទី២៖ កិច្ចសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ (២០១០-២០១៩)**......២៦
**កថាខណ្ឌទី១៖ កិច្ចសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្រលើវិស័យនយោបាយ យោធា ការទូត**......២៦

១. វិស័យនយោបាយ........................................................................២៧
២. វិស័យយោធា..........................................................................២៨
៣. វិស័យការទូត..........................................................................៣០
**កថាខណ្ឌទី២៖ កិច្ចសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្រលើវិស័យសេដ្ឋកិច្ច វិនិយោគ និងសង្គមកិច្ច**..........................................................................៣៧
១. វិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម..........................................................................៣៧
២. វិស័យវិនិយោគ..........................................................................៤២
៣. វិស័យសង្គមកិច្ច..........................................................................៤៧
**សេចក្តីសន្និដ្ឋាន**..........................................................................៥៧
**អនុសាសន៍**..........................................................................៦១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

ជាទូទៅប្រទេសនីមួយៗនៅលើពិភពលោក មិនអាចស្ថិតនៅក្នុងភាពឯកោបាននោះទេពោល គឺតម្រូវ និងទាមទារឲ្យមានការទំនាក់ទំនងរវាងប្រជាជាតិមួយទៅប្រជាជាតិមួយទៀត ទោះបីជាស្ថិតនៅក្នុងក្របខណ្ឌតំបន់ ឬក្របខណ្ឌពិភពលោកក៏ដោយ។

ការធ្វើទំនាក់ទំនងអន្តរជាតិ គឺជាគោលការណ៍ដ៏សំខាន់បំផុតរបស់ប្រទេសនីមួយៗក្នុងសង្គមអន្តរជាតិ ដោយហេតុថា មុខងាររដ្ឋ ឬប្រទេសនីមួយៗមានតួនាទីសំខាន់ណាស់ដូចជា ការចូលរួមជាមួយអង្គការអន្តរជាតិ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិ និងការបង្កើតស្ថាប័នទំនាក់ទំនងការទូតជាមួយគ្នាជាដើម។

ម្យ៉ាងវិញទៀត រដ្ឋក៏ដើរតួនាទីជាអ្នករៀបចំគោលនយោបាយជាតិ និងក៏ជាអ្នករៀបចំការពារនូវអធិបតេយ្យភាពរដ្ឋផងដែរ។ ក្នុងនាមជាអង្គការរៀបចំចាត់តាំងនយោបាយ រដ្ឋគឺជាអ្នកគ្រប់គ្រងរដ្ឋបាលដែនដី រក្សាថែទាំប្រជាពលរដ្ឋ ហើយនិងមានទំនួលខុសត្រូវលើផ្នែកផ្សេងៗដែលជាកន្សោម នៃយន្តការរបស់ប្រទេសជាតិមានដូចជា វិស័យសេដ្ឋកិច្ច យោធា នយោបាយ សង្គមកិច្ច និងទំនាក់ទំនងលើវិស័យដទៃៗជាច្រើនទៀតផងដែរ។ ម្យ៉ាងទៀត រដ្ឋក៏មានអំណាចអធិបតេយ្យភាព តាមរយៈការកសាង និងពង្រីកទំនាក់ទំនងរបស់ខ្លួនដោយឈរលើគោលការណ៍គោរពសិទ្ធិគ្នាទៅវិញទៅមក និងមិនចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរដ្ឋណាមួយដោយផ្ទាល់ ឬដោយប្រយោលនោះទេ ដើម្បីធ្វើយ៉ាងណាឲ្យស្របទៅតាមវិធាននៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ជាក់ស្ដែងដូចចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលរបស់ជាតិត្រង់ស្មារតីនៃមាត្រា៥៣ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ បានចែងថា "ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ភ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ គឺព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើពិភពលោក។"

ទន្ទឹមនឹងការការពារនូវអធិបតេយ្យភាព និងមិនចូលបក្សសម្ព័ន្ធ ព្រះរាជាណាចក្រកម្ពុជាក៏បានប្ដេជ្ញាក្នុងការមិនឈ្លានពានប្រទេសណាមួយជាដាច់ខាត មិនជ្រែតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោលតាមរយៈរូបភាពណាមួយឡើយ ប៉ុន្តែកម្ពុជាគាំទ្រជាដាច់ខាតចំពោះការដោះស្រាយរាល់បញ្ហានានាដោយសន្តិវិធី និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។

នាពេលបច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្តគោលនយោបាយប្រជាធិបតេយ្យ សេដ្ឋកិច្ចទីផ្សារសេរី ប្រកបដោយភាពរស់រវើកដែលជាកត្តាមួយជម្រុញឲ្យនីតិវិធីក្នុងការអភិវឌ្ឍន៍ប្រទេសកាន់តែមានលក្ខណៈសម្បូរបែប និងប្រកបដោយអានុភាពខ្ពស់បំផុតស្របតាម

តម្រូវការ និងស្ថានភាពជាក់ស្តែងរបស់ប្រទេសជាតិ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនឲ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។

ដូច្នេះពាក្យថា ទំនាក់ទំនងអន្តរជាតិ នេះមិនមែនមានតែក្នុងពេលបច្ចុប្បន្ននោះទេ គឺកើតតាំងពីយុគសម័យបុរាណកាលមកម្ល៉េះពោលគឺតាំងពីសតវត្សរ៍ទី១នៃសម័យប្រវត្តិសាស្ត្រដែលវាអាស្រ័យទៅលើស្ថានភាព កាលៈទេសៈ និងពេលវេលាជាក់ស្តែង។នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ អនុសញ្ញាទីក្រុងវីយ៉េនស្តីពីទំនាក់ទំនងការទូត (Vienna Convention on Diplomatic Relations) បានចូលជាធរមានឆ្នាំ១៩៦៤ ទើបញ៉ាំងឲ្យមានភាពរឹងមាំនៃបទដ្ឋានគតិយុត្តិនៃការទំនាក់ទំនងអន្តរជាតិ។

បើយោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ពាក្យថា "ទំនាក់ទំនង" គឺបានមកពីពាក្យពីរដោយឡែក គឺ "ទំនាក់" និង "ទំនង"។ ពាក្យថា "ទំនាក់" មានន័យថា ការទាក់គ្នា ប្រទាក់គ្នា ឧទាហរណ៍ថា ទំនាក់ទន្លេ គឺអាការនៃទន្លេដែលជាប់ទាក់គ្នា (ទន្លេមួយជាប់នឹងទន្លេមួយ) ចំណែកពាក្យ "ទំនង" មានន័យថា ដើមទង គន្លង លំអាន។ តាមរយៈអត្ថន័យនៃពាក្យទាំងពីរនេះ យើងអាចកំណត់ពាក្យ "ទំនាក់ទំនង" បានថា គឺជាអាការនៃប្រទេសមួយ ជាមួយនឹងប្រទេសមួយទៀត តាមរយៈការទាក់ទងគ្នាក្នុងក្របខណ្ឌបទដ្ឋានគតិយុត្តិ និងគោលនយោបាយនៃប្រទេសនីមួយៗ។

ជាទូទៅ ពាក្យដែលប្រើញឹកញាប់គឺ ទំនាក់ទំនងអន្តរជាតិ តាមន័យសាមញ្ញគឺបានសេចក្តីថា រវាងឬចន្លោះប្រទេសមួយទៅនឹងប្រទេសមួយទៀត។ ម្យ៉ាងទៀត បើយោងតាមនិយមន័យទំនាក់ទំនងអន្តជាតិមានន័យថា "គឺជាទំនាក់ទំនងរវាងរដ្ឋអធិបតេយ្យ ជាមួយនឹងរដ្ឋអធិបតេយ្យមួយទៀត ដោយឈរលើគោលការណ៍នៃច្បាប់អន្តរជាតិ ប៉ុន្តែអ្វីដែលសំខាន់នោះគឺថា ទំនាក់ទំនងអន្តរជាតិមានកម្មវត្ថុចម្បងមួយដែលផ្តោតការសិក្សា តាមរយៈការសិក្សាស្រាវជ្រាវទៅលើនយោបាយអន្តរជាតិ និងព្រឹត្តិការណ៍ទាំងឡាយដែលវិវឌ្ឍន៍នៅក្នុងពិភពលោក។"[1]

ក្នុងន័យនេះ ខ្ញុំបាទសូមលើកយកតែ ទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន ដែលបានធ្វើទំនាក់ទំនងយ៉ាងជិតស្និតជាមួយគ្នា តាំងពីយូរលង់ណាស់មកហើយ រហូតមកដល់ពេលបច្ចុប្បន្ន ដើម្បីធ្វើការស្រាវជ្រាវដូចខាងក្រោម។

## ២. ចំណោទបញ្ហា

ដោយយោងទៅលើ ទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន ដែលកំពុងតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ហើយមានសារៈសំខាន់បំផុតក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសគឺរឹតចំណងមិត្តភាពរវាង

[1] «សៀវភៅទំនាក់ទំនងអន្តរជាតិ» , របស់លោកសាស្ត្រចារ្យ ជុំ អ៊ឹម បោះពុម្ពលើកទី២

ប្រទេសទាំងពីរ ឲ្យកាន់តែមានលក្ខណៈប្រសើរឡើងថែមទៀតនោះ ក៏មានសំនួរមួយចំនួនបានចោទជាបញ្ហា ដែលទាមទារឲ្យមានការបកស្រាយ និងវិភាគក្នុងក្របខណ្ឌសិក្សាដូចខាងក្រោម៖

១.តើអ្វីទៅជាសារតាដែលនាំឲ្យមានទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន?

២.តើព្រះរាជាណាចក្រកម្ពុជាទទួលបានអត្ថប្រយោជន៍អ្វីខ្លះចេញពីកិច្ចទំនាក់ទំនងនេះ?

៣.តើកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរកើតឡើងតាំងពីពេលណា? មានអត្ថន័យដូចម្ដេច?

៤.តើប្រទេសទាំងពីរគួរធ្វើដូចម្ដេចខ្លះ ដើម្បីបន្តក្នុងការពង្រឹងទំនាក់ទំនងរបស់ខ្លួនឲ្យកាន់តែមានលក្ខណៈប្រសើរឡើង?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទស្តីអំពី «ទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន» នៅពេលនេះគឺដើម្បីសិក្សាស្វែងយល់ និងស្វែងដឹងអំពីទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលប្រទេសទាំងពីរនេះបាន និងកំពុងផ្តល់នូវកិច្ចសហប្រតិបត្តិការយ៉ាងល្អទៅលើគ្រប់វិស័យទាំងអស់ ដែលមានដូចជាវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច តាមរយៈការជួយកសាង ស្តារ និងអភិវឌ្ឍប្រទេសកម្ពុជា ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ឲ្យកាន់តែមានភាពរីកចម្រើនទៅមុខឥតឈប់ឈរ។

ម្យ៉ាងវិញទៀត ក៏ដើម្បី លើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋឲ្យកាន់តែមានភាពល្អប្រសើរប្រកបដោយសុខដុមរមនា ឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រដោយពិតប្រាកដ ក្នុងនាមជាដៃគូអភិវឌ្ឍគ្រប់ជ្រុងជ្រោយ តាមរយៈការពង្រីក និងពង្រឹងទំនាក់ទំនងនៃប្រទេសទាំងពីរឲ្យកាន់តែមានប្រសិទ្ធភាព និងភាពជឿជាក់ ក្នុងការអនុវត្តនូវរាល់ការងារនានា គឺធ្វើយ៉ាងណាទទួលបានភាពច្បាស់លាស់ប្រាកដប្រជាត្រឹមត្រូវ និងមានទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។

នៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ ខ្ញុំបាទបានធ្វើការសិក្សា និងវិភាគដោយបែងចែកចេញជា២ជំពូក ដែលក្នុងមួយជំពូកៗបែងចែកចេញជា២ផ្នែក ហើយក្នុងមួយផ្នែកៗបែងចែកជាពីរកថាខណ្ឌថែមទៀតផង។ ជាក់ស្តែងនៅក្នុងជំពូកទី១ ខ្ញុំបាទបានធ្វើការរៀបរាប់អំពី អតីតកាលនៃទំនាក់ទំនងព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន ហើយក្នុងជំពូកទី២ គឺបានធ្វើការរៀបរាប់អំពីបច្ចុប្បន្នកាលនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ព្រមទាំងសេចក្តីសន្និដ្ឋាន និងការផ្តល់ជាអនុសាសន៍សំខាន់ៗផងដែរ៕

# ជំពូកទី១ អតីតកាលនៃទំនាក់ទំនងកម្ពុជា-ចិន

## ផ្នែកទី១ សវតានៃដែលនាំឲ្យមានទំនាក់ទំនង

ការបង្កើតនូវកិច្ចទំនាក់ទំនងរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ ពីរដ្ឋមួយទៅរដ្ឋមួយ គឺសុទ្ធតែស្តែងចេញតាមរយៈពាក្យពេចន៍ រូបភាព និងសកម្មភាពនានាដើម្បីធ្វើការឆ្លុះបញ្ចាំងឲ្យមនុស្សទូទៅបានឃើញអំពីកិច្ចទំនាក់ទំនងរបស់យើង ដែលទាំងអស់នេះគឺសុទ្ធសឹងតែជាធាតុសំខាន់ៗក្នុងការបង្កើត និងបន្តឲ្យកិច្ចទំនាក់ទំនងកាន់តែរលូនទៅមុខ។

ម្យ៉ាងទៀត មានកត្តាជាច្រើនទៀតក៏នាំឲ្យទំនាក់ទំនងអាចកើតឡើងផងដែរ គឺកត្តាពេលវេលា និងការយល់ចិត្តគ្នា និងការបម្រើដល់ផលប្រយោជន៍រួម។ ជាក់ស្តែងនេះហើយគឺជាទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានកើតឡើងអស់រយៈពេលជាង២០០០ឆ្នាំមកហើយ គឺដោយសារតែការយល់ចិត្តគ្នា ការមិនរើសអើងគ្នា និងការគិតអំពីផលប្រយោជន៍ជារួម ផងដែរ ក៏មានសវតាមួយចំនួនទៀតដែលនឹងត្រូវបានរៀបរាប់ដូចខាងក្រោមៈ

### កថាខណ្ឌទី១. ទំនាក់ទំនងមុន និងក្នុងសម័យអង្គរ

យោងទៅតាម ទំព័រប្រវត្តិសាស្ត្រកម្ពុជា បានង្ហាញឲ្យឃើញថាទំនាក់ទំនងរវាងកម្ពុជា-ចិនគឺមានរយៈពេលជាង២០០០ឆ្នាំមកហើយ គឺតាំងពីក្នុងអំឡុងឆ្នាំ២៣០នៃសតវត្សទី៣ ដែលកាលនោះមានបេសកជនការទូតចិនគឺលោក **កាំង ថៃ** ឬ **ខាង ថាយ** និងលោក **ជូ លីង** ឬ **ជូ អ៊ីង** បានមកដល់នគរខ្មែរជាលើកដំបូង ដែលពេលនោះអ្នកការទូតទាំងពីរនេះបានហៅប្រទេសខ្មែរថា «ហ្វូណន»។

ជាការពិតដែលពិបាកក្នុងការប្រកែកនោះគឺ ប្រទេសកម្ពុជា និងប្រទេសចិនបានធ្វើទំនាក់ទំនងសេដ្ឋកិច្ចជាមួយគ្នាតាំងពីពេលនោះមក គឺតាមរយៈផ្លូវសូត្រលើសមុទ្រ គ្រឿងធ្វើពីព័រសឺឡែនកុម្ភៈការភ័ណ្ឌរបស់ចិន គ្រឿងក្រអូប និងក្រមួនរបស់កម្ពុជាត្រូវបានបញ្ជូនដល់ដៃប្រជាជនប្រទេសទាំងពីរជាបន្តបន្ទាប់ និងឥតឈប់ឈរ។ បន្ថែមទៀតនៅក្នុងប្រវត្តិសាស្ត្រ ក៏ត្រូវបានសរសេររៀបរាប់អំពី លោក **ជឹង ហឺ** (Zheng He) ដែលលោកគឺជានាវឹកចិននាសម័យមីង (Ming) ពេលដែលលោកបានធ្វើដំណើរតាមសមុទ្រ លោកបានស្នាក់នៅកម្ពុជាជាច្រើនលើកច្រើនសារ ដោយលោកបានរៀបរាប់តំបន់នោះថា "អាកាសធាតុក្តៅជានិច្ច សម្បូរស្រែចម្ការ សម្បូតទឹកសមុទ្រធ្វើជាអំបិល មានទំនៀមទម្លាប់ប្រពៃណីសម្បូរបែប។"[2]

#### ១.ទំនាក់ទំនងក្នុងសម័យហ្វូណាន និងសម័យចេនឡា

ពាក្យ «ហ្វូណន» គឺជាឈ្មោះចិននៃនគរបុរាណ ដែលស្ថិតនៅតំបន់ដីសណ្តទន្លេមេគង្គ ដែល

[2] ជឹង ហឺ,«ធ្វើជាអ្នកជិតខាងល្អ និងមិត្តភ័ក្តិពិតប្រាកដ» , *កម្ពុជាទស្សនៈថ្មី, ២០១៦*

ការកំណត់ឈ្មោះនេះត្រូវបានគេរកឃើញនៅ ក្នុងអត្ថបទប្រវត្តិសាស្ត្រចិនជាច្រើនដែលពិពណ៌នាពីតំបន់នេះ។ បើតាមចិនបុរាណអានថា «ប៊ីយូណាម» ដែលជាពាក្យគ្មានន័យអ្វីឲ្យប្រាកដ ក្នុងភាសាចិនទេ គ្រាន់តែចិនចាត់ទុកមនុស្សជាតិនៃតំបន់នេះភាគច្រើនគឺជា ខ្មែរ-មន ឬ អូស្ត្រូណេសៀន ព្រោះថា ហ្វូណនគឺត្រូវនឹងពាក្យថា ភ្នំ ដោយសំអាងថាកុលសម្ព័ន្ធភ្នំដែលរស់នៅលើតំបន់ខ្ពង់រាប នៅពេលសព្វថ្ងៃ គឺស្ថិតនៅក្នុងអំបូរខ្មែរមួយនេះ។

ម្យ៉ាងវិញទៀត បើសំអាងលើរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបុរាណខ្មែរ បានបង្ហាញថាខ្មែរក្នុងសម័យនោះមានសំលៀកបំពាក់ និងទម្លាប់ខ្លះដូចពួកភ្នំដែរ។[3] បើតាមការវិនិច្ឆ័យដែលបានចែងនៅក្នុងសៀវភៅប្រវត្តិសាស្ត្រចិន សរសេរដោយលោកសាស្ត្រាចារ្យ **អ៊ែល ប្រាំផ្ត** គឺកាន់តែបញ្ជាក់យ៉ាងកាន់តែច្បាស់ថា ជនជាតិខ្មែរ និងជនជាតិភ្នំក្នុងសម័យនោះ ពិតជាមានពូជអំបូរជាមួយគ្នាមែន ដោយសំអាងទៅលើលទ្ធផលនៃការសិក្សារបស់លោកទៅលើឈាមក្រហម (អេម៉ូក្លូប៊ីន)។[4]

បើក្រឡេកទៅមើលប្រវត្តិទំនាក់ទំនងរវាងប្រទេសទាំងពីរ លើផ្នែកនយោបាយ របស់សម័យហ្វូណន គឺមានលក្ខណៈតិចតួចតែប៉ុណ្ណោះ បានសេចក្តីថាក្រៅពីប្រទេសចិន គឺមេដឹកនាំក្នុងសម័យហ្វូណន កម្រនឹងធ្វើកិច្ចទំនាក់ទំនងជាមួយបណ្តាប្រទេសផ្សេងៗណាស់។ តួយ៉ាង មេដឹកនាំសម័យហ្វូណនបានធ្វើកិច្ចទំនាក់ទំនងការទូតរវាងគ្នាតាមរយៈការទិញ និងលក់ ជាមួយ មេដឹកនាំ **Wu** ដែលជាខ្សែរាជវង្សនៅភាគខាងកើតនៃប្រទេសចិន និងជាមួយខ្សែរាជវង្ស Han ស្ថិតនៅភាគខាងត្បូង នៃប្រទេសចិន។

បន្ថែមពីលើនេះទៀត មេដឹកនាំសម័យហ្វូណនបានពង្រីក និងបង្កើនទំនាក់ទំនង ការទូតជាមួយបណ្តាប្រទេសដទៃបន្ថែមទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺបន្ទាប់ពីការពង្រីកកិច្ចទំនាក់ទំនងរបស់ខ្លួនជាមួយរាជវង្ស ហានរួចមក។ កាលពីសម័យនោះ មេដឹកនាំហ្វូណនបានសិក្សារៀនសូត្រច្រើនពីប្រទេសចិន ទៅលើការការជួញដូរទំនិញពីឈ្មួញអ្នកលក់ទំនិញដែលមកពីប្រទេសចិនចូលមកប្រទេសហ្វូណន។ផងដែរ មេដឹកនាំហ្វូណនបានសិក្សារៀនសូត្រអំពីការជីករកសំរិទ្ធ មាស នៅក្នុងប្រទេសកម្ពុជា ពីពួកឈ្មួញចិនផងដែរ ។[5]

ប្រវត្តិសាស្ត្រ និងពេលវេលាចេះតែរំកិលទៅមុខឥតឈប់ឈរ រហូតដល់ក្នុងអំលុងឆ្នាំ២៣០ និងឆ្នាំ២៨៧ ដែលជារជ្ជកាលរបស់ព្រះអង្គ **ហ្វានឆាន** និងព្រះអង្គ **ហ្វាន ស៊ីយុន** ក៏បានបង្កើនទំនាក់

[3] ឯកសាររបស់អ្នកប្រាជ្ញចិន លាង ស្ស៊ូ ,»សៀវភៅលាង» ,នៅឆ្នាំ៦៣៦, ម.៦៣៧

[4] លោកសាស្ត្រាចារ្យ អ៊ែល ប្រាំផ្ត (L. Brumpt) ជនជាតិបារាំង, «ប្រវត្តិសាស្ត្រខ្មែរសម័យនគរភ្នំ (ហ្វូណន) គ.ស ៥២-៦២៧», *Sakhan*, ២០១៧

[5] លោកសាស្ត្រចារ្យជនជាតិបារាំង លោក George Coedes, «inscriptions du Cambodge», vols. 1-7 vol.1

ទំនងជាមួយប្រទេសចិនតាមរយៈការបញ្ជូនរាជទូតទៅកាន់ប្រទេសចិនជារឿយៗ ចំណែកប្រទេសចិនវិញក៏បានធ្វើការបញ្ជូនរដ្ឋទូតរបស់ខ្លួនមកវិញផងដែរ ដែលក្នុងន័យបំពេញនូវតម្លៃការទូតរវាងប្រទេសទាំងពីរ ដែលយោងតាមកំណត់ត្រាគឺកើតមានឡើងចំនួន៣លើកធំៗ។ នៅលើកទី១គឺការបញ្ជូនរាជទូតខ្មែរទៅកាន់ប្រទេសចិននៅឆ្នាំ២៤៣ ដែលកាលនោះខ្មែរបានពាំនាំនូវឧបករណ៍ភ្លេងខ្មែរ និងផលិតផលដទៃៗទៀតទៅថ្វាយស្តេចចិន។ ចំណែកឯលើកទី២ នៅចន្លោះឆ្នាំ២៤៥-២៥០ ដែលកាលនោះស្តេចចិន បានបញ្ជូនរដ្ឋទូតមកជួបស្តេចខ្មែរនៅក្នុងរាជវាំងនៃប្រទេសខ្មែរវិញ និងលើកទី៣ ដែលជាលើកចុងក្រោយនោះគឺស្តេច**ហ្វាន ស៊ីយុន** បានបញ្ជូនរាជទូតទៅប្រទេសចិនវិញ នៅចន្លោះឆ្នាំ២៨៥-២៨៧ ដែលព្រឹត្តិការណ៍ទាំងអស់នេះគឺត្រូវបានគេសន្និដ្ឋានថា ជាការហុចផលវិជ្ជមានដល់សន្ទុះនៃការធ្វើជំនួញផ្លូវសមុទ្រ ព្រោះព្រឹត្តិការណ៍ទាំងអស់នេះបានបំពេញដល់សេចក្តីត្រូវការរៀងៗខ្លួនតាមរយៈការទទួលបាននូវវត្ថុប្រណីត និងសម្ភារៈដទៃៗទៀតពីស្តេចខ្មែរ ទៅស្តេចចិន និងពីស្តេចចិនមកស្តេចខ្មែរវិញជាច្រើនច្រើនសារ។[6]

អ្វីដែលកាន់តែឆ្លុះបញ្ចាំងអំពីទំនាក់ទំនងមិត្តភាពរវាងខ្មែរ និងចិនកាន់តែខ្លាំងទៀតនោះគឺនៅក្នុងអំលុងឆ្នាំ៤០០ មានស្តេចខ្មែរមួយអង្គព្រះនាម **ឆេលីតោប៉ាម៉ោ (ស្រីឥន្ទ្រវរ្ម័ន រឺ ស្រេស្ឋវរ្ម័ន)** បានប្រកែកមិនចូលរួមជាមួយចម្ប៉ា ដើម្បីដណ្តើមយកខេត្តតុងកឹងរបស់ប្រទេសចិន ផ្ទុយទៅវិញ ថែមទាំងបាននាំសួយ និងដង្វាយទៅថ្វាយស្តេចក្រុងចិនជាច្រើនលើក នៅឆ្នាំ៤៣៤ ឆ្នាំ៤៣៥ និងឆ្នាំ៤៣៨។

បន្ទាប់ពីការដួលរលំនៃសម័យហ្វូណនមក សម័យចេនឡាក៏ត្រូវបានកើតឡើង។ បើយោងតាមអ្នកប្រាជ្ញ និងអ្នកនិពន្ធ និងក៏ជាបេសកជនចិនដែលមានឈ្មោះថា **ជីវ តាក្វាន់** ក្រោយពេលលោកបានបំពេញទស្សនកិច្ចនៅប្រទេសខ្មែរ លោកក៏បានចងក្រងសៀវភៅមួយក្បាលដែលមានចំណងជើងថា «កំណត់ហេតុទឹកដីនិងប្រពៃណីអ្នកស្រុកចេនឡា» ឬ «The Customs of Cambodia» លោកបានចងក្រងថាពាក្យ «ចេនឡា» គឺត្រូវបានបង្កើតដោយប្រទេសចិន ហើយត្រូវបានគេយកទៅប្រើប្រាស់តាំងពីពេលនោះមក។ នៅក្នុងសៀវភៅកំណត់ហេតុនោះលោក បានកត់ត្រានូវជីវិតរស់នៅទំនៀមទម្លាប់ប្រពៃណី និងទំនាក់ទំនងរវាងប្រជាជននៃប្រទេសខ្មែរ-ចិន ដែលទំនាក់ទំនងនេះបានគ្របដណ្តប់ទៅលើវិស័យធំៗដូចជា វិស័យពាណិជ្ជកម្ម នយោបាយ និងវប្បធម៌ផងដែរ។ ជាក់ស្តែងលោកក៏បានធ្វើការប្រៀបធៀបអំពីជាយក្រុងកំពង់ចាម ដែលមានវិហារមួយឈ្មោះថា «វិហារសានប៉ាវ» គឺមានផ្សែងធូបហុយឥតឈប់ឈរ ដែលប្រៀបដូចទៅនឹងទំនាក់ទំនង ដែលមិនអាចកាត់ផ្តាច់

[6] ឯកសាររបស់អ្នកប្រាជ្ញចិន លាង ស៊្វូ ចំណងជើង "សៀវភៅលាង" ម.៦៣៧ នៅឆ្នាំ៦៣៦

បានរវាងប្រជាជននៃប្រទេសចិន និងប្រជាជននៃប្រទេសខ្មែរ។

ក្នុងសម័យរជ្ជកាលនៃភាគខាងត្បូង និងភាគខាងជើងនៃប្រទេសចិន ក្នុងអំឡុងសតវត្សរ៍ទី៥ ដល់សតវត្សទី៦ មានព្រះសង្ឃរាជខ្មែរចំនួន៣អង្គ ព្រះនាម**សង្ឃវរ្ម័ន** ព្រះនាម**មណ្ឌល** និង ព្រះនាម **សុភូតិ** បាននិមន្តទៅប្រទេសចិនដើម្បីធ្វើការផ្សព្វផ្សាយធម៌អាថ៌ជាបន្តបន្ទាប់។ ដូចនេះហើយ ទើបគេអាចសន្និដ្ឋានបានថា ការមកដល់អាណាចក្រអង្គររបស់លោក **ជីវ តាក្វាន់** ក្នុងឆ្នាំ១៣៩៣ និងរបាយការណ៍របស់លោកអំពីស្រុកខ្មែរនៅពេលនោះ រឹតតែបញ្ជាក់អំពីភាពស្និទ្ធស្នាលនៃទំនាក់ទំនងរបស់ប្រទេសទាំងពីរ។

*សុភាសិតមួយពោលថា "ទំនុកចិត្តប្រៀបដូចដើមឈើដែលត្រូវការបណ្ដុះនិងថែទាំ"*

តាមរយៈសុភាសិតមួយនេះ វាប្រៀបបានទៅនឹងទំនាក់ទំនងមិត្តភាពកម្ពុជា-ចិន ដែលបានឆ្លងកាត់ពេលវេលា និងបទពិសោធន៍ប្រែប្រួលអន្តរជាតិឥតឈប់ឈរ ហើយប្រទេសទាំងពីរនេះ នៅតែអាចអភិវឌ្ឍ និងរីកចម្រើនទៅមុខបាន គឺដោយសារតែគ្រឹះរឹងមាំ ដែលថ្នាក់ដឹកនាំជំនាន់មុនៗនៃប្រទេសទាំងពីរ ជាអ្នកពូនជ្រំដោយយកចិត្តទុកដាក់ជាទីបំផុត។

ឈានទៅដល់សម័យចក្រភពអង្គរ នៅសតវត្សទី៩ រហូតដល់សតវត្សទី១៣ គឺគិតចាប់ពីឆ្នាំ ៨០២ ដល់ ឆ្នាំ១២៤៣ ដែលក្នុងអំលុងពេលនោះមានស្ដេចខ្មែរគ្រប់គ្រងអាណាចក្រសរុបចំនួន ២១ អង្គដែលសុទ្ធសឹងជាព្រះរាជវង្សានុវង្សរបស់ខ្សែ **វរ្ម័ន** ។

បើយោងតាមឯកសាររបស់បរទេសដែលបានចងក្រង គេជឿថា សម័យអង្គរគឺជាសម័យដ៏រុងរឿងបំផុតនៃអារ្យធម៌ខ្មែរ គឺដោយផ្អែកថាបុព្វបុរសខ្មែរបានកសាងទាំងវប្បធម៌ ទាំងសង្គមធម៌ឲ្យបានរីកចម្រើនជឿនលឿន ហើយជម្រុញប្រទេសខ្មែរអោយមានឈ្មោះល្បីល្បាញ ជាមហាអំណាចមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ផ្ទៃដីដ៏ធំទូលំទូលាយនាសម័យនោះ រួមទាំងសំណល់វប្បធម៌ជាប្រាសាទបុរាណដ៏ច្រើនសន្ធឹកស្ទើរតែពេញផ្ទៃឥណ្ឌូចិនទាំងមូល សិលាចារឹក សិល្បៈដ៏សម្បូរបែប និងបដិមាបុរាណវត្ថុផ្សេងៗរាប់មិនអស់ ដែលសេសសល់ដល់សព្វថ្ងៃនេះ គឺជាភស្តុតាងជាក់ស្ដែងបញ្ជាក់ពីភាពរុងរឿងនៃអារ្យធម៌ខ្មែរសម័យអង្គរនេះ។

ក្នុងសម័យកាលរុងរឿងនេះ សាសនាមានមុខងារសំខាន់ណាស់។ គេសង្កេតឃើញព្រះរាជាខ្លះកាន់សាសនាព្រះឥសូរ ព្រះរាជាខ្លះកាន់សាសនាព្រះវិស្ណុ ព្រះរាជាខ្លះកាន់សាសនាព្រះព្រហ្ម និងព្រះរាជាខ្លះទៀត កាន់ព្រះពុទ្ធសាសនា។ ប៉ុន្តែទោះជាព្រះអង្គកាន់សាសនាណាក៏ដោយ ក៏ព្រះរាជាខ្មែរក្នុងសម័យនោះ ភាគច្រើនបានថែរក្សាការពារសាសនាដទៃទៀតអោយរួមរស់ដោយសុខសន្តិភាពជាមួយគ្នា។ ជាក់ស្ដែង តាមរយៈជំនឿសាសនានេះហើយ ទើបប្រាសាទភ្នំធំៗជាច្រើន ត្រូវបានកសាងឡើង ដើម្បីតម្កល់ «លិង្គទេវរាជ» សម្រាប់អ្នកកាន់សាសនាព្រះឥសូរ តម្កល់បដិមាព្រះវិស្ណុ

សម្រាប់អ្នកកាន់សាសនាព្រះវិស្ណុ ដូចប្រាសាទអង្គរវត្ត ក្នុងរជ្ជកាលព្រះបាទសូរិយាវរ្ម័នទី២ តម្កល់បដិមាព្រះពុទ្ធ គឺ "ពុទ្ធរាជ" សម្រាប់អ្នកកាន់សាសនាព្រះពុទ្ធ ដូចប្រាសាទបាយ័នរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ជាដើម។ ចំណែកឯប្រាសាទវិញគឺត្រូវបានសាងសង់ជាច្រើន ដែលភាគច្រើនគឺសាងសង់នៅលើដីទំនាប ដើម្បីធ្វើការឧទ្ទិសចំពោះអ្នកដ៏មានគុណ អ្នកជាទីសក្ការៈ ឬបុព្វការីជនផ្សេងៗ ដែលប្រវត្តិវិទូមួយចំនួននិយមអោយឈ្មោះថា "លទ្ធិបុគ្គលនិយម" ថែមទៀតផង។

ម្យ៉ាងទៀត គឺដោយសារជំនឿទៅលើលទ្ធិទេវរាជ ឬសាសនាព្រះវិស្ណុ ឬក៏ពុទ្ធរាជនេះហើយ ដែលធ្វើអោយព្រះរាជាក្លាយជាតំណាងអាទិទេពលើផែនដី ឬក៏ជាតំណាងអវតារនៃព្រះអាទិទេព ឬក៏ជាតួអង្គព្រះពោធិសត្វ ដែលរស់លើផែនដីជាមួយមនុស្ស ជួយស្រោចស្រង់មនុស្សលោកអោយឆ្លងផុតភពទុក្ខ ខំកសាងសុខសុភមង្គល អោយមនុស្សជាតិខិតខំកសាងផែនដីតាមគំរូនៃឋានសួគ៌ដ៏ល្អប្រណិតឥតអ្វីប្រៀប ដែលយើងឃើញមានជាសំណល់ជាប្រាសាទ បារាយណ៍ទឹក មន្ទីរពេទ្យ ស្ពានថ្មល់ដ៏ច្រើនសន្ធឹកសន្ធាប់ រហូតមកដល់សព្វថ្ងៃនេះ។[7]

## ២. ទំនាក់ទំនងក្នុងសម័យអាណាចក្រអង្គរ

ព្រះរាជានៃមហាអាណាចក្រអង្គរ មានអំណាចខ្លាំងក្លា និងមានភាពរុងរឿងណាស់។ ព្រះអង្គទ្រង់ជាម្ចាស់លើដីធ្លីទាំងអស់ ជាមេដឹកនាំនយោបាយ ទាំងក្នុង និងក្រៅប្រទេស ជាមេទ័ពក្នុងសមរភូមិដ៏ចំណាន ទ្រង់ដឹកនាំទ័ពដែលប្រកបដោយវិន័យ និងថាមពលខ្លាំងក្លា ដូចអត្ថបទសិលាចារឹកជាច្រើនបានកោតសរសើរ ចំពោះគុណសម្បត្តិយោធារបស់ព្រះរាជា ថាសុទ្ធសឹងតែមានតេជដៃថ្វីព្រះហស្តខ្លាំងពូកែ ទទួលបានជ័យជម្នះលើខ្មាំងសត្រូវជានិច្ច។ ព្រះអង្គជាមេតុលាការ និងជាមេសាសនាថែមទៀតផង។ ព្រះរាជាទ្រង់ប្រទានសវនាការពីរដងក្នុងមួយថ្ងៃ សម្រាប់ដោះស្រាយកិច្ចការប្រទេសជាតិ។ តួយ៉ាង បើតាមការកំណត់ហេតុរបស់លោក **ជីវ តាក្វាន់** ដែលបានមកកាន់ប្រទេសខ្មែរ នៅចុងសតវត្សទី១៣ បានពណ៌នាយ៉ាងក្បោះក្បាយថា "ភាសាចិនមានសម្លេងប្រហាក់ប្រហែលនឹងភាសាអ្នកស្រុកខ្មែរដែរ តែនិយាយប្រាស្រ័យស្តាប់គ្នាមិនបានទេ ព្រោះថាស្រុកនេះមានភាសាមួយពិសេស ទោះបីជាភាសាអ្នកជិតខាងខ្លួនដូចជា ចាម ឬសៀម ក៏មិនអាចស្តាប់គ្នាបានដែរ។

ម្យ៉ាងមួយទៀត នៅសម័យនោះមន្ត្រីគេនិយាយតាមបែបមន្ត្រី អ្នកប្រាជ្ញនិយាយគ្នាតាមភាសាអ្នកប្រាជ្ញ លោកសង្ឃ ឬតាបស ក៏មានពាក្យសម្តីប្រើរបៀបខ្លួនជាសង្ឃ ឬជាជាតាបសផងដែរ ចំណែកឯអ្នកស្រែចម្ការក៏និយាយប្លែកតាមបែបរបស់គេដែរ មិនខុសប្លែកអ្វីពីរបៀបប្រើភាសារបស់អ្នកស្រុកចិនទេ។

បើយើងក្រឡេកទៅមើល ចម្លាក់អំពីសិល្បៈសៀកចិន នៅលើប្រាសាទបាយ័នបានបញ្ជាក់ថា

[7] »អរិយធម៌ខ្មែរសម័យអង្គរនិងការស្រុតចុះ» ,*វិទ្យុអាស៊ីសេរី,* ចុះផ្សាយថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

នៅក្នុងពិធីបុណ្យទានធំៗ គេឃើញមានការសម្តែងនូវទស្សនីយភាពមួយចំនួនដូចជា ល្បែងឈុតឈរតម្រៀបជាន់លើគ្នា ឈុតជិះដំរីវាយកូនឃ្លី ការបង្វិលខ្លួន លើចុងបង្គោលឈើ ឈុតដើរសួរលើព្រ័ត្រ ឈុតលេបកាំបិតវែងនិងខ្លី និងឈុតលើកទម្ងន់ជាដើម។ ប្រសិនបើយើងទស្សនាឈុតសៀកចិនបច្ចុប្បន្ន យើងនឹងឃើញមានលក្ខណៈដូចគ្នាទៅនឹងឈុតដែលបានឆ្លាក់លើថ្មប្រាសាទខ្មែរមួយចំនួន ដែលជាមូលហេតុធ្វើឲ្យយើងជឿថា សម្ព័ន្ធភាពផ្នែកទស្សនីយភាពរវាងជនជាតិចិន និងជនជាតិខ្មែរគឺពិតជាកើតមានក្នុងសម័យកាលនោះ។

តាមរូបចម្លាក់គេឃើញថា កាយវិការ សម្លៀកបំពាក់ និងបរិបទវប្បធម៌សង្គមខ្មែរ ដែលខ្មែរជាអ្នកសម្តែងសម្រាប់បង្ហាញដល់មហាជនក្នុងព្រះរាជធានី មិនមែនចិនបែបចិនទេ មានន័យថាសិល្បករខ្មែរមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសឈុត និងទីតាំងសម្រាប់សម្តែងដោយមិនបានស្លៀកពាក់ ឬប្រគុំទំនុកបទភ្លេងតាមបែបចិននោះឡើយ។

## កថាខណ្ឌទី២ ជនជាតិភាគតិចចិននៅកម្ពុជា

### ១. ប្រវត្តិនៃជនជាតិភាគតិចចិន

បើយោងទៅតាមវចនានុក្រមខ្មែរ ក្នុងអំឡុងឆ្នាំ(១៩៦៧:១៩៧) បានពន្យល់ថា "ចិនគឺជាជាតិមនុស្សមួយប្រភេទមានដើមកំណើតនៅប្រទេសចិន ឬមកពីប្រទេសចិនមកនៅក្នុងប្រទេសកម្ពុជា" ដូចដែលបានរៀបរាប់ពីខាងលើ ស្របពេលដែលឯកសារប្រវត្តិសាស្ត្រកម្ពុជានៅក្នុងសតវត្សដំបូងៗ ដូចជាកំណត់ត្រារបស់បេសកទូតចិនលោក **ម៉ា ទួនលីន** និងលោក **ជីវ តាក្វាន់** គឺមានភស្តុតាងដែលផ្អែកលើបុរាណវត្ថុវិទ្យា តាមរយៈចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និងឯកសារបរទេសផ្សេងៗទៀត អ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថា ជនជាតិចិនប្រហែលមកដល់ប្រទេសកម្ពុជាតាំងពីសតវត្សទី១នៃគ្រឹស្តសករាជមកម្ល៉េះ។[៩]

ចំណែកឯអ្នកស្រាវជ្រាវខ្លះទៀតក៏បានអះអាងថា ទំនាក់ទំនងការទូតប្រទេសចិន និងខ្មែរបានចាប់ផ្តើមនៅរវាងឆ្នាំ២២៥-៣៣០នៃគ្រឹស្តសករាជ ដែលសម័យកាលនោះគឺមានជនភៀសខ្លួនជនជាតិចិនបានចូលមករស់នៅក្នុងប្រទេសខ្មែរជាបន្តបន្ទាប់។ ជនភៀសខ្លួនជនជាតិចិនដែលមកកាន់កម្ពុជាទាំងនោះ ភាគច្រើនមានដើមកំណើតចេញមកពីទីជនបទប្រទេសចិន ហើយមូលហេតុដែលនាំឲ្យជនជាតិចិនមកកាន់ប្រទេសខ្មែរយ៉ាងសន្ធឹកសន្ធាប់នោះគឺ ដោយសារពួកគេចង់គេចចេញពីការលក់កម្លាំងពលកម្មឲ្យក្រុមគ្រួសារជនជាតិចិនជាអ្នកមាន តាមរយៈការបង្ខិតបង្ខំចុះកិច្ចសន្យាលក់កម្លាំងពលកម្មឲ្យភ្នាក់ងារអាណានិគម សង្គ្រាមក្នុងតំបន់រស់នៅរបស់ពួកគេ ការរត់ភៀសខ្លួនពីការឈ្លានពានរបស់កងទ័ពជប៉ុន ការគេចពីកាតព្វកិច្ចយោធា ទឹកជំនន់ និង គ្រោះទុរ្ភិក្សជាដើម។

[៩] អ្នកវិទ្យាសាស្ត្រជនជាតិបារាំងឈ្មោះ Jean Boisselier, «LE Cambodge», ឆ្នាំ១៩៦៦, Edition A et P.Picard,

បើយោងតាមការកត់សម្គាល់របស់ **ជីវ តាក្វាន់** កត្តាភូមិសាស្ត្រ ធនធានធម្មជាតិ និងសង្គមខ្មែរនាពេលនោះក៏អាចជាចំណែកដ៏ធំក្នុងការទាក់ទាញដល់ជនភៀសខ្លួនចិនមករស់នៅផ្ញើជីវិតនៅលើទឹកដីកម្ពុជាផងដែរ៖

"ពួកជនជាតិចិនដែលជាអ្នកស៊ីឈ្នួលដើរសំពៅកាលមកដល់ស្រុកនេះគឺគេពេញចិត្តខ្លាំងណាស់ព្រោះស្រុកនេះមិនបាច់ប្រើសម្លៀកបំពាក់ច្រើនហើយអង្ករក៏ស្រួលរកប្រពន្ធក៏ស្រួលរកបាន ឯផ្ទះសំបែងក៏ស្រួលធ្វើគ្រឿងប្រើប្រាស់ក៏ងាយរកការលក់ដូរក៏ធូរងាយម្ល៉េះហើយបានជាមានអ្នកចូលពីស្រុកក្រៅមករស់នៅស្រុកនេះច្រើនណាស់"[៩]

ស្ត្រីខ្មែរក៏ប្រហែលជាហេតុផលមួយផ្សេងទៀត ដែលជម្រុញទឹកចិត្តដល់បុរសជនជាតិចិនជាច្រើនមកកម្ពុជា។ លោក ជីវ តាក្វាន់បានសរសើរស្ត្រីខ្មែរថាពូកែរកស៊ី និងឧស្សាហ៍ព្យាយាម ដែលជាកត្តាទាក់ទាញបុរសជនជាតិចិនចង់បានស្ត្រីខ្មែរជាប្រពន្ធ៖

"អ្នកស្រុកនេះពួកស្រីៗប៉ិនជួញដូរណាស់ ហេតុនេះហើយទើបពួកចិនៗគេត្រូវការរកប្រពន្ធមួយជាមុនសិនហើយនឹងបានចំណេញច្រើនដោយសារគេប៉ិនប្រសព្វរកស៊ីរាល់ថ្ងៃគេទៅលក់តាំងពីភ្លឺព្រាងៗដល់ពេលថ្ងៃត្រង់ទើបឈប់""[10]

បើតាមឯកសាររបស់អ្នកវិទ្យាសាស្ត្រឈ្មោះ **Jean Boisselier** ជនជាតិបារាំង កើតថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩១២ ដោយលោកជឿថា ជនជាតិចិន ឬខ្មែរកាត់ចិន ឬកូនចៅចិន ជាជនជាតិចិនភាគតិចមួយ ដែលបានភៀសខ្លួនពីស្រុកចិនមករស់នៅលើទឹកដីនៃប្រទេសកម្ពុជា ដោយសារមូលហេតុគេចចេញពីស្ថានភាពលំបាកក្នុងសង្គម ឬបញ្ហាសង្គ្រាមស៊ីវិលនៅប្រទេសចិន ដើម្បីស្វែងរកឱកាសរស់រានមានជីវិត។

ជនជាតិចិនទាំងនោះធ្វើដំណើរផ្សងព្រេងតាមសមុទ្រទាំងប្រថុយប្រថានបំផុត ដែលពេលក្រុមនេះមកដល់ស្រុកខ្មែរដំបូងគឺខ្លាចក្រែងម្ចាស់ស្រុកណាស់ មិនហ៊ានក្រអឺតក្រទមនោះឡើយ ដែលខ្មែរយើងហៅពួកចិនទាំងអស់នោះថា **ចិនឆៅ** ។[11] អន្តោប្រវេសន៍ជនជាតិចិនទាំងនោះ ភាគច្រើនជាបុរសហើយរៀបការជាមួយស្ត្រីខ្មែរបង្កើតបានជាកូនពូនជាចៅ ដែលខ្មែរនិយមហៅថា **កូនចៅចិន** ។ ពួកចិនទាំងនេះក៏ចេះពីរបៀបរស់នៅក្នុងសង្គមខ្មែរ ចេះសម្របខ្លួនក្នុងសហគមន៍ខ្មែរ មានអាកប្បកិរិយាសមរម្យ ហើយក៏មានឥទ្ធិពលលើផ្នែកសេដ្ឋកិច្ចលើសហគមន៍កសិករខ្មែរផងដែរ ដែល

[៩]អ្នកវិទ្យាសាស្ត្រចិនកាត់ខ្មែរឈ្មោះ លី ធាមតេង, «កំណត់ហេតុជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា», *មូលនិធិខ្មែរសម្រាប់ការសិក្សា,* បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៣

[10]អ្នកវិទ្យាសាស្ត្រចិនកាត់ខ្មែរឈ្មោះ លី ធាមតេង, «កំណត់ហេតុជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា», *មូលនិធិខ្មែរសម្រាប់ការសិក្សា,* បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៣

[11]ផេនី អេដ្វឺដ្ស ២០០៩:១៧៣

ពេលនោះគឺជាដំណើរការសមាហរណកម្មមួយដែលនាំឲ្យជនជាតិចិនទាំងនោះមានឥរិយាបថចុះសម្រុងទៅនឹងសង្គមធម៌ និងវប្បធម៌ខ្មែរផងដែរ។

**២. លំហូរជនជាតិភាគតិចចិនមកកម្ពុជា**

នៅឆ្នាំ១៦២០ ជនជាតិភាគតិចចិនបានបង្កើតភូមិចិនមួយនៅក្នុងទីក្រុងភ្នំពេញ។ បុរសៗជនជាតិភាគតិចចិនបានយកនារីខ្មែរធ្វើជាប្រពន្ធ ដែលជាហេតុធ្វើឲ្យជីវិតពួកគេមួយផ្នែកធំអាចចុះសម្រុងទៅនឹងសង្គមវប្បធម៌ខ្មែរ និងអាចរស់នៅដោយសុខសាន្ត។ នៅចន្លោះរវាងសតវត្សទី១៨ និង១៩ អន្តោប្រវេសន៍ជនជាតិចិន បានចូលមកប្រទេសកម្ពុជាកាន់តែច្រើនឡើងៗ ហើយភាគច្រើនមកពីតំបន់ភូមិភាគឥសាននៃប្រទេសចិន និងមានអម្បូរភាសាខុសៗគ្នា។ [12] បើទោះបីជាមានការសិក្សាអំពីជនជាតិចិន នៅប្រទេសខ្មែរជាច្រើនយ៉ាងណាក៏ដោយក្តី ក៏ប៉ុន្តែរហូតដល់បច្ចុប្បន្នមិនមានការបញ្ជាក់ឲ្យច្បាស់អំពីស្ថិតិជនជាតិភាគតិចចិនរស់នៅក្នុងប្រទេសកម្ពុជានៅឡើយនោះទេ គ្រាន់តែគេដឹងថាមកទល់បច្ចុប្បន្ននេះមានចំនួន៥ក្រុមអម្បូរធំៗដោយធ្វើការផ្អែកទៅលើភាសានិយាយ។

១. ចិនទាជីវ

ជនជាតិចិនទាជីវ មានស្រុកកំណើតនៅខេត្តក្វាងទុងនៃប្រទេសចិន។ [13] គេឃើញចិនទាជីវសព្វថ្ងៃនេះរស់នៅទីក្រុងភ្នំពេញ ខេត្តកំពត និងខេត្តកំពង់ចាម។ មានជនភៀសខ្លួនចិនទាជីវរាប់ម៉ឺននាក់មករស់នៅកម្ពុជា ក្រោយពេលដែលប្រទេសសៀមដណ្តើមគ្រប់គ្រងបានខេត្តបាត់ដំបងនៅឆ្នាំ១៩៤១។ ចិនទាជីវច្រើនជាអ្នកមានមុខរបរខាងជំនួញពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្មតាមគ្រួសារ បើកហាងកាហ្វេ ធ្វើស្រែចំការ។

២. ចិនកន្តាំង

នៅទសវត្សរ៍ឆ្នាំ១៨៨០ ចិនកន្តាំងបានរីកចម្រើន និងធំឡើងនៅទីក្រុងភ្នំពេញ ដែលមកទល់នឹងទសវត្សរ៍១៩៦០ ចិនកន្តាំងបានក្លាយទៅជាក្រុមជនជាតិភាគតិចច្រើនជាងគេលំដាប់ទី១នៅក្នុងកម្ពុជា។ ជនជាតិភាគតិចចិនកន្តាំងនេះផ្តោតទៅលើមុខរបរខាងសិប្បកម្ម និងសំណង់។[14]

៣. ចិនហៃណាំ

ក្រុមជនជាតិភាគតិចចិនហៃណាំ មានប្រភពមកពីកោះហៃណាំនៃប្រទេសចិន ដែលបានមក

---

12 អ្នកវិទ្យាសាស្ត្រអាមរិកឈ្មោះ William Willmot, «The Political Structure of the Chinese Community in Cambodia», *Berg Publisher*, ឆ្នាំ១៩៧០ ទំព័រទី៦

13 [13] អ្នកវិទ្យាសាស្ត្រអាមរិកឈ្មោះ William Willmot, «The Political Structure of the Chinese Community in Cambodia», *Berg Publisher*, ឆ្នាំ១៩៧០ ទំព័រទី៧

14 អ្នកវិទ្យាសាស្ត្រអាមេរិកឈ្មោះ ផេនី អេដ្វឺដ្ស (Penny Edwards), «Cambodge: The Cultivation of a Nation» *University of Hawaii Press,* បោះពុម្ពលើកទី១, ២០០៨

ដល់កម្ពុជានៅឆ្នាំ១៦៧៥។ ចិនហៃណាំមានមុខរបរខាងឧស្សាហកម្មផលិតនំ ធ្វើចុងភៅ លក់កាហ្វេ និងជាអ្នកបម្រើការងារតាមផ្ទះឲ្យគ្រួសារជនជាតិអឺរ៉ុប រកស៊ីចងការប្រាក់ និងធ្វើកសិដ្ឋានដាំម្រេច។

៤. ចិនហុកកៀន

ក្រុមជនជាតិភាគតិចហុកកៀន ប្រហែលភៀសខ្លួនចេញពីខេត្តហ្វូចៀន ប្រទេសចិន។ កូនចៅចិនហុកកៀនបាននិយាយតៗគ្នាថា ចិនហុកកៀន ជាក្រុមជនជាតិចិនដំបូងបង្អស់ដែលបានមកតាំងលំនៅក្នុងទីក្រុងភ្នំពេញ។ ជនជាតិចិនហុកកៀនភាគច្រើនមានមោទនភាពដោយសារពួកគេមានការចុះសម្រុងនឹងគ្នាក្នុងការរួមរស់ក្នុងសង្គមខ្មែរជាងក្រុមជនជាតិភាគតិចចិនដទៃៗទៀត។ចិនហុកកៀនបានបញ្ជូនកូនចៅទៅសាលារៀនខ្មែរដើម្បីក្លាយខ្លួនជាខ្មែរ និងបានចូលបម្រើការងាររាជការខ្មែរដែរ។

៥. ចិនខិ ឬចិនហាក់កា

ចិនខិ មានឈ្មោះដើមថា ហាក់កា ដែលមានន័យថា ភ្ញៀវ ឬគ្រួសារចម្លែក។ គេមិនដឹងច្បាស់ថាក្រុមចិនខិចេញពីទីកន្លែងកំណើតណាឲ្យប្រាកដនោះទេនៅក្នុងប្រទេសចិន។ ប៉ុន្តែពួកគេបានតាំងទីលំនៅពាសពេញខេត្តក្វាងចូវ ហ្វូចៀន កៅហ្ស៊ូ ក្វាងហ្ស៊ី កោះហៃណាំ ស៊ីឆ័ន និងហ៊ូហាន់។ ពួកចិនខិបានកសាងកេរ្តិ៍ឈ្មោះល្បីល្បាញ ដោយសារពួកចិនខិបានក្លាយជារដ្ឋបុរស និងជាអ្នកជំនួញល្បីល្បាញជាច្រើនរូបដែលមានដូចជា លោក **តេង ស៊ាវពីង** លោក **លី ក្វាន់យូ** លោក **ស៊ុន យ៉ាត់សេន** ។

ម្យ៉ាងវិញទៀត ភាពល្បីល្បាញនៃពួកចិនខិដោយសារតែភាពស្មោះត្រង់ និងភាពអំណត់ក្នុងកិច្ចការងារ។ ពួកចិនខិបានចាត់ទុកពួកចិនដទៃៗទៀតជាអ្នកខ្ជិលច្រអូស គ្មានភាពស្មោះត្រង់ និងមានភាពខ្ជះខ្ជាយ។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ចិនខិមានតួនាទីធំៗក្នុងវិស័យសេដ្ឋកិច្ច រួមមានជាងសំណង់ អ្នកដាំម្រេច ម្ចាស់កសិដ្ឋានគ្រឿងទេស អ្នករកស៊ីហាងបញ្ចាំរបស់របរ អ្នកលក់ថ្នាំពេទ្យ អ្នកធ្វើនំ និងអ្នកកាប់ឈើ ដែលពួកគេទាំងអស់គឺបានក្លាយជាផ្នែកមួយដ៏សំខាន់ និងដ៏ល្អរបស់ប្រទេសកម្ពុជា។

នៅចុងឆ្នាំ១៩៦០ ចិន ឬកូនចៅចិននៅកម្ពុជាមានចំនួនប្រមាណ ៤២៥ ០០០នាក់។ ចំនួននេះបានធ្លាក់ចុះដោយសារសង្គ្រាម និងដោយសារការកាប់សម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ របស់ខ្មែរក្រហម រហូតដល់ឆ្នាំ១៩៨៤ ចំនួនខ្មែរកាត់ចិននៅសល់ប្រហែលតែ ៦១០០០នាក់តែប៉ុណ្ណោះ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៩៣មក ចំនួនចិនកាត់ខ្មែរកើនឡើងយ៉ាងឆាប់រហ័សមកវិញគឺកើនដល់៧០ ០០០នាក់ ភាគច្រើនមានជីវភាពល្អ សម្បូរអ្នកមានទ្រព្យធន និងមួយចំនួនមានមុខតំណែងខ្ពង់ខ្ពស់ក្នុងជួររដ្ឋាភិបាល ដែលអ្នកខ្លះមកពីសិង្ហបុរី ហុងកុង និងចិនដីគោកជាដើមល្អ។ ពលរដ្ឋខ្មែរដែលមានដើមកំណើតចិន មានពីរប្រភេទគឺៈ

(១) ចិនឆៅ គឺជាក្រុមចិនដែលបានធ្វើចំណាកស្រុកពីប្រទេសចិន មករស់នៅលើទឹកដីនៃ

ប្រទេសកម្ពុជាតាំងពីយូរយារណាស់មកហើយ។

(២) កូនចៅចិន គឺជាពលរដ្ឋជីដូនជីតា ឬម្តាយឪពុកជាខ្មែរ ឬជាចិន។ [15]

បច្ចុប្បន្ននេះ ចំនួនពលរដ្ឋខ្មែរដែលមានដើមកំណើតចិន ឬចិនកាត់ខ្មែរ និងអន្តោប្រវេសន៍ចិនដទៃៗទៀត បាននិងកំពុងកើនឡើងនៅកម្ពុជាជាបន្តបន្ទាប់ដោយសារតែកម្ពុជាបានប្រកាន់យករបបទីផ្សារសេរី និងរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលចិន។ តាមការប៉ាន់ស្មាន ត្រឹមឆ្នាំ២០១៣ ពលរដ្ឋខ្មែរដែលមានដើមកំណើតចិន និងចិនកាត់ខ្មែរ មានចំនួនប្រមាណ ១៥២ ០៥៥នាក់ ស្មើនឹង១ភាគរយនៃប្រជាជនកម្ពុជាសរុប ដែលភាគច្រើនពួកគេកំពុងរស់នៅក្នុងរាជធានីភ្នំពេញ កំពង់ធំ កំពត បាត់ដំបង កំពង់ចាម និងខេត្តមួយចំនួនទៀត។

ទោះបីជាពលរដ្ឋខ្មែរដើមកំណើតចិន ឬចិនកាត់ខ្មែរ មានចំនួនមិនច្រើនក៏ដោយ ក៏ពួកគេបានចូលរួមយ៉ាងសកម្មក្នុងវិស័យផ្សេងៗក្នុងសង្គមខ្មែរ។ជាទូទៅពួកគេមិនត្រូវបានរើសអើង ឬមើលងាយដោយពលរដ្ឋខ្មែរដែលជាម្ចាស់ស្រុកនោះទេ។ ទន្ទឹមនឹងនោះ ពួកគេក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការនាំមុខនៅក្នុងវិស័យអាជីវកម្មនៅក្នុងកម្ពុជា ក៏ដូចជានៅក្នុងឆាកនយោបាយរបស់ប្រទេសកម្ពុជាផងដែរ។ ភាគច្រើននៃពួកគេ ក៏មានឥទ្ធិពលពិសេសនៅក្នុងវិស័យធនាគាររបស់កម្ពុជា ដែលជាសហគ្រាសផ្តល់ប្រាក់កម្ចី សហគ្រាសប្តូរប្រាក់ ស្ថាប័នហិរញ្ញវត្ថុខ្នាតតូច និងសហគ្រាសដទៃៗទៀត។

## ផ្នែកទី២ ទំនាក់ទំនងក្នុងអំលុងសម័យសង្គមរាស្ត្រនិយម

### កថាខណ្ឌទី១ ដំណើរការទទួលបានឯករាជ្យជាតិ

នៅក្រោយពេលដែលបារាំងបានធ្វើជាអាណាព្យាបាលលើប្រទេសកម្ពុជា អស់រយៈពេល៩០ឆ្នាំ (១៨៦៣-១៩៥៣) បារាំងធ្វើទុក្ខបុកម្នេញខ្មែរយ៉ាងខ្លាំង រហូតធ្វើឲ្យមានការតស៊ូប្រឆាំងនឹងបារាំងយ៉ាងខ្លាំងក្លា ដូចជាចលនាជាតិនិយមជាច្រើន បានរីករាលដាលក្នុងប្រទេសកម្ពុជាដើម្បីប្រឆាំងនឹងបារាំងក្នុងការទាមទារនូវឯករាជ្យជាតិមកវិញ។ក្រុមដែលតស៊ូដើម្បីឯករាជ្យមានច្រើនដូចជា សមាជិកគណបក្សប្រជាធិបតេយ្យ ពួកខ្មែរឥស្សរៈសេរីនៅបាត់ដំបង ដែលក្រោយមកបែកសំបុក និងបែកជាច្រើនក្រុម ដែលបានអូសបន្លាយពេលជាយូរ ហើយនឹងជាច្រើនដំណាក់កាល រហូតបារាំងព្រមប្រគល់ឯករាជ្យជាតិមកកម្ពុជាវិញ ដែលអ្នកដែលបានដណ្តើមឯករាជ្យពិតប្រាកដដោយសន្តិវិធីជូនកម្ពុជាបានមុនគេគឺព្រះបាទ **នរោត្តម សីហនុ** ដែលបានធ្វើរាជ្យបូជនីយកិច្ចទាមទារឯករាជ្យក្រោយគេនៅឆ្នាំ១៩៥២ និងជោគជ័យជាស្ថាពរនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ដូច្នេះហើយទើបពួកឥស្សរៈចោរព្រៃ និងពួកតស៊ូពិតប្រាកដ បានចុះចូលរួបរួមជាមួយរាជរដ្ឋាភិបាល សម្តេច **នរោត្តម សីហនុ** និង

[15] អ្នកវិទ្យាសាស្ត្រអាមេរិកឈ្មោះផេន្នី អេដ្វឺដ្ស(Penny Edwards),<<Cambodge: The Cultivation of a Nation>>,*University of Hawaii Press,* បោះពុម្ពលើកទី១, ២០០៨

សង្គមជាតិទាំងអស់ ប៉ុន្តែលើកលែងតែក្រុមខ្មែរឥស្សរៈ វៀតមិញ និងកងទ័ពវៀតមិញរបស់វៀតណាមខាងជើង ដែលនៅធ្វើសកម្មភាពយោធា រំខានដល់រាជរដ្ឋាភិបាលកម្ពុជានៅឡើយ ជាពិសេស នៅតាមជនបទនៃប្រទេសកម្ពុជា។

**១. ចិនបានរួមចំណែកក្នុងការទាមទារឯករាជ្យឲ្យកម្ពុជា**

បើយើងក្រឡេកទៅមើលចរន្តនយោបាយកាលពីសម័យនោះ យើងឃើញថាចលនាតស៊ូខ្មែរឥស្សរៈបានធ្វើសកម្មភាពរំខាននៅក្នុងប្រទេសកម្ពុជា ដោយសារមានពួកវៀតមិញនៅពីក្រោយខ្នង។ ពួកក្រុមនេះគឺមិនចង់ឲ្យខ្មែរបរួមនោះទេ ដោយធ្វើការទាមទារឲ្យមានការបែងចែកជាពីរតំបន់នៅក្នុងប្រទេស ពោលគឺយកទន្លេមេគង្គជាព្រំដែនរួម ដូចដែរខ្មែរឥស្សរៈទាមទារចង់បាន គឺប៉ែកខាងលិចគ្រប់គ្រងដោយសម្តេច ព្រះបាទ **នរោត្តម សីហនុ** និងប៉ែកខាងកើតប្រគល់ទៅឲ្យខ្មែរឥស្សរៈ ដែលនេះជាការទាមទាររបស់ក្រុមខ្មែរឥស្សរៈ។

ដោយឃើញហេតុការណ៍នេះហើយ ទើបសាធារណរដ្ឋប្រជាមានិតចិន បានបដិសេធគាំទ្រខ្មែរឥស្សរៈនៅអង្គការសហប្រជាជាតិ ដើម្បីជាការរារាំងដល់មហិច្ឆិតារបស់នយោបាយវៀតមិញមកលើប្រទេសកម្ពុជា។ ម្យ៉ាងទៀត ចិនយល់ឃើញថាការទទួលស្គាល់តួនាទីគ្រប់គ្រងរបស់រណសិរ្សខ្មែរឥស្សរៈនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាទទួលស្គាល់តួនាទីពួកវៀតមិញនៅក្នុងប្រទេសនេះផងដែរ ដោយចិនគិតថាវាពិតជាគ្រោះថ្នាក់ណាស់សម្រាប់កម្ពុជា ព្រោះថាពួកវៀតមិញមានប្រៀបជាងទាំងលើកម្លាំងទ័ព ចំនួនប្រជាជន និងលើវិស័យនយោបាយ។

ម្យ៉ាងទៀត កាលពីពេលនោះ អ្នកដែលបានគាំទ្រវត្តមានអំណាចខ្មែរឥស្សរៈនៅក្នុងប្រព័ន្ធគ្រប់គ្រងកម្ពុជាក្រោយពេលកម្ពុជាទទួលបានឯករាជ្យ គឺមានតែសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមមួយតែប៉ុណ្ណោះ ដូចនេះហើយ បើគិតពីសំលេងនៃការគាំទ្រ គឺវៀតណាមនៅខ្សោយណាស់ដើម្បីសម្រេចឲ្យបាននូវការទាមទារឲ្យមានការបែងចែកកម្ពុជាជាពីរនេះ ជាពិសេសនៅក្នុងកម្មវិធីបង្កើតសហព័ន្ធប្រទេសកុម្មុយនីស្តឥណ្ឌូចិន ក្រោយពេលដែលបារាំងចាកចេញពីប្រទេសកម្ពុជា។ ដូច្នេះដើម្បីថែរក្សាអធិបតេយ្យភាព បូរណភាពទឹកដីដល់កម្ពុជា ចិនបានបដិសេធគាំទ្រ រណសិរ្សខ្មែរឥស្សរៈ ដោយទាមទារឲ្យប្រទេសកម្ពុជានៅតែជាប្រទេសអព្យាក្រឹត។

ជាលទ្ធផល តំណាងខ្មែរឥស្សរៈដែលត្រូវបានបញ្ជូនឲ្យទៅចូលរួមក្នុងសន្និសីទហ្សឺណែវ ត្រូវបានហាមឃាត់មិនឲ្យចូលរួម ដោយគណៈប្រតិភូនៃសន្និសីទបានសម្រេចជាឯកច្ឆន្ទទទួលស្គាល់តែតំណាងគណៈប្រតិភូរាជរដ្ឋាភិបាលដឹកនាំដោយសម្តេច ព្រះបាទ **នរោត្តម សីហនុ** តែមួយគត់។ នៅក្នុងអំឡុងសន្និសីទហ្សឺណែវ ប្រទេសចិនបានទាមទារឲ្យលោកខាងលិចទទួលស្គាល់នូវសកម្មភាពនយោបាយរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងមានការធានាដល់សន្តិសុខតាមព្រំប្រទល់ភាគ

ខាងត្បូងនៃប្រទេសចិន និងបានធ្វើការគាំទ្រដល់ការទាមទាររបស់ប្រទេសលោកខាងលិចដែលឲ្យពួកវៀតមិញដកកងទ័ពចេញពីប្រទេសកម្ពុជា និងរំសាយកងទ័ពខ្មែរឥស្សរៈជាបន្ទាន់។

តាមឯកសារប្រវត្តិសាស្ត្របានបង្ហាញថា បន្ទាប់ពីមានសន្និសីទនៅទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ សន្និសីទបានសម្រេចឲ្យមាន ការដកកងទ័ពបរទេសទាំងអស់ចេញពីទឹកដីកម្ពុជា និងបានតម្រូវឲ្យក្រុមប្រដាប់អាវុធខ្មែរនានាក្នុងទឹកដីកម្ពុជាទម្លាក់អាវុធចុះ និងចូលរួមបង្កើតបក្សនយោបាយត្រៀមប្រកួតប្រជែងក្នុងការបោះឆ្នោតសកលមួយនៅឆ្នាំ១៩៥៥។

ដើម្បីបានចូលក្នុងឆាកនយោបាយ សម្តេច នរោត្តម សីហនុ បានសម្រេចព្រះទ័យដាក់រាជ្យនៅឆ្នាំ១៩៥៥ ហើយបានផ្ទេររាជបល្ល័ង្កថ្វាយព្រះបិតារបស់ទ្រង់ គឺ **ព្រះបាទនរោត្តម សុរាម្រិត** ដើម្បីទ្រង់បានចូលធ្វើនយោបាយស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា។

**២. សម័យសង្គមរាស្ត្រនិយមត្រូវបានបង្កើតឡើង**

គណបក្សសង្គមរាស្ត្រនិយមដែលប្រជាពលរដ្ឋខ្មែរហៅរបបដឹកនាំសម័យនោះថា សម័យសង្គមរាស្ត្រនិយម ឬសម័យសង្គម ដែលត្រូវបានបង្កើតឡើងក្រោមការដឹកនាំដោយព្រះប្រមុខរដ្ឋ **នរោត្តម សីហនុ** ចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៩ នឹងត្រូវបានមតិជាតិ និងអន្តរជាតិ ទទួលស្គាល់ថាជាសម័យកាលមួយមានការរីកចម្រើនគ្រប់វិស័យក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលមិនធ្លាប់មាន។ មន្ត្រីព្រះបរមរាជវាំងបានឲ្យដឹងថា ជំនាន់សង្គមរាស្ត្រនិយមមិនត្រឹមតែបានផ្តល់សុខសន្តិភាពជូនប្រជាពលរដ្ឋទេ តែថែមទាំងកសាងសមិទ្ធផលបានជាច្រើននៅតាមរាជធានី និងតាមខេត្តនានានៅទូទាំងប្រទេសដែលមានចំនួនរាប់ពាន់សមិទ្ធផល។ ចំណែកឯលោក **ចាស្វីន ខូហ្សិល** ដែលជាអ្នកនិពន្ធបរទេសម្នាក់ក៏ធ្លាប់បាននិយាយថា "សម័យសង្គមរាស្ត្រនិយមហ្នឹង គឺជាយុគ្គសម័យមាសនៃប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប" ។

ក្នុងដំណើរការដឹកនាំ និងកសាងប្រទេសរបស់ព្រះអង្គក្នុងសម័យសង្គមរាស្ត្រនិយម ដែលកាលនោះ កម្ពុជាមានចំនួនប្រជាពលរដ្ឋខ្មែរសរុបប្រហែលជាង ៥លាននាក់ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** ដែលកាលនោះព្រះអង្គជាព្រះប្រមុខរដ្ឋ ឬប្រជាពលរដ្ឋខ្មែរទូទៅនិយមហៅព្រះអង្គថា "**សម្តេចឪ**" ព្រះអង្គបានប្រកាន់ជំហរឯករាជ្យមិនចូលបក្សសម្ព័ន្ធ ហើយអភិវឌ្ឍប្រទេសដោយអនុវត្តនូវទ្រឹស្តីមួយគឺ "ខ្លួនទីពឹងខ្លួន"។

សរុបសេចក្តីមក យើងឃើញថា ថ្វីត្បិតតែកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនពុំទាន់បានភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាជាផ្លូវការក៏ពិតមែន ប៉ុន្តែក្នុងខណៈពេលដែលរាជរដ្ឋាភិបាលចិនបានទទួលស្គាល់រាជរដ្ឋាភិបាលកម្ពុជា ជារដ្ឋាភិបាលស្របច្បាប់តែមួយគត់ ក្រោមការដឹកនាំផ្ទាល់របស់**សម្តេចព្រះបាទ នរោត្តម សីហនុ** និងគាំទ្រដល់អធិបតេយ្យភាព បូរណភាពទឹកដី និងឯករាជ្យ

ភាពរបស់កម្ពុជា នេះជាកាយវិការមួយដ៏ល្អដែលចិនបានសម្តែងឡើងក្នុងអំឡុងពេលសន្និសីទហ្សឺណែវ ហើយក៏ជាមូលដ្ឋានគ្រឹះមួយដ៏រឹងមាំសម្រាប់ការតភ្ជាប់ទំនាក់ទំនងប្រទេសទាំងពីរទៅថ្ងៃមុខ។

**កថាខណ្ឌទី២ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ**

**១. ការចាប់ផ្តើមនៃទំនាក់ទំនងការទូត**

ក្រោយពីសន្ធិសញ្ញាទីក្រុងហ្សឺណែវ សហរដ្ឋអាមេរិកបានបង្ខំឲ្យកម្ពុជាចូលជាសមាជិក The Southast Asia Treaty Organization (SEATO) ដែលជាប្លុកយោធាមួយត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមពីសហរដ្ឋអាមេរិក ដែលមានទិសដៅប្រឆាំងនឹងចលនាកុម្មុយនីស្ត នៅអាស៊ីអាគ្នេយ៍ ពោលគឺបន្ទាប់ពីកិច្ចប្រជុំលើកទី១របស់ SEATO ដែលបានប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ កាលពីខែកុម្ភៈ ឆ្នាំ១៩៥៥ រដ្ឋមន្ត្រីការបរទេសនៃសហរដ្ឋអាមេរិកលោក **ច.ហ្វ. ដាល្លេស (G.F Dalles)** បានធ្វើដំណើរមកកម្ពុជា ដើម្បីបង្ខំឲ្យកម្ពុជាចូលជាសមាជិកSEATO ដោយលោករដ្ឋមន្ត្រីការបរទេសនោះបានធ្វើសេចក្តីថ្លែងការណ៍ទៅកាន់រដ្ឋាភិបាលកម្ពុជាថា "នេះមិនមែនជាសំណើទេ តែជាលក្ខណៈឱសានវាទ"។ ចំណែកឯកម្ពុជាបានឆ្លើយតបវិញថា "កម្ពុជាមិនអាចចូលជាសមាជិកSEATO បានទេ ក្នុងនាមជាប្រទេសអព្យាក្រឹត"។ ត្បិតតែដូចនេះក្តី កម្ពុជាពិតជាមានការព្រួយបារម្ភខ្លាំងណាស់ចំពោះបញ្ហាមួយនេះ។

ប៉ុន្តែក្តីបារម្ភទាំងអស់នេះ គឺត្រូវបានរំសាយនៅពេលដែលព្រះករុណា ព្រះបាទ **សម្តេចព្រះបាទ នរោត្តម សីហនុ** និងឯកឧត្តម **ជូ អេនឡាយ** នាយករដ្ឋមន្ត្រីចិនបានជួបគ្នានៅក្នុងសន្និសីទអាស៊ី-អាហ្វ្រិកនៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី នៅក្នុងខែមេសា ឆ្នាំ១៩៥៥ ព្រះអង្គបានសព្វព្រះរាជទ័យយ៉ាងខ្លាំង ចំពោះការផ្តល់នូវកិត្តិយសរបស់មហាអំណាចចិន ដោយសារតែពិធីការដ៏ទន់ភ្លន់ និងបដិសណ្ឋារកិច្ចដ៏គួរសមគ្មានខ្ចោះរបស់ពួកគេ។ នៅពេលនោះហើយ ដែលត្រូវបានគេចាត់ទុកជាទីចាប់ផ្តើមថ្មីនៃទំនាក់ទំនងមេត្រីភាពរវាងប្រទេសចិន និងកម្ពុជា ដោយនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន បានសន្យាជាមួយព្រះអង្គអំពីឆន្ទៈរបស់ប្រទេសចិនថា ចង់កសាងទំនាក់ទំនងជាមួយនឹងកម្ពុជា ដោយឈរលើគោលការណ៍គោរពគ្នាទៅវិញទៅមក ការគោរពអធិបតេយ្យភាព បូរណភាពទឹកដី និងមិនលូកដៃចូលបញ្ហាផ្ទៃក្នុង។ ម្យ៉ាងប្រទេសចិន ក៏បានមើលឃើញការមិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា ជាកត្តាសំខាន់ដើម្បីទប់ស្កាត់ការហូរចូលនូវមនោគមន៍នយោបាយក្នុងប្រទេសដោយសារតែសហរដ្ឋអាមេរិក និងពួកសម្ព័ន្ធមិត្តរបស់គេ។

ដើម្បីថែរក្សាឯកភាពជាតិ **សម្តេចព្រះបាទ នរោត្តម សីហនុ** បានជ្រើសរើសផ្លូវអព្យាក្រឹតដែលមិនងាកទៅឆ្វេង ហើយក៏មិនងាកទៅស្តាំ គឺនៅកណ្តាលហើយចងសម្ព័ន្ធភាពជាមួយគ្រប់និន្នាការ។ នៅខណៈពេលនោះហើយ ដើម្បីគោលជំហរកិច្ចសហប្រតិបត្តិការអន្តរជាតិឲ្យកាន់តែល្អប្រសើរ នៅ

ខែកុម្ភៈ ឆ្នាំ១៩៥៦ **សម្តេចព្រះបាទ នរោត្តម សីហនុ** បានធ្វើទស្សនកិច្ចជាផ្លូវការទៅប្រទេសចិន ហើយព្រះអង្គបានធ្វើសេចក្តីប្រកាសនៅក្នុងសន្និសីទកាសែតថា ៖ "កម្ពុជាគឺអព្យាក្រឹត។ ប្រជាពលរដ្ឋបានសុំឲ្យខ្ញុំគោរពតាមកម្មវិធីនយោបាយអព្យាក្រឹត។"ក្នុងពេលជាមួយគ្នានេះដែរ គណៈប្រតិភូកម្ពុជា ក៏បានសម្តែងអំពីការតាំងចិត្តក្នុងការបង្កើតឲ្យមានកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសចិន ដែលផ្តោតចំបងសំខាន់គឺ វិស័យសេដ្ឋកិច្ច ដែលពេលនោះហើយធ្វើឲ្យកិច្ចទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិនទៅលើផ្នែកសេដ្ឋកិច្ច ត្រូវបានចាប់ផ្តើមឡើង ពោលគឺនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៦ កិច្ចព្រមព្រៀងកម្ពុជា-ចិនត្រូវបានចុះហត្ថលេខានៅលើទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរនូវទំហំទឹកប្រាក់ ១៤ លានដុល្លារសហរដ្ឋអាមេរិក បន្ទាប់មកទៀត នៅខែមិថុនា ចិនបានចុះហត្ថលេខាផ្តល់ជំនួយដល់កម្ពុជា ក្នុងទំហំទឹកប្រាក់ ២២.៤ លានដុល្លារ ដែលនេះជាលើកទី១បង្អស់សម្រាប់ប្រទេសចិន ដែលបានចុះហត្ថលេខាផ្តល់ជំនួយដល់ប្រទេសដែលមិនកាន់របបកុម្មុយនីស្ត។

កាលពីថ្ងៃទី២២ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៥៦ ឯកឧត្តមនាយករដ្ឋមន្ត្រីនៃប្រទេសចិន **ជូ អេនឡាយ** បានបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដោយបានចូលជួបសម្តែងការគួរសមជាមួយមេដឹកនាំនៃប្រទេសកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចផ្លូវការនេះហើយទើបធ្វើឲ្យនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរគឺ **សាន យុន** និង **ជូ អេនឡាយ** បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយ ដោយបានធ្វើការអះអាងសាជាថ្មីម្តងទៀត នូវការប្រកាន់ខ្ជាប់គោលនយោបាយមិនឈ្លានពាន និងគោរពគ្នាទៅវិញទៅមក។

នៅក្នុងអំឡុងទស្សនកិច្ចនេះ នាយករដ្ឋមន្ត្រីប្រមុខដឹកនាំនៃប្រទេសចិន **ជូ អេនឡាយ** បានជម្រុញឲ្យប្រទេសកម្ពុជាអនុញ្ញាតឲ្យជនជាតិភាគតិចចិនចូលក្នុងប្រទេសកម្ពុជា ដែលមានចំនួនប្រហែល ៣០០.០០០នាក់ ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការ និងជម្រុញដល់ការអភិវឌ្ឍក្នុងប្រទេសកម្ពុជា ដោយមិនស្ថិតនៅក្នុងន័យនយោបាយនោះទេ ហើយថែមទាំងបានធ្វើការស្នើសុំឲ្យសម្តេច ព្រះបាទ **នរោត្តម សីហនុ** ពិចារណាទទួលយកពលរដ្ឋភាពរបស់ជនជាតិចិនទាំងនោះផងដែរ។ ជាលទ្ធផល សាធារណរដ្ឋប្រជាមានិតចិន និង ព្រះរាជាណាចក្រកម្ពុជាបានឈានដល់ការភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរជាផ្លូវការនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨។

### ២. ការពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ

បន្ទាប់ពីការភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការរវាងប្រទេសទាំងពីររួចមក ប្រទេសទាំងពីរបានខិតខំប្រឹងប្រែងក្នុងការពង្រឹងទំនាក់ទំនងនេះឲ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។ជាក់ស្តែងនៅឆ្នាំ១៩៦០ ប្រទេសទាំងពីរបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពរវាងកម្ពុជា-ចិន ដោយសង្កត់

ធ្ងន់លើការមិនឈ្លានពានគ្នា និងជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងរបស់ប្រទេសទាំងពីរ។

បន្ថែមលើនេះទៀត ឯកឧត្តមនាយករដ្ឋមន្ត្រី **ជូ អេនឡាយ** និងឯកឧត្តមប្រធានាធិបតី **លីវ សាវឈី** នៃសាធារណរដ្ឋប្រជាមានិតចិន ជានិច្ចកាលតែងតែដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាជាច្រើនលើកច្រើនសារ ស្របពេលដែលសម្តេច **ព្រះនរោត្តម សីហនុ** ក៏ធ្លាប់បានយាងទៅបំពេញទស្សនកិច្ចនៅប្រទេសចិនសរុបចំនួន ៦លើកផងដែរ។ ម្យ៉ាងទៀត ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ក៏ធ្លាប់បានដឹកនាំការតស៊ូ ដើម្បីធ្វើការទាមទារឯករាជ្យជាតិ និងរំដោះជាតិ នៅប្រទេសចិនចំនួន២លើក ដែលជាលទ្ធផល គឺទ្រង់បានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រដ្ឋាភិបាល និង ប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិនទាំងមូលផងដែរ។

នៅក្នុងសម័យសង្គមរាស្ត្រនិយម សមិទ្ធផលនានាជាច្រើនត្រូវបានកសាងឡើង និងប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់នៅតាមបណ្តាខេត្ត-ក្រុងនានា សម្រាប់ប្រជារាស្ត្រប្រើប្រាស់ ។ បើយោងតាមឯកសារស្រាវជ្រាវនៃសមិទ្ធផលរបស់សម័យសង្គមរាស្ត្រនិយម គេបានលើកឡើងថាប្រទេសចិនក៏ជាផ្នែកមួយដ៏សំខាន់ ក្នុងការសាងនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើន រួមទាំងជំនួយផងដែរសម្រាប់ការអភិវឌ្ឍន៍នៅក្នុងសម័យកាលដ៏ឧត្តុងឧត្តមមួយនេះ។

ភាគច្រើននៃជំនួយរបស់ប្រទេសចិន មានទិសដៅពង្រឹងវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាតាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរោងចក្រជាដើម ដែលក្នុងនោះមានយើងឃើញថាមានរោងចក្រចំនួនបួនកន្លែងដែលជាជំនួយរបស់ប្រទេសចិនគឺ ៖ រោងចក្រតម្បាញ រោងចក្រក្រដាស រោងចក្រក្តារបន្ទះ និងរោងចក្រស៊ីម៉ង់ត៍។ អ្វីដែលកាន់តែពិសេសទៅទៀតនោះគឺ ប្រទេសចិនក៏បានបញ្ជូនអ្នកឯកទេសរបស់ខ្លួន ដើម្បីជួយជម្រុញឲ្យរោងចក្រទាំងនោះឲ្យមានដំណើរការល្អប្រសើរ និងធ្វើការបណ្តុះបណ្តាលអ្នកឯកទេសកម្ពុជា ដើម្បីទទួលបានជំនាញនិងអាចធ្វើការងារនៅទីនោះបានផងដែរ ក្រៅពីនេះ ចិនក៏បានជួយសាងសង់ប្រព័ន្ធធារាសាស្ត្រ សាលារៀន និងគិលានុប្បដ្ឋាននៅឯទីជនបទជាច្រើនកន្លែងទៀតផងដែរ។[16]

អ្វីដែលបានរៀបរាប់ខាងលើនេះ គឺសុទ្ធសឹងជាសមិទ្ធផលដែលសម្រេចបាននៅក្នុងសម័យសង្គមរាស្ត្រនិយម ដែលមានសមិទ្ធិផលខ្លះគឺជាការជួយជ្រោមជ្រែងក្នុងការកសាងដោយសម្ព័ន្ធមិត្តរបស់ប្រទេសកម្ពុជាកាលពីសម័យនោះ។ ដូច្នេះ បានសេចក្តីថាក្រៅអំពីការពង្រឹងលើវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច **សម្តេចព្រះបាទ នរោត្តម សីហនុ** ទ្រង់ក៏បានធ្វើការពង្រឹងលើវិស័យការទូតជាមួយបណ្តាប្រទេសដទៃៗដែលជាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធរបស់ព្រះអង្គផងដែរ។

16 សៀវភៅសមិទ្ធផលសម័យសង្គមរាស្ត្រនិយម

# ជំពូកទី២ បច្ចុប្បន្នភាពនៃទំនាក់ទំនងកម្ពុជា-ចិន

## ផ្នែកទី១ កិច្ចសហប្រតិបត្តិការកម្ពុជា-ចិន (១៩៩៣-២០១០)

បន្ទាប់ពីការអួសបន្លាញនូវសង្គ្រាមដ៏ខ្លាំងក្លាក្នុងប្រទេសរួច ប្រទេសកម្ពុជាស្ទើរក្លាយជាទីរលត់សូន្យ ព្រោះថាបញ្ញវន្តកម្ពុជារាប់លាននាក់ត្រូវបានសម្លាប់ ហេដ្ឋារចនាសម្ព័ន្ធជាច្រើនកន្លែងត្រូវបានវាយកំទេច។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំក្នុងការកសាងជាតិមាតុភូមិឡើងវិញ តាមរយៈការកសាងនូវធនធានមនុស្សជាចំនុចស្នូល និងការបើកទំព័រថ្មីនៃកិច្ចទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនឡើងវិញ ដែលយើងសង្កេតឃើញថាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធដែលមិនងាយនឹងបំបែកបាននេះបាន និងកំពុងព្យាយាមបង្កើន និងបង្កើតថ្មីនូវយុទ្ធសាស្រ្ត និងផែនការសកម្មភាពនានា ដើម្បីធ្វើយ៉ាងណាធានាឲ្យបានថាកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែមានប្រសិទ្ធិភាព និងគង់វង្សយូរអង្វែង។

### កថាខណ្ឌទី១ កិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ

ការប្រកាន់ខ្ជាប់ជានិច្ចនូវការកសាងជំនឿជឿជាក់ និងទំនុកចិត្តលើផ្នែកនយោបាយឲ្យកាន់តែស៊ីជម្រៅ ប្រទេសចិនរីករាយក្នុងការរក្សាដំណើរទស្សនកិច្ចជាន់ខ្ពស់ទៅវិញទៅមកជាមួយកម្ពុជា ដើម្បីធ្វើការពង្រឹងទំនាក់ទំនងយុទ្ធសាស្រ្តដោយសង្ឃឹមថារដ្ឋាភិបាល ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអាជ្ញាធរមូលដ្ឋានខេត្តក្រុងនៃប្រទេសទាំងពីរពង្រឹងទំនាក់ទំនងនឹងគ្នា។ ប្រទេសចិននៅតែបន្តគាំទ្រកម្ពុជា ដើរលើមាគ៌ាអភិវឌ្ឍន៍ដែលសមស្របទៅនឹងស្ថានភាពប្រទេសរបស់ខ្លួន ដោយសន្យាធ្វើការគាំទ្រកម្ពុជាដោយឥតងាករេ ក្នុងការការពារអធិបតេយ្យភាពជាតិ រក្សាស្ថិរភាពក្នុងប្រទេស និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច។ ចំណែកឯកម្ពុជាវិញ ក៏បានប្តេជ្ញាក្នុងការរក្សានូវគោលតម្លៃ និងផលប្រយោជន៍រួមតាមរយៈកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរផងដែរ។

**១. វិស័យយោធា**

ប្រទេសចិន និងប្រទេសកម្ពុជា បានខិតខំពង្រឹងនូវអំណាចយោធា តាមរយៈការផ្លាស់ប្តូរនូវបទពិសោធន៍ និងលំហាត់សម និងផ្តល់ជាជំនួយយោធាដល់ប្រទេសកម្ពុជាជារឿយៗ។ ជាក់ស្តែងនៅក្នុងថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៧ ប្រទេសចិនបានបញ្ជូនទាហានជំនាញរបស់ខ្លួនមកកាន់ប្រទេសកម្ពុជាសរុបចំនួន១០០នាក់ ដើម្បីបើកវគ្គហ្វឹកហ្វឺនដល់ទាហានកម្ពុជា លើលំហាត់ស៊ើបអង្កេត និងការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពក្នុងវិស័យយោធា ដែលវគ្គបណ្តុះបណ្តាលនេះត្រូវបានចំណាយពេលរហូតដល់២សប្តាហ៍។

ម្យ៉ាងវិញទៀត នៅក្នុងអំឡុងទស្សនកិច្ចទៅកាន់ទីក្រុងប៉េកាំង ប្រទេសចិន កាលពីខែសីហា

ឆ្នាំ១៩៩៧ របស់សម្តេច **ហ៊ុន សែន** រួមជាមួយនឹងឯកឧត្តម **អ៊ឹង ហួត** ក្នុងនាមលោកទាំងពីរជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសចិនបានផ្តល់ជាជំនួយលើវិស័យយោធានូវកប៉ាល់យោធាចំនួន១១៦គ្រឿង និងឡានទាហានចំនួន៧០គ្រឿង សរុបជាទឹកប្រាក់ប្រមាណ២.៨លានដុល្លារ។

ប្រទេសចិន ក៏បានជួយប្រទេសកម្ពុជាជាបន្តបន្ទាប់ទៀត ជាក់ស្តែងកាលពីខែធ្នូ ឆ្នាំ១៩៩៩ ក្នុងនោះប្រទេសចិនបានសាងសង់វិទ្យាស្ថានយោធាមួយមានទីតាំងនៅ តំបន់ធ្លកតាសេក ស្ថិតក្នុងខេត្តកំពង់ស្ពឺ ដែលអ្នកស្រាវជ្រាវពីឥទ្ធិពលចិនលើកម្ពុជាតែងចាត់ទុកជានិមិត្តរូបតំណាងឲ្យកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិនលើវិស័យយោធា។ វិទ្យាស្ថាននេះ ត្រូវបានសាងសង់ឡើងក្រោមជំនួយជាសម្ភារៈសំណង់ដែលមានតម្លៃ ១.៥លានដុល្លារសហរដ្ឋអាមេរិក ជាមួយនឹងការសាងសង់វិទ្យាស្ថាននេះ រដ្ឋាភិបាលចិនក៏បានផ្តល់នូវជំនួយជាសម្ភារៈយោធាមួយចំនួនទៀត ដល់កម្ពុជាដែលរួមមានៈ ឡានទាហានធំៗមួយចំនួន ឡានមេបញ្ជាការចំនួន១០ ឡានសង្គ្រោះបន្ទាន់ចំនួន១០ ឆ័ត្រយោងមួយចំនួនធំ សម្រាប់ការហ្វឹកហាត់របស់ទាហានកម្ពុជា។ ចាប់តាំងពីការសាងសង់រួចរាល់មក វិទ្យាស្ថាននេះទទួលបានជំនួយជាបន្តបន្ទាប់ពីប្រទេសចិន ដែលធ្វើឲ្យចិនក្លាយជាប្រភពជំនួយធំជាងគេបង្អស់សម្រាប់វិស័យយោធាកម្ពុជា។

បន្ថែមលើនេះទៀត ក្នុងចន្លោះខែកញ្ញា និងខែតុលា ឆ្នាំ២០០៦ ប្រទេសចិនបានធ្វើការបើកវគ្គបណ្តុះបណ្តាលដល់ទាហាន នៃកម្ពុជាទៅលើវិធីសាស្ត្រហ្វឹកហ្វឺន និងការជួសជុលនូវសម្ភារៈយោធាដល់ទាហានកម្ពុជា និងក៏បានផ្តល់ជំនួយដល់កម្ពុជានូវ នាវាចម្បាំងចំនួន៦គ្រឿងសម្រាប់ការបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការរត់ពន្ធគ្រឿងញៀន។

ម្យ៉ាងវិញទៀតក្នុងខែមេសា ឆ្នាំ២០១០ ក្នុងកម្មវិធី ការតាំងពិព័រណ៍ពិភពលោក(World Expo) ដែលបានប្រារព្ធឡើងក្នុងទីក្រុងសៀងហៃ ប្រទេសចិន សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានធ្វើការជួបសម្តែងការគួរសម ជាមួយឯកឧត្តមប្រធានាធិបតីនៃប្រទេសចិន Hu Jintao ផងដែរ។ ប្រទេសចិនក៏បានប្រកាសផ្តល់ជំនួយលើវិស័យយោធាដល់កម្ពុជាបន្ថែមទៀតដែលរួមមាន រថយន្តយោធាសរុបចំនួន២៥៧គ្រឿង សម្លៀកបំពាក់យោធាចំនួន៥០០០០កំប្លេ រួមជាមួយនឹងជំនួយជាទឹកប្រាក់ ១៥ លានដុល្លារសហរដ្ឋអាមេរិក។

តាមរយៈកិច្ចសហប្រតិបត្តិការយោធា ទៅលើការពង្រឹងការអនុវត្ត ការជួយជ្រោមជ្រែងក្នុងការបើកវគ្គបណ្តុះបណ្តាលនិងបំប៉នបន្ថែម ក៏ដូចជាការផ្តល់ឲ្យតាមរយៈជំនួយផ្សេងៗពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់ព្រះរាជាណាចក្រកម្ពុជា ពិតជាសបញ្ជាក់ឲ្យឃើញកាន់តែច្បាស់អំពីទំនាក់ទំនងរវាងប្រទេសទាំងពីរថាពិតជាគិតអំពីប្រយោជន៍រួម ដែលនេះជាស្ពានយ៉ាងសំខាន់ក្នុងការចម្លងប្រទេសទាំងពីរទៅកាន់អភិវឌ្ឍន៍ប្រកបដោយចីរភាពពិតប្រាកដ។

**២.ដំណើរទស្សនកិច្ចផ្លូវការ**

ទំនាក់ទំនងការទូតកម្ពុជា-ចិន រយៈពេលជាង ៥ទសវត្សរ៍មកនេះ មានប្រធានាធិបតីចិនចំនួន ២រូប អនុប្រធានាធិបតីចិន ចំនួន២រូប និងនាយករដ្ឋមន្ត្រីចិនចំនួន២រូបហើយ បានបំពេញទស្សនកិច្ច នៅកម្ពុជា រួមមានៈ ឯកឧត្តមប្រធានាធិបតី **ជាំង ជឺមីង** ទស្សនកិច្ចនៅកម្ពុជា នៅឆ្នាំ២០០០។ ឯកឧត្តម ប្រធានាធិបតី **ហ៊ូ ជីងតាវ** មកទស្សនកិច្ចផ្លូវការ នៅកម្ពុជា ឆ្នាំ២០១២។ ឯកឧត្តមអនុប្រធានាធិបតី **ស៊ី ជីនពីង** ទស្សនកិច្ចមកកម្ពុជាកាលពីឆ្នាំ២០០៩។ ឯកឧត្តមនាយករដ្ឋមន្ត្រីចិន **ជូ រ៉ុងជី** ទស្សនកិច្ចមក កម្ពុជាកាលពីឆ្នាំ២០០២។ ឯកឧត្តមនាយករដ្ឋមន្ត្រីចិន **វិន ជាប៉ាវ** ឆ្នាំ២០០៦។

ចំណែកឯកម្ពុជាវិញក៏ធ្លាប់បានធ្វើដំណើរទស្សនកិច្ច ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ជាច្រើនលើកច្រើនសារ ដោយរៀងរាល់ពេលតែងតែត្រលប់មកវិញនូវផ្លែផ្កា និងអត្ថប្រយោជន៍ជា ច្រើនមកដល់ប្រទេសកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចទាំងអស់នេះនឹងត្រូវបានរៀបរាប់ក្នុងខ្លឹមសារ ដូចខាងក្រោមៈ

នៅក្នុងអំឡុងខែសីហា ឆ្នាំ១៩៩៧ សម្តេច **ហ៊ុន សែន** រួមជាមួយនឹងឯកឧត្តម **អ៊ឹង ហួត** ក្នុង នាមលោកទាំងពីរ ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅធ្វើកាន់សាធារណរដ្ឋ ប្រជាមានិតចិន ក្នុងន័យសួរសុខទុក្ខព្រះបាទ **នរោត្តម សីហនុ** ព្រះវររាជបិតាជាតិខ្មែរ នៅឯទីក្រុងប៉េ កាំង។ ក្នុងអំឡុងទស្សនកិច្ចនេះ រដ្ឋាភិបាលនៃប្រទេសចិន បានផ្តល់ជាជំនួយមកកាន់កម្ពុជានូវ កប៉ាល់យោធាចំនួន១១៦គ្រឿង និងឡានទាហានចំនួន៧០គ្រឿង ដែលសរុបជាទឹកប្រាក់មានចំនួន ប្រមាណ ២.៨លានដុល្លារសហរដ្ឋអាមេរិក។

បន្ថែមពីលើនេះទៀត កាលពីឆ្នាំ១៩៩៩ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានធ្វើទស្សនកិច្ច ទៅប្រទេសចិនម្តងទៀត ហើយក៏ជាលើកដំបូងក្នុងនាមសម្តេចជានាយករដ្ឋមន្ត្រី។ នៅក្នុងអំឡុង ទស្សនកិច្ចសម្តេច **ហ៊ុន សែន** បាននាំមកវិញនូវឥណទានគ្មានការប្រាក់សរុប ចំនួន២០០លានដុល្លារ សហរដ្ឋអាមេរិក និងជំនួយឥតសំណង១៨.៣លានដុល្លារសហរដ្ឋអាមេរិក ពីប្រទេសចិនដែលទំហំ ជំនួយនេះស្ថានទូតចិនបាននិយាយថា«នេះជាជំនួយធំបំផុតដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្ររបស់ប្រទេស ចិន ដែលធ្លាប់ផ្តល់ឲ្យបណ្តាប្រទេសដទៃ។» ទស្សនកិច្ចកិច្ចនេះ ស្ថានទូតចិនហៅថា ដំណាក់កាលខ្ពស់ថ្មី មួយ ក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា-ចិន។

ប្រធានាធិបតីចិន **ជាំង ជឺមីង** ក៏បានធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាកាលពីខែវិច្ឆិ កា ឆ្នាំ២០០០។ ប្រមុខដឹកនាំប្រទេសទាំងពីរ ចាត់ទុកដំណើរទស្សនកិច្ចនោះថាជាចំណុចកំពូលមួយ ក្នុងប្រវត្តិសាស្ត្រនៃចំណងការទូតរវាងប្រទេសទាំងពីរ ដោយសារវាជាដំណើរទស្សនកិច្ចផ្លូវការដំបូង បំផុតនៃមេដឹកនាំកំពូលរបស់ចិនមកកម្ពុជា ក្នុងដំណើរទស្សនកិច្ចនោះ ប្រមុខដឹកនាំប្រទេសទាំងពីរ

បានចេញសេចក្តីប្រកាសរួមស្តីពីការពង្រីកវិសាលភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគី។ ស្របពេលដែល សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក៏បានបញ្ជាក់ជំហរជាថ្មីម្តងទៀតថា នឹងនៅតែបន្តគាំទ្រគោលនយោបាយ «ចិនតែមួយ» ។

នាយករដ្ឋមន្ត្រីចិន **ជូ រ៉ុងជី** បានធ្វើទស្សនកិច្ចមកប្រទេសកម្ពុជានៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ដែលនៅក្នុងដំណើរទស្សនកិច្ចរយៈពេលពីរថ្ងៃនេះ បាននាំមកនូវការលុបចោលបំណុល ដែលកម្ពុជាធ្លាប់ជំពាក់ចិន ប្រមាណ២០០លានដុល្លារសហរដ្ឋអាមេរិក ដែលសំដៅដល់ឥណទានមិនគិតការប្រាក់ដែលចិនឲ្យកម្ពុជាខ្ចី នៅឆ្នាំ១៩៩៩។ ឯកឧត្តម **ជូ រ៉ុងជី** បានបន្តផ្តល់ឥណទាន គ្មានការប្រាក់ និងផ្តល់ជំនួយសរុបចំនួន ១២.៥លានដុល្លារសហរដ្ឋអាមេរិក បន្ថែមទៀតដល់កម្ពុជា សម្រាប់វិស័យជាអាទិភាពមានដូចជា ការអភិវឌ្ឍធនធានមនុស្ស និង ការកសាងហេដ្ឋារចនាសម្ព័ន្ធ។

នៅក្នុងខែមេសា ឆ្នាំ២០០៦ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន **វិន ជាប៉ាវ** បានយល់ព្រម ក្នុងការផ្តល់ជំនួយដល់ប្រទេសកម្ពុជានៅទំហំទឹកប្រាក់ ៦០០លានដុល្លារសហរដ្ឋអាមេរិកដល់រាជរដ្ឋាភិបាលកម្ពុជា ដែលពាក់កណ្តាលនៃជំនួយនេះគឺសម្រាប់ការកសាងនូវតំបន់វារីអគ្គិសនី ចំណែកឯ ៣៣លានដុល្លារ សម្រាប់សាងសង់អគារទីស្តីការគណៈរដ្ឋមន្ត្រី ទុកជាកាដូអបអរសាទរខួប៥០ឆ្នាំនៃទំនាក់ទំនងការទូតកម្ពុជា-ចិន និងប៉ុន្មានទៀតសម្រាប់ការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ និងស្ពាននៅក្នុងប្រទេសកម្ពុជា។[17]

នៅក្នុងខែសីហា ឆ្នាំ២០០៨ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះករុណា ព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ** រួមទាំងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** បានយាងទៅកាន់សាធារណរដ្ឋប្រជាមានិតចិនដើម្បីចូលរួមក្នុងពិធីបើកការប្រកួតកីឡាអូឡាំពិកនៅក្នុងរដ្ឋធានីប៉េកាំង ដែលនេះក៏ជាខួបគម្រប់ ៥០ឆ្នាំនៃកិច្ចទំនាក់ទំនងការទូតកម្ពុជា-ចិនផងដែរ។

អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះគឺនៅក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ដើម្បីចុះហត្ថលេខាប្រែក្លាយកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន ទៅជាកិច្ចសហប្រតិបត្តិនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ។

### កថាខណ្ឌទី២ កិច្ចសហប្រតិបត្តិលើវិស័យសេដ្ឋកិច្ច ហិរញ្ញប្បទាន និង ឥណទានផ្សេងៗ

សាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជាបានបន្តក្នុងការពង្រីក និងពង្រឹង

[17] «China gives Cambodia 600$m in aid» *សារព័ត៌មាន BCC,* ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៦

បន្ថែមកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច តាមរយៈការចុះកិច្ចព្រមព្រៀង សន្ធិសញ្ញា ព្រមទាំងអនុស្សារណៈនៃការយោគយល់ជាច្រើន។

តួយ៉ាងក្នុងដំណើរទស្សនកិច្ចរបស់លោកជំទាវឧបនាយករដ្ឋមន្ត្រី **វូ យី** មកកាន់ប្រទេសកម្ពុជាកាលពីខែមីនា ឆ្នាំ២០០៤ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច រវាងប្រទេសទាំងពីរដែលផ្តោតសំខាន់ទៅលើវិស័យធំៗទាំងប្រាំគឺៈ វិស័យកសិកម្ម វិស័យព័ត៌មាននិងទំនាក់ទំនង វិស័យអភិវឌ្ឍន៍ធនធានមនុស្ស វិស័យវិនិយោគ និងការអភិវឌ្ឍន៍លើទន្លេមេគង្គ។ តាមរយៈកិច្ចព្រមព្រៀងនេះ បានជួយឲ្យកម្ពុជារីកចម្រើនខ្លាំងលើវិស័យកសិកម្ម តាមរយៈការលើកលែងពន្ធនាំចេញនូវផលិតផលកសិកម្មទៅកាន់ប្រទេសចិនជាង៥០មុខ។[18]

## ១. វិស័យពាណិជ្ជកម្ម និងវិនិយោគ

### ក. វិស័យពាណិជ្ជកម្ម

ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជា-ចិន មានការរីកចម្រើនលូតលាស់គួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ១៩៩០មកម្ល៉េះ។ បើទោះបីជាពាណិជ្ជកម្មកម្ពុជា-ចិនមិនសូវជាមានទំហំធំក៏ពិតមែន ក៏ប៉ុន្តែកម្ពុជាគឺជាច្រកចូលទីផ្សារដ៏ធំរបស់ប្រទេសចិន និងបានផ្តល់សក្តានុពលយ៉ាងខ្លាំងសំរាប់ការនាំចេញផលិតផលកសិកម្មរបស់ប្រទេសកម្ពុជា។ ជាក់ស្តែង កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី នៅខែកក្កដា ឆ្នាំ១៩៩៧ ជាមួយនឹងប្រទេសចិន ដែលកិច្ចព្រមព្រៀងនេះ បានបង្កើតជាមូលដ្ឋានសំខាន់សម្រាប់សកម្មភាពពាណិជ្ជកម្មទៅវិញទៅមក រហូតធ្វើឲ្យពាណិជ្ជកម្មរវាងប្រទេសទាំងពីរ មានការរីកចម្រើនឥតឈប់ឈរ។ តួយ៉ាង ចិនគឺជាដៃគូពាណិជ្ជកម្មធំជាងគេទី៧របស់កម្ពុជាក្នុងឆ្នាំ១៩៩៥ និងធំជាងគេទី៤ក្នុងឆ្នាំ២០០៣ និងបន្តកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ២៣ភាគរយអំឡុងឆ្នាំ១៩៩៥-២០០១ និង កើនដល់៦២ភាគរយ ចាប់ពីឆ្នាំ២០០២-២០០៥។

ចំណែកក្នុងអំឡុងឆ្នាំ២០០០ និង២០០៥ផលិតផលដែលកម្ពុជានាំចេញទៅចិនគឺផលិតផលកសិកម្ម និងផលិតផលធនធានធម្មជាតិ ហើយផលិតផលនាំចេញធំជាងគេគឺ ឈើ និងផលិតផលធ្វើអំពីឈើដែលមានតម្លៃប្រមាណ ១៣២លានដុល្លារសហរដ្ឋអាមេរិក ដែលច្រើនជាងពាក់កណ្តាលនៃការនាំចេញសរុប ផងដែរ ផលិតផលនាំចេញដែលសំខាន់ៗផ្សេងទៀតរួមមាន កប្បាស កៅស៊ូ បង្គាត្រី សត្វរស់ ផ្សិត ដំឡូងឈើ គ្រាប់ស្វាយច័ន្ទទី ហើយនឹងផ្លែឈើស្រស់ៗដូចជា ធុរេន ម្នាស់ មៀន និងចេកផងដែរ។

ក្នុងពេលជាមួយគ្នានេះ ផលិតផលដែលកម្ពុជានាំចូលពីប្រទេសចិនវិញនោះ គឺផលិតផលឧស្សាហកម្មជាច្រើនប្រភេទដែលមានដូចជា វាយនភណ្ឌនិងសំលៀកបំពាក់ ដែកថែប សេរ៉ាមិក

18 »កិច្ចទំនាក់ទំនងកម្ពុជា-ចិន», *កាសែត China Daily* ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤

ឧបករណ៍អគ្គិសនី និងអេឡិចត្រូនិក ម្ហូបអាហារ និងយានជំនិះជាដើម។ ការនាំចូលវាយនភណ្ឌ និងសំលៀកបំពាក់គឺជាផលិតផលដែលនាំចូលធំជាងគេបង្អស់ ដែលគិតជាទឹកប្រាក់ប្រមាណ ១២១០លានដុល្លារ ឬស្មើនឹង៦៣ភាគរយនៃការនាំចូលសរុបពីប្រទេសចិន។ កំណើនដ៏ច្រើនលើសលប់នៃការនាំចូលផលិតផលនេះ គឺបណ្តាលមកពីកំណើននៃតម្រូវការធាតុចូលសម្រាប់ផលិតកម្មសំលៀកបំពាក់ដែលកើនឡើងជាប់រហូតក្នុងប្រទេសកម្ពុជា។ ចំណែកឯផលិតផលនាំចូលធំទី២គឺ ឧបករណ៍អគ្គិសនី និងគ្រឿងម៉ាស៊ីន ដែលមានតម្លៃ១៩៤.៦២លានដុល្លារ ឬស្មើនឹង១០ភាគរយ នៃការនាំចូលសរុប ហើយផលិតផលនាំចូលសំខាន់ៗដទៃៗទៀតពីប្រទេសចិនរួមមាន សាច់ត្រី និងផលិតផលគ្រឿងសមុទ្រ ដែកនិងដែកថែប គ្រឿងធ្វើពីដែកនិងដែកថែប ផលិតផលសេរ៉ាមិក និងយានយន្ត។

**ខ.វិស័យវិនិយោគ**

ទំនាក់ទំនងលើវិស័យវិនិយោគរវាងកម្ពុជា-ចិន មានការរីកចម្រើនលូតលាស់គួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ១៩៩០មកម្ល៉េះ។ នៅមុនកិច្ចព្រមព្រៀងក្របខណ្ឌ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជម្រុញ និងការពារវិនិយោគ ជាមួយចិនក្នុងខែកក្កដា ឆ្នាំ១៩៩៦។ កិច្ចព្រមព្រៀងទាំងអស់នេះ បានបង្កើតជាមូលដ្ឋានសម្រាប់ការវិនិយោគរវាងគ្នាទៅវិញទៅមកពីបណ្តាប្រទេសទាំងពីរ។ ទំហំវិនិយោគរបស់ប្រទេសចិនមកកាន់កម្ពុជាបានកើនឡើង៣ដង គឺនៅឆ្នាំ១៩៩៧ មានត្រឹម៣៦លានដុល្លារតែប៉ុណ្ណោះ កើនដល់១១៣លាននៅឆ្នាំ១៩៩៨។ បន្ថែមពីលើនេះទៀត ប្រទេសចិនគឺជាប្រភពវិនិយោគទុនផ្ទាល់ពីបរទេសធំជាងគេក្នុងលំដាប់ទី៤របស់កម្ពុជាពីឆ្នាំ១៩៩៥-២០០៤ ដោយមានទុនវិនិយោគប្រមាណជា ៣៩៥លានដុល្លារសហរដ្ឋអាមេរិក ឬស្មើនឹង ៩ភាគរយនៃទុនវិនិយោគផ្ទាល់ពីបរទេស។

រហូតចាប់ពីឆ្នាំ២០០៦ ទំហំទុនវិនិយោគរបស់ប្រទេសចិនមកកាន់ប្រទេសកម្ពុជាគឺកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលគិតចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ទំហំទុនវិនិយោគសរុបមានចំនួនប្រមាណ ៧៧១៩លានដុល្លារសហរដ្ឋអាមេរិក ដែលធ្វើឲ្យប្រទេសចិនក្លាយជាប្រទេសដែលមកធ្វើការវិនិយោគនៅកម្ពុជា ជាមួយនឹងទំហំទឹកប្រាក់ធំជាងគេបង្អស់លំដាប់ថ្នាក់លេខ១ នេះបើប្រៀបធៀបជាមួយនិងបណ្តាប្រទេសវិនិយោគដទៃៗទៀត។ តួយ៉ាងប្រទេសកូរ៉េ គឺជាប់ចំណាត់ថ្នាក់លេខពីរជាមួយទំហំទឹកប្រាក់សរុប៤០២៧លានដុល្លារសហរដ្ឋអាមេរិក និង ម៉ាឡេស៊ីនៅលេខបី ដែលមានទឹកប្រាក់សរុបចំនួន ២៦០៩លានដុល្លារសហរដ្ឋអាមេរិក។

**២. ការផ្តល់ហិរញ្ញប្បទាន ឥណទាន និងការលុបចោលនូវឥណទាន**

**ក. ការផ្តល់ហិរញ្ញប្បទាន និងឥណទាន**

នៅក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កម្ពុជាទទួលបានមិនតិចទេនូវ

ផលប្រយោជន៍ពីប្រទេសចិន ដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ប្រទេសជាតិ។ រដ្ឋាភិបាលចិនបានផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជា ចាប់ផ្តើមតាំងពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣មកម្ល៉េះ និងបន្តមានរហូតដល់ពេលបច្ចុប្បន្ន។

ចាប់តាំងពីឆ្នាំ១៩៩៣មក ប្រទេសចិន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងការអភិវឌ្ឍប្រទេសកម្ពុជា តាមរយៈការផ្តល់នូវឥណទាន(គ្មានការប្រាក់) ហិរញ្ញប្បទាន(ឥតសំណង) ជាច្រើនដល់ប្រទេសកម្ពុជា។ ជំនួយរបស់ប្រទេសចិនមកកម្ពុជានៅមានកម្រិតនៅឡើយក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៧ ប៉ុន្តែបានចាប់ផ្តើមកើនឡើងនៅក្រោយឆ្នាំ១៩៩៧ និងបន្តកើនឡើងយ៉ាងខ្លាំងនៅពេលដែលបញ្ចប់ការបោះឆ្នោតជ្រើសរើសតំណាងតំណាងរាស្ត្រ អាណត្តិទី២ ក្នុងឆ្នាំ១៩៩៨ គឺនៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ត្រូវបានប្រជាពលរដ្ឋខ្មែរបោះឆ្នោតគាំទ្រឲ្យក្លាយជានាយករដ្ឋមន្ត្រីដើម្បីដឹកនាំប្រទេសកម្ពុជា។

ជាក់ស្តែងនៅឆ្នាំ១៩៩៤ ជំនួយរបស់ចិនជាផ្លូវការមានប្រមាណ៨.៦លានដុល្លារតែប៉ុណ្ណោះ ប៉ុន្តែនៅឆ្នាំ១៩៩៧ ជំនួយកើនបានបន្តិចដែលមានទំហំទឹកប្រាក់សរុប ៨.៨លានដុល្លារ រហូតមកដល់ឆ្នាំ១៩៩៨ ជំនួយផ្លូវការរបស់ប្រទេសចិនមានការកើនឡើងរហូតដល់ ២០០លានដុល្លារ និងកើនដល់ ៤០០លានដុល្លារនៅឆ្នាំ២០០៤ និងឆ្នាំ២០០៥ បានកើនឡើងដល់ ៦០០លានដុល្លារ។

**ខ.ការលុបចោលនូវឥណទាន**

បើគិតអំពីបំណុលសរុបដែលប្រទេសកម្ពុជាបានជំពាក់ រដ្ឋាភិបាលនៃប្រទេសចិនគិតចាប់ពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០១១ គឺមានទំហំ៨៦០លានដុល្លារសហរដ្ឋអាមេរិក។[១៩] ទោះបីជាយ៉ាងណាក្តី ប្រទេសចិនគឺតែងតែធ្វើការលុបចោលនូវប្រាក់បំណុលដែលកម្ពុជាធ្លាប់ជំពាក់ចិនជារឿយៗដែលក្នុងនោះយើងឃើញថានៅក្នុងឆ្នាំ ២០០២ ប្រទេសចិនបានលុបចោលបំណុលរបស់ប្រទេសកម្ពុជានៅក្នុងទសវត្សរ៍១៩៧០ ដែលត្រូវបានប៉ាន់ប្រមាណដោយក្រុមអ្នកការទូតថា មានតម្លៃរវាងពី៦០លានដុល្លារអាមេរិកទៅ ១០០០ លានដុល្លារអាមេរិក ដោយប្រទេសចិនចង់ធ្វើការបង្វែរបំណុលនេះទៅជាការអភិវឌ្ឍន៍ប្រទេសជាតិសម្រាប់ប្រទេសកម្ពុជាវិញ។

បន្ថែមលើនេះទៀតនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០គឺជាថ្ងៃកំណត់ដែលកម្ពុជាត្រូវសងចិនវិញនៅបំណុលដែលកម្ពុជាធ្លាប់បានខ្ចីប្រទេសចិន កាលពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែចិនមិនត្រឹមតែមិនទាមទារនោះទេ ថែមទាំងប្រកាសលុបចោលនូវបំណុលប្រមាណ៤.២លានដុល្លារសហរដ្ឋអាមេរិកនោះថែមទៀតផង ដោយបន្ថែមជំនួយឲ្យកម្ពុជានូវចំនួន១៤.៧លានដុល្លារបន្ថែមទៀត។

[១៩] របាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទ អំពីទំហំប្រាក់កម្ចីរបស់កម្ពុជា ចេញផ្សាយឆ្នាំ២០១២

## ផ្នែកទី២ កិច្ចសហប្រតិបត្តិនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ (២០១០-២០១៩)

នាពេលបច្ចុប្បន្ននេះ បើយើងក្រឡេកមើលអំពីទំនាក់ទំនងរវាងប្រទេសទាំងពីរ គឺឈានដល់កម្រិតកំពូលមួយមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ។ ជាក់ស្តែង នៅក្នុងថ្ងៃទី១៣ខែធ្នូ ឆ្នាំ២០១០ កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន បានប្រែក្លាយទៅជា កិច្ចសហប្រតិបត្តិនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ដែលការសម្រេចនេះគឺធ្វើឡើងអំឡុងជំនួបរវាង សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងលោកនាយករដ្ឋមន្ត្រីនៃប្រទេសចិន **វេន ជាប៉ាវ** ដែលនេះគឺជាកម្រិតខ្ពស់បំផុតនៃកិច្ចទំនាក់ទំនងការទូតទ្វេភាគីក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺសូម្បីតែប្រទេសជប៉ុនដែលជាម្ចាស់ជំនួយដ៏ធំ និងជាមិត្តដែលតែងគាំទ្រកម្ពុជាប្រហាក់ប្រហែលចិនដែរនោះ គឺត្រឹមស្ថិតនៅជាដៃគូយុទ្ធសាស្ត្ររបស់កម្ពុជាប៉ុណ្ណោះ។ ស្របពេលដែលប្រទេសមហាយក្សចិនក៏មានទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជាមួយកម្ពុជាតែមួយផងដែរ។

រហូតមកដល់ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ មេដឹកនាំនៃប្រទេសទាំងពីរ ក៏បានចុះហត្ថលេខាបន្ថែមទៀត លើផែនការសកម្មភាព ស្តីពីការអនុវត្តកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន នៅទីក្រុងប៉េកាំង ប្រទេសចិន ហើយឆ្នាំ២០១៣នេះ ក៏ជាខួប៥៥ឆ្នាំនៃថ្ងៃបង្កើតទំនាក់ទំនងការទូតកម្ពុជា-ចិនផងដែរ។ ដោយឈរលើចំណុចថ្មីនៃកិច្ចទំនាក់ទំនងកម្ពុជា-ចិន ប្រទេសចិនបាន និងកំពុងខិតខំប្រឹងប្រែងរួមគ្នាជាផ្លូវមួយជាមួយនឹងប្រទេសកម្ពុជា ដើម្បីជម្រុញឲ្យទំនាក់ទំនងនៃកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ របស់ប្រទេសទាំងពីរសម្រេចបាននូវការអភិវឌ្ឍ មានលក្ខណៈពេញលេញ ពហុវិស័យ និងស៊ីជម្រៅ ដើម្បីផ្តល់នូវសេចក្តីសុខចម្រើនកាន់តែប្រសើរដល់ប្រជាជននៃប្រទេសទាំងពីរ។

ជារួមសេចក្តីមក គោលជំហររបស់សាធារណរដ្ឋប្រជាមានិតចិន គឺគោរពចំពោះគោលបំណង និងឆន្ទៈរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាផងដែរ តាមរយៈការប្តេជ្ញាគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសកំពុងអភិវឌ្ឍន៍កម្ពុជា និងធ្វើការប្រកាន់ខ្ជាប់គោលការណ៍មិនជ្រៀតជ្រែកគោលនយោបាយផ្ទៃក្នុងរបស់កម្ពុជា។ ស្របពេលដែលកម្ពុជា តែងតែគោរពដល់គោលនយោបាយរបស់រដ្ឋាភិបាលចិន គឺគោលនយោបាយចិនតែមួយ។

### កថាខណ្ឌទី១ កិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រ លើវិស័យនយោបាយ យោធា ការទូត

តាមរយៈការដាក់ចេញ និងអនុវត្តន៍នូវគោលនយោបាយឈ្នះ-ឈ្នះ រយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថា មានការផ្លាស់ប្តូរយ៉ាងប្រសើរទាំងទិដ្ឋភាពនយោបាយ សន្តិសុខ ការទូត និងយោធា នេះគឺដោយសារតែការប្រកាន់ខ្ជាប់ជានិច្ចនូវការ

កសាងទំនុកចិត្តលើផ្នែកនយោបាយយោធា និងការទូត ឲ្យកាន់តែស៊ីជម្រៅជាមួយនិងប្រទេសចិន។

ជាក់ស្តែង ប្រទេសចិនបាន និងនៅតែបន្តគាំទ្រដល់ការដឹកនាំរបស់ប្រទេសកម្ពុជា ស្ទើរតែគ្រប់សម័យកាល និងពេលវេលាទាំងអស់ ដោយដើរលើមាគ៌ាអភិវឌ្ឍន៍ដែលសមស្របទៅនឹងស្ថានភាពរបស់កម្ពុជា និងសន្យាធ្វើការគាំទ្រកម្ពុជាដោយឥតងាករេ ក្នុងការការពារអធិបតេយ្យភាពជាតិ រក្សាស្ថិរភាពក្នុងប្រទេស មិនលូកដៃចូលកិច្ចការផ្ទៃក្នុង និងតែងតែការពារកម្ពុជាក្នុងនាមជាមិត្តដ៏ជិតស្និទ្ធ និងទុកចិត្តដែលមិនអាចខ្វះបានឡើយ។

ចំណែកឯ ការគោរពអធិបតេយ្យចិន គឺជាចំណុចមួយសំខាន់ណាស់សម្រាប់កម្ពុជា ក្នុងឋានៈកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលទើបតែងើបពីសង្គ្រាម គឺត្រូវធ្វើយ៉ាងណាខិតខំថែរក្សាទំនាក់ទំនងជាមួយប្រទេសមហាអំណាចចិន តាមរយៈការគោរពគោលនយោបាយអ្នកជិតខាងល្អ មិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងដូចដែលប្រទេសមហាអំណាចចិនគោរពលើកម្ពុជា និងគាំទ្រដល់គោលនយោបាយចិនតែមួយ គឺធ្វើយ៉ាងណាដើម្បីជាផលប្រយោជន៍រួមរវាងគ្នានឹងគ្នា។

**១. វិស័យនយោបាយ**

នៅក្នុងវិស័យនយោបាយ គេសង្កេតឃើញថា ព្រះរាជាណាចក្រកម្ពុជាគឺជាអ្នកគាំទ្រយ៉ាងសកម្មមួយ ក្នុងការបញ្ចូលសមាជិកភាពអចិន្ត្រៃយ៍ របស់សាធារណរដ្ឋប្រជាមានិតចិនទៅក្នុងសមាជិកអង្គការសហប្រជាជាតិ ហើយជានិច្ចកាលរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាតែងតែធ្វើការប្រកាសគាំទ្រ និងបន្តការគាំទ្រយ៉ាងមោះមុត និងពេញទំហឹងទៅនូវគោលនយោបាយចិនតែមួយ។[20]

តួយ៉ាង សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសនៅចំពោះមុខសមាគមខ្មែរ-ចិន ពីការបន្តក្នុងការគាំទ្រយ៉ាងពេញទំហឹង និងដោយឥតងាករេនូវ គោលនយោបាយចិនតែមួយ ក្នុងកម្មវិធីពិសារអាហារសាមគ្គីសមាគមខ្មែរ-ចិន កាលថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៨។[21]

ងាកទៅមើលប្រទេសចិនវិញ ក្នុងនាមជាអ្នកជិតខាងល្អ ជាសម្ព័ន្ធមិត្តចាក់ទឹកមិនលិច ឬមិត្តភាពដែកថែបកម្ពុជា-ចិន គឺរដ្ឋាភិបាលនៃប្រទេសចិនតែងតែប្រកាសគាំទ្រ និងពោលសរសើរពីការដឹកនាំ និងការរៀបចំប្រព្រឹត្តិទៅរបស់ប្រទេសកម្ពុជាទាំងលើទំនាក់ទំនងភាពជាដៃគូ និងលើឆាកអន្តរជាតិធំៗនានា។ ជាក់ស្តែង ប្រទេសចិន តែងតែគាំទ្រជានិច្ចនូវការរៀបចំការបោះឆ្នោតនៅកម្ពុជា និងបន្តជូនពរឲ្យការដឹកនាំរបស់កម្ពុជាឲ្យសម្រេចបាននូវសមិទ្ធផលកាន់តែធំធេងឡើងក្នុងកាអភិវឌ្ឍជាតិសម្រាប់បម្រើដល់ផលប្រយោជន៍ប្រជាជនរបស់ប្រទេសកម្ពុជា បើទោះបីជាមានបណ្តាប្រទេស

20 យុន ប៊ុននី, «ស្តីពីនយោបាយ-សេដ្ឋកិច្ចកម្ពុជា», *គេហទំព័រ POLITICO360* ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩

21 ប្រសាសន៍ទាំងស្រុងរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងកម្មវិធីពិសារអាហារសាមគ្គីសមាគមខ្មែរ-ចិន នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧

បស្ចិមលោកមួយចំនួន តែងប្រតិកម្មជាបន្តបន្ទាប់អំពីការបោះឆ្នោតនៅកម្ពុជាស្ទើរតែគ្រប់អាណត្តិ។[22]

បន្ថែមពីលើនេះទៀត រដ្ឋមន្ត្រីនៃក្រសួងការបរទេសចិន លោក **វ៉ាង យី** ក៏បានប្រកាសសារនយោបាយធ្វើការឆ្លើយតបទៅកាន់បណ្តាប្រទេសដែលរិះគន់ការបោះឆ្នោតនៅកម្ពុជាថា មិនមានសេរីភាព និងយុត្តិធម៌ថា "មិនគួរជ្រៀតជ្រែកក្នុងកិច្ចការងារផ្ទៃក្នុងរបស់កម្ពុជាឡើយ"។

កាន់តែពិសេសទៅទៀតនោះគឺ នៅក្នុងជំនួបទ្វេភាគីរវាងសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងឯកឧត្តម **វ៉ាន់ ហ្វនីង** ជាសមាជិកគណៈអចិន្ត្រៃយ៍នៃការិយាល័យនយោបាយ និងជាលេខាធិការនៃលេខាធិការដ្ឋានបក្សកុម្មុយនីស្តចិន កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងប៉េកាំង បានបង្ហាញជំហរយ៉ាងមុតមាំក្នុងការជួយដោះស្រាយគ្រប់បញ្ហាដែលកម្ពុជាជួបប្រទះក្នុងនោះរួមមានទាំងបញ្ហាប្រព័ន្ធអនុគ្រោះពន្ធ ដែលសហភាពអឺរ៉ុបគ្រោងនឹងព្យួរផងដែរ។[23]

**២. វិស័យយោធា**

ប្រទេសចិន តែងតែផ្តល់ការបណ្តុះបណ្តាលដល់ទាហានកម្ពុជា និងផ្តល់ជាសម្ភារៈគ្រឿងបរិក្ខារយោធា ការធ្វើសមយុទ្ធរួមគ្នា ជំនួយផ្សេងៗ និងអាហារូបករណ៍សម្រាប់យោធាកម្ពុជាផងដែរ ដើម្បីជាការបើកផ្លូវឲ្យទាហានកម្ពុជា អាចទទួលបានការបណ្តុះបណ្តាលនៅក្នុងប្រទេសចិន។ ជាក់ស្តែង ក្នុងរយៈពេលតែ៤ឆ្នាំប៉ុណ្ណោះ ពោលគឺចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ប្រទេសកម្ពុជា បានធ្វើសមយុទ្ធយោធាជាមួយប្រទេសចិនចំនួន៣លើក ដែលសមយុទ្ធនេះត្រូវបានប្រទេសទាំងពីរដាក់ឈ្មោះថាជា "សមយុទ្ធនាគមាស"។

**សមយុទ្ធនាគមាសលើកទី១**

លំហាត់សមយុទ្ធនាគមាសលើកទី១នេះ បានរៀបចំឡើងនៅខែធ្នូ ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ក្រោមប្រធានបទ "ការជួយសង្គ្រោះធម៌ និងគ្រោះមហន្តរាយ" ដើម្បីជម្រុញកិច្ចសហប្រតិបត្តិការយោធារវាងប្រទេសទាំងពីរ ដែលមានកងទ័ពកម្ពុជាសរុបចំនួន២៨០នាក់ និងកងទ័ពចិនសរុបចំនួន៨៧នាក់។

**សមយុទ្ធនាគមាសលើកទី២**

លំហាត់សមយុទ្ធនាគមាសឆ្នាំ២០១៨ រវាងកងយោធពលខេមរភូមិន្ទ និង កងទ័ពរំដោះប្រជាជនចិន បានរៀបចំធ្វើឡើងរយៈពេល១៧ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ នៅខេត្តកំពង់ស្ពឺ ក្រោមប្រធានបទ "ប្រឆាំងភេរវកម្ម និងសកម្មភាពមនុស្សធម៌" ដោយផ្តោតសំខាន់លើសកម្មភាពប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការដោះមីន ការជួយសង្គ្រោះប្រជាពលរដ្ឋពីគ្រោះមហន្តរាយ

---

22«ចិនប្រកាសគាំទ្រការបោះឆ្នោតនៅកម្ពុជា»,*វិទ្យុសម្លេងអាមេរិក* ចេញផ្សាយថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨

23 វណ្ណ សុគន្ធា, «ចិនប្រកាសជំហរជួយដល់កម្ពុជាទប់ទល់នឹងសម្ពាធពីអឺរ៉ុបរឿងEBA», *វិទ្យុបារាំងអន្តរជាតិ*, ២០១៩

នៅតំបន់ភ្នំធំម្រះព្រៅ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

លំហាត់សមយុទ្ធនេះ មានកម្លាំងចូលរួមសរុប ៥១៦នាក់៖ លំហាត់ទីបញ្ជាការ មានចំនួន៤៥នាក់ កងទ័ពចិន២០នាក់ និងកម្ពុជា២៤នាក់។ លំហាត់លើទីលាន មានចំនួន ៤២៧នាក់ កងទ័ពចិន ១៧១នាក់ និងកម្ពុជា ២៥៦នាក់។ លំហាត់សមយុទ្ធនាគមាសឆ្នាំ២០១៨នេះ គឺត្រូវបានធ្វើឡើងដើម្បីអបអរសាទរខួប៦០ឆ្នាំ នៃទំនាក់ទំនងកម្ពុជា-ចិន ដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៨។

**សមយុទ្ធនាគមាសលើកទី៣**

លំហាត់សមយុទ្ធនាគមាសលើកទី៣ រវាងកងយោធពលខេមរភូមិន្ទ និងកងទ័ពរំដោះប្រជាជនចិនដែលរួមគ្នារៀបចំ "សមយុទ្ធនាគមាស ឆ្នាំ២០១៩" រយៈពេល២៨ថ្ងៃ ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ នៅទីលានបាញ់គ្រាប់ពិតសាលាហ្វឹកហ្វឺនតេជោសែនជុំគីរី របស់កងពលតូចលេខ៧០ នៅស្រុកជុំគីរី ខេត្តកំពត។ សមយុទ្ធនេះ មានភាគីកងទ័ពរំដោះប្រជាជនចិនចូលរួមចំនួន ២៥២នាក់ និងភាគីកម្ពុជាចូលរួមចំនួន២៥៤២នាក់ក្នុងនោះមាន៖ កម្លាំងធ្វើលំហាត់ចំនួន ៣៨២នាក់ កម្លាំងបម្រើការក្នុងលំហាត់ចំនួន៤៥៨នាក់ និងកម្លាំងចូលរួមពិធីបើក-បិទចំនួន១៦៨៥នាក់។

ក្នុងលំហាត់នាគមាសនេះ មានការហ្វឹកហាត់ក្នុងទីបញ្ជាការ និងទីលាន ដោយផ្តោតសំខាន់លើវិញ្ញាសាមួយចំនួន ដូចជាការប្រឆាំងភេរវកម្ម ការរំដោះចំណាប់ខ្មាំង ការសង្គ្រោះ ប្រជាពលរដ្ឋពីគ្រោះធម្មជាតិ ការបំពេញភារកិច្ចក្រោមឆ័ត្រអង្គការសហប្រជាជាតិ និងវិស្វកម្មជាដើម។ ចំណែកឯអាវុធយុទ្ធភ័ណ្ឌសំខាន់ៗដែលប្រើប្រាស់នៅក្នុងលំហាត់នាគមាសឆ្នាំនេះ រួមមានដូចជា៖ រថពាសដែក រថក្រោះ កាំភ្លើងធំ កាំភ្លើងត្បាល់ ឧទ្ធម្ភាចក្រ និងអាវុធគាំទ្រពីលើអាកាសជាដើម។

**ជំនួយឥតសំណងលើវិស័យយោធា**

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ចិនបានបញ្ជូននាវាទ័ពជើងទឹក៣គ្រឿង ដែលមានទាហ៊ាន ជិត១០០០នាក់ បានមក ធ្វើទស្សនកិច្ចនៅសមុទ្រកម្ពុជា នៅឯខេត្តព្រះសីហនុ ដែលមានរយៈពេល៣ថ្ងៃ។

ក្នុងដំណើរទស្សនកិច្ចផ្លូវការនៅកម្ពុជា របស់ឯកឧត្តម **វ៉ៃ ហ្វឹងហឺ** ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិចិន រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ភាគីចិនក៏បានប្រកាសផ្តល់ជំនួយឥតសំណងជាទឹកប្រាក់ចំនួន ៦៩៥លានយ័ន ឬប្រហែល ១០០លានដុល្លារអាមេរិកសម្រាប់វិស័យយោធាដល់កម្ពុជា។ បន្ទាប់មករដ្ឋមន្ត្រីទាំងពីរអញ្ជើញបើកពិព័រណ៍កិច្ចសហប្រតិបត្តិការកម្ពុជា-ចិនដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍កោះពេជ្យ។

ចំណែកឯនៅក្នុងជំនួបពិភាក្សារវាងសម្តេចពិជ័យសេនា **ទៀ បាញ់** រដ្ឋមន្ត្រីក្រសួងការពារជាតិ

ជាមួយឯកឧត្តម **វ៉ៃ ហ្វឹងហឺ** សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិចិននៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៨ នៅឯប្រទេសចិន សម្ដេចពិជ័យសេនា **ទៀ បាញ់** បានស្នើសុំចិន៖[24]

(១) ផ្ដល់ជំនួយឥតសំណងចំនួនពីរគឺ អាវុធធុនធ្ងន់ និងប្រព័ន្ធការពារដែនអាកាស

(២) ជួយជួសជុលឧទ្ធម្ភាគចក្រ Z9 ចំនួន១១គ្រឿង ដែលបានទិញពីប្រទេសចិន

(៣) ផ្ដល់កាំជ្រួចផ្កា និងសម្ភារៈផ្សេងៗ ដើម្បីអបអរសាទរការសម្ពោធវិមានឈ្នះ-ឈ្នះ

តាមរយៈការស្នើសុំនេះ ប្រទេសទាំងពីរក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ជំនួយឥតសំណងផ្នែកយោធាចំនួន ៨៥៥លានយ័ន សម្រាប់រយៈពេល៥ឆ្នាំ ដើម្បីបណ្ដុះបណ្ដាលកងទ័ពកម្ពុជា ករអភិវឌ្ឍប្រព័ន្ធនាំផ្លូវ(Navigation System/GPS)ការសាងសង់សាលាហ្វឹកហ្វឺន ថ្លុកតាសេក និងការផ្ដល់នូវសម្ភារៈយោធាផ្សេងៗ។

ដោយឡែកក្នុងដំណើរទស្សនកិច្ចរបស់សម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅប្រទេសចិន កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីនៃប្រទេសចិន បានប្រកាសផ្ដល់ជំនួយឥតសំណងចំនួន៦០០លានយ័ន ឬប្រមាណ៩០លានដុល្លារសហរដ្ឋអាមេរិក ដើម្បីលើកកម្ពស់វិស័យការពារជាតិកម្ពុជាឲ្យកាន់តែប្រសើរឡើង។

**៣. វិស័យការទូត**

នៅក្នុងបរិបទរវាងប្រទេសកម្ពុជា និងប្រទេសចិន យើងសង្កេតឃើញថា ប្រទេសទាំងពីរបានខិតខំក្នុងការបង្កើននូវកិច្ចសហប្រតិបត្តិការ តាមរយៈវិស័យការទូតយ៉ាងខ្លាំង ដែលសកម្មភាពទាំងអស់នោះគឺស្ដែងអំពីការផ្លាស់ប្ដូរទស្សនកិច្ចផ្លូវការធំៗ រវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ការការពារផលប្រយោជន៍គ្នាលើឆាកអន្តរជាតិ ការកសាងនូវស្ថានទូត ស្ថានអគ្គកុលស៊ុល ក្នុងន័យគោរពអធិបតេយ្យភាព និងភាពជាម្ចាស់នៃប្រទេសដែលជាសម្ព័ន្ធមិត្តនឹងគ្នា។ ជាក់ស្ដែងប្រទេសកម្ពុជាបានបើកស្ថានអគ្គកុងស៊ុលនៅទីក្រុងរបស់ប្រទេសចិន ដែលមានចំនួនសរុប ចំនួន ០៧រួមមាន ហុងកុង-ម៉ាកាវ សៀងហៃ ឆុងឈីង ក្វាងចូវ ណាននីង គុនមិញ និងស៊ីអាន។

**៣.១ ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំកំពូលរវាងប្រទេសទាំងពីរ**

**ក.ទស្សនកិច្ចថ្នាក់ដឹកនាំកំពូលប្រទេសកម្ពុជា ទៅប្រទេសចិន**

ជាការពិតដែលមិនអាចប្រកែកបាននោះគឺ កិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនេះសុទ្ធតែផ្ដល់ប្រយោជន៍ដល់ភាគីទាំងសងខាង ជាហេតុនេះហើយទើបប្រទេសទាំងពីរបាន និងកំពុងខិតខំក្នុងការពង្រឹងនូវទំនាក់ទំនងទ្វេភាគី តាមរយៈទស្សនកិច្ចផ្លូវការធំៗ។ ជាក់ស្ដែងថ្នាក់ដឹកនាំនៃប្រទេសកម្ពុជាដែលមាន ព្រះបាទ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃប្រទេសកម្ពុ

[24] ក្រសួងការពារជាតិ, «របាយការណ៍របស់ក្រសួងការពារជាតិ», គេហទំព័រ www.mod.gov.kh, ប្រចាំឆ្នាំ២០១៨

ជា ព្រះអង្គទ្រង់បានយាងទស្សនកិច្ចទៅកាន់ប្រទេសចិនចំនួនសរុបចំនួន១២លើក (២០០៥-២០១៩) ដែលក្នុងនោះចំនួន១០លើកគឺ ព្រះអង្គទ្រង់យាងទៅពិនិត្យព្រះសុខភាពនៅទីក្រុងប៉េកាំង នៃប្រទេសចិន ចំនួន២លើកគឺជាទស្សនកិច្ចផ្លូវរដ្ឋ។

ចំណែកឯ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ធ្លាប់បានធ្វើទស្សនកិច្ចទៅកាន់ប្រទេសចិនសរុបចំនួន១១លើកពោលគឺទស្សនកិច្ចផ្លូវការចំនួន៦លើក និងទស្សនកិច្ចការងារចំនួន៥លើក ដែលគិតចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១៩។

**ខ. ទស្សនកិច្ចថ្នាក់ដឹកនាំកំពូលប្រទេសចិន មកប្រទេសកម្ពុជា**

ឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីនៃប្រទេសចិន បានធ្វើទស្សនកិច្ចផ្លូវរដ្ឋមកប្រទេសកម្ពុជាជាលើកដំបូងក្នុងនាមជាប្រធានាធិបតី កាលពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦។ នៅក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តម **ស៊ី ជីនភីង** បានចូលបង្គំគាល់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅឯព្រះបរមរាជវាំង កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។ នៅក្នុងជំនួបនេះ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** បានសព្វព្រះរាជហឫទ័យ បានរៀបចំព្រះសុវណ្ណកោដ្ឋៈសម្រាប់ឯកឧត្តមប្រធានាធិបតី ដោយមានព្រះរាជបន្ទូលថា «យើងអង្គុយជជែកគ្នាដូចជាគ្រួសារតែមួយ»។ ព្រះសុវណ្ណកោដ្ឋៈនេះ គឺជារបស់ព្រះបរមរតនកោដ្ឋនៅពេលដែលព្រះអង្គនៅមានព្រះជន្ម ពោលគឺក្រោយពេលដែលព្រះអង្គសោយទីវង្គត ព្រះរាជវង្សានុវង្សពុំដែលធ្លាប់អញ្ជើញភ្ញៀវដែលចូលមកបង្គំគាល់រូបណា អង្គុយលើព្រះសុវណ្ណកោដ្ឋៈនេះឡើយ។[25]

ចំណែកឯ ឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃប្រទេសចិន បានធ្វើទស្សនកិច្ចផ្លូវរដ្ឋមកកាន់ប្រទេសកម្ពុជា កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨។ ក្នុងជំនួបផ្លូវរដ្ឋនេះ ប្រទេសទាំងពីរបានចុះហត្ថលេខាលើឯកសារចំនួនសរុប១៩ ដែលក្នុងនោះមានកិច្ចព្រមព្រៀងចំនួន៩ អនុស្សារណៈនៃការយោគយល់ចំនួន៧ លិខិតប្តូរសារចំនួន២ និងកិច្ចសន្យាចំនួន១ ដែលភាគច្រើនគ្របដណ្តប់ទៅលើការអភិវឌ្ឍលើវិស័យចម្បងៗដូចជា វិស័យកសិកម្ម វិស័យបច្ចេកវិទ្យា វិស័យសុខាភិបាល វិស័យគមនាគមន៍ផ្លូវថ្នល់ និងឥណទាន ក៏ដូចជាហិរញ្ញប្បទានផ្សេងៗជាច្រើនទៀតផងដែរ ដែលយើងអាចសង្កេតឃើញថាបានផ្តល់នូវផលប្រយោជន៍ជាច្រើនដល់កម្ពុជាក្នុងការអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួនឲ្យស្របទៅតាមមាគ៌ានៃសន្តិភាព និងភាពរុងរឿងគង់វង្សយូរអង្វែង។

**៣.២ ការពង្រឹងកិច្ចទំនាក់ទំនងការទូតនៅក្នុងតំបន់**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនបាន

---

[25] សុង ឈឹង, «ទស្សនកិច្ចលោក ស៊ី ជីនភីង នាំយកឱកាសមាសមកកម្ពុជា», *ទស្សនាវដ្តីសេដ្ឋកិច្ចខ្មែរ*, តុលា ២០១៦ លេខទី៥៦

ជួយជ្រោមជ្រែង និងយកអាសារគ្នាក្នុងកិច្ចការពារ និងថែទាំទំនាក់ទំនងភាពជាដៃគូនៅក្នុងក្របខណ្ឌថ្នាក់តំបន់ គឺធ្វើយ៉ាងណាដើម្បីផ្តល់ជាប្រយោជន៍ដល់ការរួមចំណែករក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍរវាងប្រទេសទាំងពីរនៅក្នុងតំបន់។[26]

យើងអាចសង្កេតឃើញអំពីសមិទ្ធិផលធំៗ តាមការជួយជ្រោមជ្រែងពីកម្ពុជា ក្នុងខណៈពេលដែលកម្ពុជាគឺជាម្ចាស់ផ្ទះអាស៊ានផ្លាស់វេន កាលពីឆ្នាំ២០១២ រហូតមកដល់ពេលបច្ចុប្បន្ន គឺអាស៊ាន និងចិន សម្រេចបានក្នុងក្របខណ្ឌទំនាក់ទំនងដៃគូសន្ទនាអាស៊ាន និងចិន និងការអនុម័តឯកសារសំខាន់ៗជាច្រើនទៀតដែលរួមមាន សេចក្តីប្រកាសរួមរបស់រដ្ឋមន្ត្រីការបរទេសនៃបណ្តាប្រទេសសមាជិកអាស៊ាន និងចិនស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅក្នុងសមុទ្រចិនខាងត្បូង ការបង្កើតទូរស័ព្ទពិសេសរវាងក្រសួងការបរទេស នៃបណ្តាប្រទេសសមាជិកអាស៊ាន និងចិន និងការចេញសេចក្តីប្រកាសរួមស្តីពីការអនុវត្តក្រមសម្រាប់ការពើបប្រទះដោយមិនបានគ្រោងទុកនៅសមុទ្រ នៅតំបន់សមុទ្រចិនខាងត្បូង និងការតាក់តែងក្របខណ្ឌនៃក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូងឲ្យបានឆាប់រហ័ស។

**ក. កិច្ចសហប្រតិបត្តិការលើសមុទ្រចិនខាងត្បូង**

នៅក្នុងបរិបទបញ្ហាជម្លោះទៅនឹងសមុទ្រចិនខាងត្បូងវិញ ព្រះរាជាណាចក្រកម្ពុជាបានធ្វើការគាំទ្រទៅលើការអនុវត្តសេចក្តីថ្លែងការណ៍ ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូងឲ្យបានពេញលេញ និងកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើតឲ្យមានបរិយាកាសអំណោយផលនានា

ដល់ការឈានទៅរកការសម្រេចបាននូវក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូងមួយដ៏ចាំបាច់ និងប្រកបប្រកបដោយប្រសិទ្ធភាព ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បានគាំទ្រជំហររបស់រដ្ឋាភិបាលនៃប្រទេសចិនផងដែរថា ចំពោះជម្លោះដែនដី និងអធិបតេយ្យនៅសមុទ្រចិនខាងត្បូង ដោយឈរលើគោលការណ៍ដោះស្រាយដោយភាគីណាដែលពាក់ព័ន្ធដោយផ្ទាល់តែប៉ុណ្ណោះ និងធ្វើការអនុលោមតាមគោលការណ៍នៃច្បាប់អន្តរជាតិនានា ដែលត្រូវបានទទួលស្គាល់ជាសកលលោក ដែលរួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២ ផងដែរ[27]។

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាក្រោមការដឹកនាំរបស់ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានរក្សាជំហរលើបញ្ហាសមុទ្រចិនខាងត្បូងដែលមានខ្លឹមសារដូចខាងក្រោម៖

- ប្រកាន់ជំហរអព្យាក្រឹតដោយមិនលម្អៀងទៅភាគីណាមួយឡើយ និងផ្តល់សារៈសំខាន់

[26] សេចក្តីថ្លែងការណ៍ស្តីពីជំនួបរវាងឯកឧត្តមប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Xu Bu ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំអាស៊ាន ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧

[27] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២

ខ្លាំងដល់ការរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងសមុទ្រចិនខាងត្បូង

- គាំទ្រការអនុវត្តសេចក្តីថ្លែងការណ៍ ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូងឲ្យបានពេញលេញ មានប្រសិទ្ធភាព និងភាពល្អប្រសើរទាំងស្រុង។
- គាំទ្ររាល់ការពិគ្រោះយោបល់ និងការចរចា ស្តីពីក្រុមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង
- ចំពោះជម្លោះដែនដី និងអធិបតេយ្យភាពនៅសមុទ្រចិនខាងត្បូងត្រូវដោះស្រាយដោយភាគីពាក់ព័ន្ធផ្ទាល់ដោយសន្តិវិធី គ្មានការគំរាមកំហែង ឬការប្រើកម្លាំង អនុលោមតាមគោលការណ៍ ច្បាប់អន្តរជាតិ ដែលទទួលស្គាល់ជាសកល រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២។

ចំណែកឯ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនវិញ ក៏បានធ្វើការប្រកាសអំពីជំហររបស់ខ្លួនលើបញ្ហាសមុទ្រចិនខាងត្បូងផងដែរ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ជម្លោះក្នុងដែនសមុទ្រចិនខាងត្បូង គួរដោះស្រាយដោយប្រទេសពាក់ព័ន្ធផ្ទាល់តាមរយៈការចរចារ និងធ្វើការពិគ្រោះយោបល់ដោយសន្តិវិធី។
- ប្រទេសក្រៅតំបន់ដែលលូកដៃចូលបញ្ហាទ្វេភាគី វានឹងធ្វើឲ្យជម្លោះកាន់តែមានភាពស្មុគស្មាញ និងកាន់តែពិបាកក្នុងការដោះស្រាយ។

### ខ. កិច្ចសហប្រតិបត្តិការលើគម្រោងខ្សែក្រវ៉ាត់ និងផ្លូវ

កាលពីសម័យបុរាណ ប្រទេសចិនបានពឹងផ្អែកយ៉ាងខ្លាំងទៅលើ «ផ្លូវសូត្រ» សម្រាប់ប្រើប្រាស់ជួញដូរពាណិជ្ជកម្ម ដើម្បីទ្រទ្រង់សេដ្ឋកិច្ចរបស់ប្រទេសខ្លួន ហើយផ្លូវសូត្រនេះ ត្រូវបានគេចាត់ទុកថា ជាបណ្តាញប្រព័ន្ធផ្លូវដ៏ល្បីមួយមានអាទិភាពតាំងពី២សតវត្សមុនគ្រិស្តសករាជ ដែលតភ្ជាប់រវាងទ្វីបអាស៊ី ទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិក សម្រាប់ធ្វើចរាចរសរសៃសូត្រ សំពត់សូត្រ និងរបស់របរមានតម្លៃផ្សេងៗទៀត។ គំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ» គឺត្រូវបានស្នើឡើងវិញ ដោយឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតីនៃប្រទេសចិន ក្នុងឆ្នាំ២០១៣ ដែលសំដៅដល់គម្រោងនៃគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់សេដ្ឋកិច្ចផ្លូវសូត្របុរាណ និងផ្លូវសូត្រសមុទ្រសតវត្សរ៍ទី ២១។ កាលពីពាក់កណ្តាលខែឧសភា ឆ្នាំ ២០១៧ កន្លងទៅនេះគំនិតផ្តួចផ្តើមនេះត្រូវបានប្រកាសជាផ្លូវការ នៅទីក្រុងប៉េកាំង នៃប្រទេសចិន ដោយមានការចូលរួមពីសំណាក់ប្រមុខរដ្ឋចំនួន ២៨ប្រទេស ស្ថាប័នអន្តរជាតិ ក្រុមហ៊ុនឯកជនធំៗ និងមន្ត្រីជាន់ខ្ពស់ជាច្រើនមកពីបណ្តាប្រទេសផ្សេងៗជាច្រើនទៀត។ តាមរយៈគោលនយោបាយគំនិតផ្តួចផ្តើមខ្សែក្រវាត់និងវិថី នេះពិតជាមានវិសាលភាពធំធេងណាស់ ដោយឆ្លងកាត់ប្រទេសជាច្រើនដែលគ្របដណ្តប់ ផលិតផលជាតិសរុបនៅលើពិភពលោកចំនួន៥៥% ប្រជាជនចំនួន ៧០% និងគ្របដណ្តប់ថាមពលបំរុងចំនួន ៧៥%នៅលើពិភពលោក។

តាមរយៈការសម្លឹងឃើញនូវផលប្រយោជន៍ជាច្រើនចេញពីគំនិតផ្តួចផ្តើម ខ្សែក្រវ៉ាត់មួយ និង វិថីមួយនេះហើយ ទើបប្រទេសកម្ពុជាសម្រេចចុះហត្ថលេខាជាមួយនឹងប្រទេសចិន តាមរយៈការឲ្យសម្រេចបានចំណុចគោល នៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើតកិច្ចសហប្រតិបត្តិការទ្វេភាគីតាមរយៈកិច្ចសហប្រតិបត្តិការផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រសតវត្សទី២១ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧។[28]

ឆ្លើយតបទៅនឹងការបង្កើតឲ្យមានគម្រោងផ្លូវសូត្រ និង ផ្លូវសូត្រសមុទ្រសតវត្សទី២១នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីសម្រេចចុះថ្ងៃទី០៨ កុម្ភៈ ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងាររៀបចំបញ្ជីគម្រោងអាទិភាព នៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងផ្លូវសមុទ្រសតវត្សទី២១។[29]

សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានអញ្ជើញចូលរួម «វេទិកាខ្សែក្រវ៉ាត់ និងផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ» ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន និងបន្តក្នុងចូលរួមម្តងទៀតក្នុង «វេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទី២» ក្រោមប្រធានបទ «ការជំរុញការតភ្ជាប់ដើម្បីស្វែងរកធនធានថ្មី សម្រាប់ការរីកចម្រើន» កាលពីខែមេសា ឆ្នាំ២០១៩ នៅក្នុងទីក្រុងប៉េកាំង ប្រទេសចិន ដែលមានបណ្តាប្រទេសចូលរួមជាង១០០ប្រទេសលើសកលលោក។

### គ. កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវបានផ្តួចផ្តើមបង្កើតដោយឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងកិច្ចប្រជុំកំពូលចិន-អាស៊ានលើកទី១៧ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅប្រទេសមីយ៉ាន់ម៉ាដែលជាម្ចាស់ផ្ទះផ្លាស់វេននៃកិច្ចប្រជុំកំពូលអាស៊ាន ដែលយោងតាមគំនិតផ្តួចផ្តើមរបស់ថៃ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនៃអនុតំបន់មេគង្គ-ឡានឆាងកាលពីឆ្នាំ២០១២កន្លងទៅ។

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង មានផ្ទៃទន្លេសរុបប្រវែងប្រមាណ ៤.៨៨០គីឡូម៉ែត្រ ហូរកាត់ប្រទេសចំនួន៦ គឺ ប្រទេសចិន ប្រទេសកម្ពុជា ប្រទេសមីយ៉ាន់ម៉ា ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ដែលមានផ្ទៃស្តុកទឹកសរុបចំនួន៧៩៥.០០០គីឡូម៉ែត្រការ៉េ នឹងអាចធ្វើការផ្គត់ផ្គង់ដល់ប្រជាជនប្រមាណ ៣២៦លាននាក់ នៅក្នុងអនុតំបន់មេគង្គ-ឡានឆាង។

ម្យ៉ាងទៀត កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង បង្កើតឡើងក្នុងគោលបំណង ដើម្បីធ្វើការ

[28] អត្ថបទពីលោក សៀម ប៊ុនធី, «អ្វីទៅជាគំនិតផ្តួចផ្តើម ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ», *សារព័ត៌មាន ស៊ីអិនស៊ី*, ឆ្នាំ២០១៨

[29] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, «សេចក្តីសម្រេចបង្កើតក្រុមការងារផ្លូវសូត្រ និងផ្លូវសមុទ្រសតវត្សទី២១», ២០១៨

លើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ តាមរយៈការបង្កើតសហគមន៍មួយដែលរួមអនាគតគ្នាប្រកបដោយសន្តិភាព វិបុលភាព ថែរក្សាសន្តិភាព ស្ថិរភាព និងជំរុញការអភិវឌ្ឍក្នុងតំបន់ពន្លឿន «ក្រវ៉ាត់សេដ្ឋកិច្ច និងវិថីសូត្រ» «វិថីសូត្រសមុទ្រសតវត្សរ៍ទី២១» ដែលហៅកាត់ថា «ផ្លូវមួយ-ខ្សែក្រវាត់មួយ» និងក៏ដើម្បីធ្វើការអភិវឌ្ឍន៍អនុតំបន់ទន្លេមេគង្គ ផ្តោតជាសំខាន់ទៅលើការតាំងចិត្តក្នុងការរក្សាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងវិបុលភាពនៃអនុតំបន់ទន្លេមេគង្គ។

អ្វីដែលយើងជឿថា កិច្ចសហប្រតិបត្តិការនេះពិតជាផ្តល់ផលប្រយោជន៍ជារួម ដល់បណ្តាប្រទេសដែលជាសមាជិកទាំងអស់ ជាពិសេសគឺប្រទេសកម្ពុជាពិតមែននោះគឺ កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវបានបង្កើតឡើងដោយគោរពតាមគោលការណ៍កូសង់ស៊ីស ការបើកចំហ ការបញ្ចូលគ្នា សមភាព ការពិគ្រោះយោបល់ ការសម្របសម្រួលទៅវិញទៅមក ការស្ម័គ្រចិត្ត ការរួមចំណែកគិតផលប្រយោជន៍រួមការគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិនានា។ អ្វីដែលគួរឲ្យចាប់អារម្មណ៍មួយទៀតនោះគឺ កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង បានកំណត់នូវកិច្ចប្រជុំជាច្រើន និងបែងចែកជា៤កម្រិត ដូចខាងក្រោម៖

១ – កិច្ចប្រជុំក្រុមការងារធ្វើឡើង១ ឬ ២ដងក្នុងមួយឆ្នាំ និងទៅតាមការចាំបាច់

២ – កិច្ចប្រជុំឧត្តមមន្ត្រីធ្វើឡើង១ដង ក្នុងមួយឆ្នាំ និងទៅតាមការចាំបាច់

៣ – កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសធ្វើឡើង ១ដងក្នុងមួយឆ្នាំ ដោយឡែក

៤ – កិច្ចប្រជុំកំពូលត្រូវធ្វើឡើង២ឆ្នាំម្តង។

ចាប់តាំងពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងត្រូវបានបង្កើតមក កិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងនេះ ត្រូវបានរៀបចំធ្វើឡើងបានចំនួន ២លើករួចមកហើយ ដោយប្រទេសចិនគឺជាសហប្រធានអចិន្ត្រៃយ៍ នូវរៀងរាល់កិច្ចប្រជុំកំពូលទាំងអស់ រួមជាមួយនឹងប្រទេសដែលស្ថិតនៅតំបន់ទន្លេមេគង្គត្រូវផ្លាស់ប្តូរវេនធ្វើជាសហប្រធានទៅតាមលំដាប់តួអក្សរ ដែលនេះគឺស្របទៅតាមការសម្រេចចិត្ត និងឯកភាពរួមបស់សមាជិកទាំង៦នៅក្នុងកិច្ចសហប្រតិបត្តិការនេះ។

**គ.១ កិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១**

កិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងទី១ ត្រូវបានរៀបចំលើកដំបូងបង្អស់ក្នុងខែតុលា ឆ្នាំ២០១៦ នៅទីក្រុងសានយ៉ា នៃប្រទេសចិន ហើយចិនក៏ជាសហប្រធាន នៃកិច្ចប្រជុំកំពូលមួយនេះដែរ។ កិច្ចប្រជុំបានឆ្លុះបញ្ចាំងអំពីដំណើរការវិវត្តជាវិជ្ជមាន ទាំងវិសាលភាព និងជម្រៅនៃកិច្ចសហប្រតិបត្តិការអនុតំបន់រវាងប្រទេសទាំងប្រាំមួយ និងការប្តេជ្ញាចិត្តរួមគ្នាដ៏មោះមុតរបស់យើងលើដំណើរផ្លូវ អភិវឌ្ឍន៍ឆ្ពោះទៅរកវិបុលភាពរួម។ ទន្ទឹមនេះ កិច្ចប្រជុំកំពូលពេលនេះជាវេទិកាដ៏មានតម្លៃបំផុតសម្រាប់ការចូលរួមចំណែកក្នុងការកសាងមហាអនុតំបន់មួយឲ្យបានរឹងមាំ និងសម្រេចបាននូវ

គោលដៅ ការកសាងសហគមន៍អនុតំបន់ទន្លេមេគង្គមួយ ដែលបម្រើផលប្រយោជន៍រួមនិងឲ្យកាន់តែជិតស្និទ្ធជាងមុន តាមរយៈយន្តការដែលមានស្រាប់នានា រួមមាន៖ ភាពជាដៃគូអាស៊ាន-ចិន កម្មវិធីមហាអនុតំបន់មេគង្គ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាស៊ាន-អាងទន្លេមេគង្គ។

**គ.២ កិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២**

កិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងទី២ ត្រូវបានរៀបចំឡើងនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នៅប្រទេសកម្ពុជា ដែលប្រទេសចិន និងប្រទេសកម្ពុជា គឺជាសហប្រធាននៃកិច្ចប្រជុំនេះ នៅក្រោមប្រធានបទ "ទន្លេរបស់យើងៈ ដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកដដោយចីរភាព" សន្តិភាពប្រកបដោយនិរន្តភាព និងការអភិវឌ្ឍប្រកបដោយចីរភាពយូរអង្វែង ត្រូវតែអត្ថិភាព និងដំណើរទៅមុខជាមួយគ្នាដែលចំនុចទាំងពីរនេះគឺមិនអាចមើលរំលងបានទេ។កិច្ចប្រជុំកំពូលនេះ បានប្រព្រឹត្តទៅដោយជោគជ័យជាទីបំផុត ដោយសមាជិកទាំង៦នៃកិច្ចសហប្រតិបត្តិការបានយល់ព្រមអនុម័តឯកសារសមិទ្ធផលសំខាន់ៗចំនួនពីរគឺ៖

(១) សេចក្តីថ្លែងការណ៍ក្រុងភ្នំពេញនៃកិច្ចប្រជុំកំពូលសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២

(២) ផែនការសកម្មភាព ៥ឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២២)

**៣.៣ ការពង្រឹងកិច្ចទំនាក់ទំនងក្នុងក្របខណ្ឌសកល**

បើយោងតាមឯកឧត្តម **វ៉ាំង វិនធៀន (Wang Wen Tian)** ឯកអគ្គរដ្ឋទូតរបស់សាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជាបានបញ្ជាក់ថា រដ្ឋាភិបាលចិនតែងតែគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ជាពិសេសបន្តជ្រោមជ្រែងកម្ពុជា ដើម្បីឱ្យមានតួនាទីសំខាន់នៅលើឆាកអន្តរជាតិ។

តួយ៉ាង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានធ្វើការគាំទ្របេក្ខភាពកម្ពុជា តាមរយៈការបោះឆ្នោតគាំទ្រជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់ឆ្នាំ២០១៩ ដោយធ្វើការបោះឆ្នោតគាំទ្រកាលពីឆ្នាំ២០១៨ នៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក និងបានគាំទ្របេក្ខភាពកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប លើកទី១៣ នៅឆ្នាំ២០២០ ដែលការបោះឆ្នោតគាំទ្របានប្រព្រឹត្តនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្សិក។ ចំណែកឯកម្ពុជាវិញ ក៏បានធ្វើការគាំទ្របេក្ខភាពលោក **យូ លាង (You Liang)** សម្រាប់ការបោះឆ្នោតឡើងវិញ ជាសមាជិកនៃ Committee on the Rights of the Persons with Disabilities អាណត្តិ ២០១៩-២០២២ ដែលការបោះឆ្នោតគាំទ្រនេះបានធ្វើឡើងកាលពីខែមិថុនា ឆ្នាំ២០១៨ ក្នុងទីក្រុងញ៉ូវយ៉ក នៃសហរដ្ឋអាមេរិក។

តាមរយៈកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រលើវិស័យនយោបាយ យោធា និង

ការទូតរវាងប្រទេសកម្ពុជា និងប្រទេសចិន ពិតជាផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងមកដល់កម្ពុជា ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ និងរីកលូតលាស់យ៉ាងឆាប់រហ័ស ព្រោះថាគោលនយោបាយរបស់ប្រទេសចិនគឺសមមស្របទៅនឹងដំណើរវិវត្តន៍នៃគោលនយោបាយការបរទេសរបស់ប្រទេសកម្ពុជា គឺឈរលើមូលដ្ឋានអព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធ មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃ និងបម្រើដល់គោលដៅរួមគឺគោរពផលប្រយោជន៍គ្នាទៅវិញទៅមក៕

## កថាខណ្ឌទី២ កិច្ចសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្រ លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងសង្គមកិច្ច

ប្រទេសកម្ពុជា បាននឹងកំពុងធ្វើឲ្យបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំៗជាច្រើន នៅក្នុងសកលលោក ចាប់ចិត្ត និងចាប់អារម្មណ៍យ៉ាងខ្លាំងមកលើកម្ពុជា ហើយតែងតែចង់ចាប់ដៃសហការជាមួយកម្ពុជាតាមរយៈការវិនិយោគ ការធ្វើពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតដែលក្នុងនោះយើងសង្កេតឃើញថា សាធារណរដ្ឋប្រជាមានិតចិនបាន និងកំពុងតែនាំមុខគេលើបណ្តាប្រទេសដទៃៗដែលមានទំហំសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយកម្ពុជា។

ការជម្រុញកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក ឲ្យកាន់តែរឹងមាំនិងស៊ីជម្រៅនោះគឺ ប្រទេសចិនរីករាយក្នុងការពង្រឹងការតភ្ជាប់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាមួយកម្ពុជា បង្កើតចំណុចចាប់អារម្មណ៍នៃកិច្ចសហប្រតិបត្តិការ "ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ" ធ្វើឲ្យកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅទៅនឹងស្ថានភាពនៃប្រទេសនីមួយៗ។ ការជម្រុញកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគធំៗទៅលើវិស័យវារីអគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ ស្ពានថ្នល់ ប្រព័ន្ធធារាសាស្ត្រកសិកម្ម វិស័យព័ត៌មានក៏ដូចជាទូរគមនាគមន៍ជាដើម ពិតជាទទួលបាននូវលទ្ធផលជាក់ស្តែងដែលមិនអាចប្រកែកបាន។

តាមន័យនេះ យើងសង្កេតឃើញថាសម្ព័ន្ធមិត្តដ៏ជិតស្និទ្ធដែលមិនងាយនឹងបំបែកបាននេះបាន និងកំពុងព្យាយាមបង្កើន និងបង្កើតថ្មីនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីធ្វើយ៉ាងណាធានាឲ្យបានថាកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែមានប្រសិទ្ធិភាព និងគង់វង្ស។

### ១. វិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម

នាពេលបច្ចុប្បន្ននេះស្ទើរតែគ្រប់ប្រទេសទៅហើយនៅលើសកលលោក ដែលបានទទួលស្គាល់ថាពាណិជ្ជកម្មសេរីពិតជាជួយចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស។

ដោយហេតុនេះហើយ ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងបន្តទៅមុខទៀតយ៉ាងស្វាហាប់ នៅលើមាគ៌ានៃការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម សំដៅធានាឲ្យទំនិញ

និងសេវាគ្រប់ប្រភេទអាចចរាចរណ៍បានដោយសេរីនៅក្នុងទូទាំងប្រទេស។ ឆ្លងតាមបទពិសោធន៍ជាក់ស្តែងរបស់ប្រទេសកម្ពុជាទៅលើវិស័យពាណិជ្ជកម្ម ដើម្បីប្រែក្លាយវិស័យពាណិជ្ជកម្មមួយនេះ ឲ្យក្លាយទៅជាកម្លាំងចលករដ៏សំខាន់ ក្នុងការការកាត់បន្ថយភាពក្រីក្រ និងការលូតលាស់សេដ្ឋកិច្ចជាតិ ឲ្យកាន់តែរីកចម្រើនថែមទៀត។

យោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន គឺជាប្រទេសដែលមានទំហំពាណិជ្ជកម្មធំជាងគេបង្អស់របស់កម្ពុជា គឺក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ទំហំពាណិជ្ជកម្មទ្វេភាគីសរុបរវាងចិន និងកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័សដែលជាមធ្យមគឺ ២៦ភាគរយ។ តួយ៉ាង ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរគឺមានត្រឹមតែ ២៤០០ លានដុល្លារសហរដ្ឋអាមេរិកតែប៉ុណ្ណោះនៅឆ្នាំ២០០៦។ ប៉ុន្តែនៅឆ្នាំ២០១៦ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជានិងប្រទេសចិន បានកើនឡើងដល់ ៤៧៣០លានដុល្លារសហរដ្ឋអាមេរិកដែលក្នុងនោះកម្ពុជានាំចេញ ៨៣០លានដុល្លារ និងនាំចូល៣៩០០លានដុល្លារ។

ទំហំពាណិជ្ជកម្មរបស់ប្រទេសទាំងពីរនៅតែបន្តកើនឡើងរហូតដល់ ៥៨០០លានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៧ ក្នុងនោះកម្ពុជានាំចេញ ១០០០លានដុល្លារសហរដ្ឋអាមេរិក និងនាំចូលពីប្រទេសចិន ៤៧០០លានដុល្លារ ដែលទំហំនេះគឺលើសពីការរំពឹងទុក ដែលបានកំណត់ដោយថ្នាក់ដឹកនាំកំពូលរវាងប្រទេសទាំងពីរកាលពីពេលកន្លងទៅ។ ម្យ៉ាងទៀត ប្រទេសនៃមហាមិត្តទាំងពីរបានធ្វើការប្តេជ្ញាបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីឱ្យដល់ ៦០០០លានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០២០ និងតាំងចិត្តឲ្យសម្រេចបាននូវទំហំទឹកប្រាក់ ១០.០០០ លានដុល្លារសហរដ្ឋអាមេរិកនៅត្រឹមឆ្នាំ២០២៣ខាងមុខនេះ។[30]

អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះគឺ ភាគីសម្ព័ន្ធទាំងពីរបានរំលេចអំពីវឌ្ឍនភាពដ៏សំខាន់ៗនៃវិស័យពាណិជ្ជកម្មទ្វេភាគី លើការងារបញ្ហាអនាម័យ និងភូតគាមអនាម័យ ដែលស្ថិតនៅជារបាំងបច្ចេកទេសរាំងស្ទះការធ្វើពិពិធកម្មនាំចេញនៃកសិផលរបស់កម្ពុជា ទៅកាន់ទីផ្សាររបស់ប្រទេសចិនរួមមាន ផ្លែឈើ និងផលដំណាំផ្សេងៗ។ ចំណែកឯភាគីចិនវិញក៏បានពិចារណាក្នុងការបង្កើនការទិញផលិតផលបន្ថែមពីកម្ពុជា រួមទាំងការទិញអង្ករផងដែរ សម្រាប់ឆ្នាំ២០១៩នេះដើម្បីកាត់បន្ថយអតុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម។

ដើម្បីសម្រេចបាននូវទំហំពាណិជ្ជកម្មខាងលើ ក្រសួងពាណិជ្ជកម្មកម្ពុជាមានយុទ្ធសាស្ត្រជំរុញ និងសម្របសម្រួលការធ្វើពាណិជ្ជកម្ម រវាងសម្ព័ន្ធមិត្តនៃប្រទេសទាំងពីរគឺកម្ពុជា-ចិន ដូចជាៈ

30«ពី១០ឆ្នាំទំហំពាណិជ្ជកម្មទ្វេភាគីសរុបរវាងចិន និងកម្ពុជា», *ដំណឹងពលរដ្ឋ*, ចេញផ្សាយថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨

- រៀបចំផែនការមេ និង ជំនួបរវាងក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើផ្នែកពាណិជ្ជកម្មនិងវិនិយោគ។
- បង្កើតក្រុមការងារ ដើម្បីធ្វើការដោះស្រាយរាល់បញ្ហានានាដែលពាណិជ្ជករ និងវិនិយោគិនប្រទេសទាំងពីរជួបប្រទះ។
- សម្របសម្រួលឲ្យមានជើងហោះហើរផ្ទាល់ពីទីក្រុងធំៗនៃប្រទេសចិនដើម្បីទាក់ទាញកំណើនភ្ញៀវទេសចរ និងវិនិយោគិន ព្រមទាំងការផ្លាស់ប្តូរពាណិជ្ជកម្ម។
- បង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម និងព័ត៌មាននៅតាមបណ្តាខេត្តផ្សេងៗនៃប្រទេសចិនថែមទៀត ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មឲ្យកាន់តែទូលំទូលាយ ។
- បើកច្រកទីផ្សារនៅប្រទេសចិន និងប្រទេសដទៃទៀត ដែលកម្ពុជាទទួលបានប្រព័ន្ធអនុគ្រោះពន្ធគយសូន្យ និងមិនជាប់កូតា ដើម្បីជំរុញឲ្យការវិនិយោគនៅកម្ពុជាទទួលបានប្រាក់ចំណេញ និងជោគជ័យ ។
- រៀបចំវេទិកាជំរុញពាណិជ្ជកម្មឲ្យបានច្រើនថែមទៀតនៅតាមខេត្ត និងតំបន់នានាក្នុងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន។[31]

ជាការឆ្លើយទៅនឹង ការពង្រឹងពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ ឲ្យកាន់តែមានសន្ទុះកើនឡើងនិងលក្ខណៈកាន់តែល្អប្រសើរនោះ ក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរបានឯកភាពគ្នាបង្កើតទំព័រប្រវត្តិសាស្ត្រថ្មីមួយ ក្នុងយុគសម័យបច្ចេកវិទ្យានេះ ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(E-commerce)។

**ក. វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម**

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានអំណោយផលជាងគេ នៅជ្រោយឥណ្ឌូចិនលើវិស័យកសិកម្មដែលគ្របដណ្តប់ជាង៥០ភាគរយនៃផលិតផលសរុប។ ផលិតផលកសិកម្មនៅក្នុងប្រទេសកម្ពុជាត្រូវបានគេរាប់បញ្ចូលរួមមានដំណាំរួមផ្សំ ៦៣ភាគរយ ការចិញ្ចឹមសត្វ ២៤ភាគរយ ការនេសាទ ១០ភាគរយ និងព្រៃឈើ ៣ភាគរយ។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងជម្រុញការអនុវត្ត "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨" ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ ធានាសន្តិភាពរុងរឿង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជ

[31] «ផែនការយុទ្ធសាស្ត្រសកម្មភាពប្រចាំឆ្នាំ២០១៧» ,*ក្រសួងពាណិជ្ជកម្ម*, ឆ្នាំ២០១៦

បនីយកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកដដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

បើយោងតាមរបាយការណ៍ប្រចាំខែរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងអំឡុងខែមេសា ឆ្នាំ២០១៩នេះ ការនាំចេញអង្ករតាមច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៥២.៩៥២តោន ដែលមានការកើនឡើងចំនួន ៦.៧០៣តោន ឬស្មើនឹង១៨.៥ភាគរយ បើធៀបទៅនឹងបរិមាណនៃការនាំចេញក្នុងខែមេសា កាលពីឆ្នាំ២០១៨។ សរុបរយៈពេល៤ខែ(មករា-មេសា) ក្នុងឆ្នាំ ២០១៩ កម្ពុជាបានធ្វើការនាំចេញអង្ករបានសរុបចំនួន ២១៣.៧៦៣តោន ទៅកាន់៤៤ប្រទេសផ្សេងៗគ្នាក្នុងសកលលោក ដែលប្រទេសចិនឈរក្នុងចំណាត់ថ្នាក់លេខ១ដែលមានចំនួន៩៥.០៦៦តោន ឬស្មើនឹងជិត៤៥ភាគរយ។[32] ផងដែរ ចិនក៏បានយល់ព្រមនាំចេញអង្ករចំនួន ៣០ម៉ឺនតោន ពីកម្ពុជានៅឆ្នាំ២០១៨ ដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ និងបានឯកភាពឲ្យសហគ្រាសកម្ពុជាចំនួន ២៦ មានសិទ្ធិនាំចេញអង្ករទៅប្រទេសចិន ក្រៅពីការនាំចេញផលិតផលស្រូវ កម្ពុជាក៏នាំចេញទៅប្រទេសចិននូវផលិតផលដទៃៗទៀតដែលមានដូចជា កៅស៊ូ ដំឡូងមី ស្ករស ម្រេច និងគ្រាប់ស្វាយចន្ទីជាដើម។

ម្យ៉ាងទៀត ក្រសួងកសិកម្មនៃប្រទេសទាំងពីរ បានចុះហត្ថលេខាអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍កសិកម្មទំនើបនៅកម្ពុជា ដែលបានចូលជាធរមានកាលពីខែមករា ឆ្នាំ២០១៨កន្លងទៅនេះ។[33]បច្ចុប្បន្ននេះ ប្រទេសទាំងពីរបាន និងកំពុងរៀបចំផែនការមេអភិវឌ្ឍន៍ និងការធ្វើទំនើបកម្ម វិស័យកសិកម្ម នៅកម្ពុជាសម្រាប់រយៈពេលវែងគិតចាប់ពីឆ្នាំ ២០១៩-២០៣០ ដែលស្ថិតក្រោមការជួយជ្រោមជ្រែងទាំងស្រុងពីរដ្ឋាភិបាលចិនដែលរាប់បញ្ចូលទាំងធនធាន ហិរញ្ញវត្ថុ និងបច្ចេកទេស។

បន្ថែមទៀតនោះ ក៏មានគម្រោងជាច្រើនទៀតដូចជា គម្រោងវិនិយោគបង្កើតកសិដ្ឋានដំណាំកសិ-ឧស្សាហកម្ម(អំពៅ) និងរោងចក្រស្ករសចំនួន២ក្រុមហ៊ុន លើផ្ទៃដីសរុបទំហំ ១៧.៨០០ហិកតានៅខេត្តព្រះវិហារ របស់ក្រុមហ៊ុន Rul Feng (Cambodia) International Company Limited និងក្រុមហ៊ុន Heng Yu (Cambodia) International Company Limited ក្នុងគម្រោងទុនវិនិយោគសរុបចំនួន ២២៣លានដុល្លារអាមេរិក។

---

32 «របាយការណ៍ប្រចាំខែមេសា», *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*, ចេញផ្សាយឆ្នាំ ២០១៩

33 «ផែនការមេអភិវឌ្ឍន៍ និងការធ្វើទំនើបកម្មវិស័យកសិកម្មនៅកម្ពុជារយៈពេលវែង ២០១៩-២០៣០», *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*, ២០១៨

មិនត្រឹមតែផ្នែកពាណិជ្ជកម្ម និងសហប្រតិបត្តិការនោះទេ ប៉ុន្តែប្រទេសចិនក៏បានជួយទៅលើកសិកម្មនៅក្នុងប្រទេសកម្ពុជាតាមរយៈការអប់រំ និងបណ្តុះបណ្តាលប្រជាកសិករខ្មែរផងដែរ។ ជាការពិតណាស់ អង្គការ Chinese Academy of Tropical Agricultural Science (CATAS) នៃប្រទេសចិនគឺជាវិទ្យាស្ថានស្រាវជ្រាវតំបន់ត្រូពិកនៃប្រទេសចិន ឈរលើលំដាប់ថ្នាក់ធំជាងគេនៅចិន ដែលទទួលការសិក្សាស្រាវជ្រាវលើវិស័យកសិកម្ម និងជំនាញបច្ចេកទេសផ្សេងៗដែលទាក់ទងនឹងផ្នែកកសិកម្ម បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨កន្លងទៅ ក្រោមកិច្ចសហប្រតិបត្តិការរយៈពេល ៥ឆ្នាំ ដោយផ្តោតលើការបណ្តុះបណ្តាលវិស័យកសិកម្មនៅកម្ពុជា។

**ខ. វិស័យទេសចរណ៍**

បច្ចុប្បន្ននេះ វិស័យទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា បាននិងកំពុង ទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលក្នុងនោះយើងសង្កេតឃើញថាភ្ញៀវទេសចរណ៍ដែលមកពីប្រទេសចិន បាននឹងកំពុងនាំមុខគេនៅប៉ុន្មានឆ្នាំចុងក្រោយនេះពោលគឺស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១ ដែលមានភ្ញៀវទេសចរណ៍មកទស្សនាក្នុងប្រទេសកម្ពុជាច្រើនជាងគេបង្អស់ក្នុងឆ្នាំ២០១៧ ២០១៨ និងពាក់កណ្តាលឆ្នាំ២០១៩នេះ ដែលកាលពីប៉ុន្មានឆ្នាំមុនគឺបានត្រឹមស្ថិតនៅចំណាត់ថ្នាក់លេខ ២ និងលេខ៣តែប៉ុណ្ណោះ។

ផងដែររាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន បានកំណត់យកឆ្នាំ២០១៩ ជាពេលពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរួមគ្នាលើវិស័យទេសចរណ៍ និងវប្បធម៌ ឬហៅថា «ឆ្នាំវប្បធម៌ និងទេសចរណ៍កម្ពុជា-ចិន កាលពីរាត្រីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅ។

វិស័យទេសចរណ៍ គឺជាវិស័យអាទិភាពមួយ នៃផែនការសកម្មភាពក្នុងគោលដៅជំរុញដល់វិនិយោគ និងលំហូរទេសចរនៃប្រទេសទាំងពីរ ដោយយកឆ្នាំវប្បធម៌ និងទេសចរណ៍កម្ពុជា-ចិន ២០១៩ ដើម្បីពង្រឹង និងពង្រីកកិច្ចកិច្ចសហប្រតិបត្តិការរួមគ្នាលើផ្នែកទេសចរណ៍ និងវប្បធម៌រវាងប្រទេសទាំងពីរបន្ថែមទៀត មានដូចជាការជំរុញការផ្សព្វផ្សាយទេសចរណ៍រួមគ្នា ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ការបណ្តុះបណ្តាលធនធានមនុស្ស ការសម្តែងសិល្បៈរួមគ្នាជាដើម។[34] ម្យ៉ាងវិញរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏មានជំនឿចិត្តផងដែរថា «ឆ្នាំវប្បធម៌ និងទេសចរណ៍កម្ពុជា-ចិន» នឹងក្លាយជាចលករក្នុងការជំរុញថែមទៀតនៃទំនាក់ទំនងរវាងប្រជាជនកម្ពុជា និងប្រជាជនចិន ក្នុងការផ្លាស់ប្តូរវប្បធម៌រវាងគ្នា ក៏ដូចជាការជម្រុញឲ្យមានលំហូរភ្ញៀវទេសចរទៅវិញទៅមក។

[34] លោក ស៊ិន ចាន់សេរីវុត្ថា អ្នកនាំពាក្យនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, «ការប្រកួតប្រជែងក្នុងវិស័យអាកាសចរកំពុងកើនឡើងនៅកម្ពុជា», *គេហទំព័រព័ត៌មានសង្គម*, ឆ្នាំ២០១៨

**គ. វិស័យអាកាសចរណ៍**

វិស័យអាកាសចរណ៍ជាឧស្សាហកម្ម ដែលកំពុងរីកលូតលាស់យ៉ាងខ្លាំងនៅលើពិភពលោក និងតំបន់ដែលត្រូវបានគេចាត់ទុកថាជាយុទ្ធសាស្ត្រ នៃផលិតកម្មនិងជាស្នូលនៃដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និង ការកាត់បន្ថយភាពក្រីក្រដោយសារតែតួនាទីទ្វេគុណរបស់ខ្លួន។ នៅក្នុងប្រទេសកម្ពុជាយើងវិញ ដោយសារតែកំណើនភ្ញៀវទេសចរណ៍មានការកើនឡើងយ៉ាងឆាប់រហ័សគួរឲ្យកត់សម្គាល់ ជាពិសេសគឺភ្ញៀវទេសចរណ៍ចិន ជាហេតុធ្វើឲ្យកំណើនក្រុមហ៊ុនអាកាសចរជាច្រើនទាំងក្នុងស្រុក និងក្រៅស្រុក។ បើយោងតាមការបកស្រាយរបស់លោក **ស៊ិន ចាន់សេរីវុត្ថា** អគ្គនាយករងបច្ចេកទេស និងជាអ្នកនាំពាក្យនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល លោកបាននិយាយថាភ្ញៀវទេសចរណ៍ដែលមកទស្សនាក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០១៧ដែលមានចំនួន ៥.៦០២.១៥៧នាក់ ដែលក្នុងនោះប្រមាណ៦០ភាគរយបានប្រើប្រាស់មធ្យោបាយតាមផ្លូវអាកាស ជាហេតុធ្វើឲ្យអាកាសយានដ្ឋានអន្តរជាតិទាំង ៣ នៅភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ បានទទួលអ្នកដំណើរចំនួន ៨.៨ លាននាក់ស្មើនឹង ៩០០០០ជើង ដោយកើនឡើង ២៥ ភាគរយបើធៀបទៅនឹងឆ្នាំ ២០១៦។

បើគិតត្រឹមឆ្នាំ២០១៨ មានក្រុមហ៊ុនអាកាសចរណ៍សរុបចំនួន៦០ក្រុមហ៊ុន ដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ខណៈក្រុមហ៊ុនអាកាសចរណ៍យ៉ាងហោចណាស់៦ផ្សេងទៀតកំពុងរង់ចាំវិញ្ញាបនបត្រ AOC ដែលអាចអនុញ្ញាតឲ្យពួកគេធ្វើការហោះហើរនៅក្នុងដែនអាកាសរបស់ព្រះរាជាណាចក្រកម្ពុជាបាន។ នៅក្នុងចំណោម៦០ក្រុមហ៊ុននោះ គឺមានក្រុមហ៊ុនអាកាសចរកម្ពុជាសរុបចំនួន១៣ ចំណែកឯក្រុមហ៊ុនអាកាសចរចិនវិញ មានចំនួនសរុប១១ ដែលបាននិងកំពុងហោះតភ្ជាប់ពីប្រទេសចិន មកកម្ពុជា ដែលក្នុងនោះជើងហោះហើរពីបណ្តាខេត្តមួយចំនួននៃប្រទេសចិនមកភ្នំពេញមានចំនួន៨៨ជើងក្នុងមួយសប្តាហ៍ មកពីសៀមរាបមានចំនួន ៩០ជើងក្នុងមួយសប្តាហ៍ និងមកពីក្រុងព្រះសីហនុមានចំនួន ៥ជើងក្នុងមួយសប្តាហ៍។

**២. វិស័យវិនិយោគ**

ចាប់តាំងពីឆ្នាំ២០១០មក ការរីតចំណងមិត្តភាពរវាងប្រទេសទាំងពីរទៅលើវិស័យវិនិយោគបានឈានដល់កម្រិតកំពូល ពោលគឺចាក់ទឹកមិនលិច ដែលបានជះឥទ្ធិពលយ៉ាងសំខាន់សម្រាប់កម្ពុជាក្នុងការកំណត់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ដែលគ្រោងនឹងសម្រេចឲ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក៏ក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅត្រឹមឆ្នាំ ២០៥០។ បើយើងក្រឡេកទៅមើល ទំហំវិនិយោគទុនពីសាធារណរដ្ឋប្រជាមានិតចិន មកលើកម្ពុជាវិញ យើងសង្កេតឃើញថាមានទំហំ ១០៨០លានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៦ និងបានកើនឡើងរហូតដល់ ១៦៤៤លានដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៧ រហូតបន្តកើនឡើងយ៉ាងខ្លាំង

នៅឆ្នាំ២០១៨ (គិតត្រឹមខែមិថុនា) ជាមួយទំហំទឹកប្រាក់សរុបចំនួន ២.៨២២លានដុល្លារ ធ្វើឲ្យប្រទេសចិនក្លាយជាប្រទេសជាប់ចំណាត់ថ្នាក់លេខ១ក្នុងចំណោមវិនិយោគទុនបរទេសក្នុងប្រទេសកម្ពុជា។

បើយោងទៅរបាយការណ៍ របស់ស្ថានទូតប្រទេសចិនប្រចាំនៅកម្ពុជាក៏បានបញ្ជាក់ផងដែរថា បច្ចុប្បន្នមានក្រុមហ៊ុនចិនច្រើនជាង២ពាន់ក្រុមហ៊ុន កំពុងវិនិយោគនៅកម្ពុជា ដែលភាគច្រើនធ្វើការគ្របដណ្ដប់ទៅលើវិស័យមួយចំនួនដូចជា៖ វិស័យវារីអគ្គិសនី វិស័យឧស្សាហកម្ម មានដូចជាឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ រោងចក្រកិនស្រូវ កសិឧស្សាហកម្មកៅស៊ូ និងជី រ៉ែ និងថាមពលរោចក្រត្បូងថ្ម និងការវិនិយោគលើវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធជាដើម។[35]

**ក. ការវិនិយោគលើវិស័យឧស្សាហកម្ម កម្សាន្តសាល រ៉ែ ថាមពល**

ការវិនិយោគពីប្រទេសចិន មកប្រទេសកម្ពុជាទៅលើវិស័យវារីអគ្គិសនីដែលបានសាងសង់រួចរាល់ហើយ អាចធ្វើការដំណើរការបាន នាពេលបច្ចុប្បន្ននេះគឺមានសរុបចំនួន៧កន្លែង ដែលស្ថិតនៅក្នុងខេត្តចំនួន៩របស់ប្រទេសកម្ពុជា។ បន្ថែមពីលើនេះទៀត ប្រទេសចិនក៏បានធ្វើការវិនិយោគរោងចក្រផលិតអគ្គិសនីដោយកាកអំពៅ និងត្បូងថ្មដែលបច្ចុប្បន្ននេះមានចំនួន៣រោងចក្រហើយ។

១. រោងចក្រអគ្គិសនីដុតកាកអំពៅអានុភាព ៩មេហ្គាវ៉ាត់

២. រោងចក្រអគ្គិសនីដុតកាកអំពៅនៅខេត្តក្រចេះ អានុភាព ២០មេហ្គាវ៉ាត់

៣. រោងចក្រអគ្គិសនីដុតត្បូងថ្ម នៅខេត្តព្រះសីហនុ អានុភាព ៣ x ១៣៥ មេហ្គាវ៉ាត់។ និងបណ្ដាញបញ្ជូនអគ្គិសនីដែលជាប្រព័ន្ធតភ្ជាប់រវាងភ្នំពេញ-បាត់ដំបង ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល និងមានប្រវែង ៣២០គីឡូម៉ែត្រ។

**ខ. ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ**

បើយោងតាមការអ្នកវិភាគសេដ្ឋកិច្ច លោក **គេង ឌីលុច** បាននិយាយថា វិស័យសំណង់បានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ច្រើនជាងគេនៅកម្ពុជា គឺរហូតដល់ទៅ ២០០០ លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆមាសទីមួយនៃឆ្នាំ២០១៨ ដែលសមិទ្ធផលដ៏អស្ចារ្យនេះគឺកើតឡើងដោយសារស្ថិរភាពនយោបាយនិងសេដ្ឋកិច្ចនៅកម្ពុជា ក៏ដូចជាច្បាប់ក្នុងការការពារវិនិយោគិន ដែលធ្វើការបណ្ដាក់ទុកក្នុងវិនិយោគក្នុងវិស័យសំណង់ និងហេដ្ឋារចនាសម្ព័ន្ធមួយនេះ។

បច្ចុប្បន្នប្រទេសចិនឈរនៅចំណាត់ថ្នាក់ទី១ លើការវិនិយោគលើវិស័យសំណង់ និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជា ដែលមានទុនវិនិយោគសរុបប្រមាណ ៨៩១ លានដុល្លារ។ កាលពីឆ្នាំ២០១៦(មករា ដល់មេសា) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានអនុម័តគម្រោង

[35] លោក ហ៊ីន ពិសី និងលោក ស៊ិន សារ៉ាត,«ការវិនិយោគចិន កំពុងងាកទៅរកតំបន់សក្ដានុពលផ្សេងទៀតនៅកម្ពុជា», *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨

សាងសង់ចំនួន ៧១២គម្រោង និងបានកើនឡើងរហូតដល់១០២០គម្រោង ដែលរបាយការណ៍គិតចាប់ពីខែមករា ដល់មេសាក្នុងឆ្នាំ២០១៧។ បន្ថែមពីលើនេះទៀតថ្មីៗនេះ ប្រទេសកម្ពុជា និងប្រទេសចិនបានធ្វើការអនុម័តកិច្ចព្រមព្រៀងក្នុងការវិនិយោគលើវិស័យសំណង់ដែលជាគម្រោងធំៗប្រចាំឆ្នាំ២០១៨ចំនួន៣ផងដែរគឺៈ[36]

១. គម្រោងវិនិយោគសាងសង់ ប្រតិបត្តិការ និងការធ្វើអាជីវកម្ម ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ តាមរូបភាពសាងសង់-អាជីវកម្ម-ផ្ទេរ (BOT) ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលជាការវិនិយោគរបស់ក្រុមហ៊ុន Cambodian PPSHV Expressway ក្នុងទុនវិនិយោគសរុបចំនួន ១៨៧០លានដុល្លារសហរដ្ឋអាមេរិក។

២. គម្រោងវិនិយោគក្នុងការបង្កើតព្រលានយន្តហោះអន្តរជាតិ ដែលមានទីតាំងស្ថិតនៅខេត្តសៀមរាប របស់ក្រុមហ៊ុន Angkor International Airport Investment (Cambodia) ក្នុងទុនវិនិយោគសរុបចំនួន ៩២២លានដុល្លារសហរដ្ឋអាមេរិក ដែលក្នុងពេលឆាប់ៗខាងមុខនេះ នឹងត្រូវដាក់សម្ពោធឲ្យបើកការដ្ឋានសាងសង់ជាផ្លូវការដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។[37]

៣. ការពង្រីកគម្រោងប្រព័ន្ធទូរស័ព្ទ របស់ក្រុមហ៊ុន South East Asia Telecom (Cambodia) ក្នុងគម្រោងទុកវិនិយោគចំនួន ៩០០លានដុល្លារសហរដ្ឋអាមេរិក។

ក្រៅពីគម្រោងខាងលើដែលបានចុះបញ្ជីនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏មានគម្រោងក្នុងវិស័យសំណង់ និងអចលនទ្រព្យមួយចំនួនទៀតដែលបាន និងកំពុងអនុវត្តដែលពុំបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលគិតត្រឹមខែមិថុនា ឆ្នាំ២០១៨នេះ មានក្រុមហ៊ុនចិនចំនួន ២៩៣ បានចុះបញ្ជីជាក្រុមហ៊ុនសាងសង់ ឬប្រឹក្សាយោបល់សាងសង់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងចំណោមក្រុមហ៊ុនបរទេសសរុបចំនួន ៦៩០។ផងដែរ គម្រោងសំណង់ដែលលេចធ្លោដែលប្រទេសចិនបានធ្វើការវិនិយោគក្នុងប្រទេសកម្ពុជាកាលពីពេលកន្លងទៅនេះរួមមាន

១. គម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលពាណិជ្ជកម្មចម្រុះCity Gate របស់ក្រុមហ៊ុនChean Chhoeng Thai Group នៅលើផ្ទៃដីទំហំសរុប៩២.៥៣៨ ម៉ែត្រការ៉េ តាមបណ្តោយទន្លេសាបពីស្ពានជ្រោយចង្វារដល់ផ្សាររាត្រីដែលបានជួលពីកំពង់ផែស្វយ័តភ្នំពេញ។

២.គម្រោងអភិវឌ្ឍន៍អាគារពហុបំណង Sino Plaza ដែលមានផ្ទៃក្រឡាសំណង់ ២១៧.០០០ ម៉ែត្រការ៉េ នៅសង្កាត់បឹងត្របែក រាជធានីភ្នំពេញ។

៣.គម្រោងអភិវឌ្ឍន៍សណ្ឋាគារលំដាប់ផ្កាយប្រាំដែលមានឈ្មោះ Prince Times របស់ក្រុមហ៊ុន

[36] សមាគមអ្នកសាងសង់កម្ពុជា «ការវិនិយោគលើវិស័យសំណង់នៅកម្ពុជា» *Cambodia Construction Property,* ២០១៧

[37] លោក ជា អូន អ្នកនាំពាក្យ និងជារដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ១១ មីនា ២០១៩

Prince Real Estate Group (Cambodia) លើផ្ទៃដី ២៩.០០០ម៉ែត្រការ៉េនៅខេត្តព្រះសីហនុ។

៩.គម្រោងអភិវឌ្ឍន៍សួនវប្បធម៌កម្ពុជា-ចិន របស់ក្រុមហ៊ុនឈ្មោះថា Yunnan Cultural Industry Investment Holding Group នៅលើផ្ទៃដីចំនួន ៣.៣ ហិកតា នៅខេត្តសៀមរាប។

## គ. ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស

នៅក្នុងព្រះរាជាណាចក្រកម្ពុជា តំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងលើកដំបូងបំផុតតាំងពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥មកម្ល៉េះ។[38] តំបន់សេដ្ឋកិច្ចពិសេសគឺជាតំបន់បង្កើតឡើសម្រាប់ប្រមូលផ្តុំដោយការវិនិយោគរួមផ្តុំគ្នាដែលមានដូចជា វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង គ្រឿងអេឡិចត្រូនិច និងចំណីអាហារជាដើម ដែលភាគច្រើនសម្រាប់នាំចេញទៅបរទេសដែលដើរតួយ៉ាងសំខាន់បំផុតជាកន្សោមឧស្សាហកម្ម ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

ម្យ៉ាងវិញទៀត រាល់ការបោះទុនវិនិយោគ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នឹងទទួលបានការលើកទឹកចិត្តដោយមិនយកពន្ធអាករលើតម្លៃបន្ថែម សម្រាប់ការនាំចេញ និងការទទួលបានការសម្រួលលើបែបបទនាំចេញ ដែលការវិនិយោគនៅខាងក្រៅតំបន់សេដ្ឋកិច្ចមិនអាចទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តំបន់សេដ្ឋកិច្ចពិសេសនេះអាចបង្កើតឡើងបានដោយរដ្ឋផ្ទាល់ ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនចំណុះណាដែលមានទំហំផ្ទៃដីចាប់ពី៥០ហិកតាឡើងទៅ ដែលមានទីតាំងច្បាស់លាស់ និងមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធនានាបានល្អ ដូចជា គមនាគមន៍ ទឹកស្អាត ប្រព័ន្ធបង្ហូរទឹកកខ្វក់ និងមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ជាដើម។

នៅក្នុងឆ្នាំ២០១៧កន្លងទៅ ទុនវិនិយោគសរុបរបស់តំបន់សេដ្ឋកិច្ចពិសេសទាំងអស់នៅក្នុងប្រទេសកម្ពុជាមានប្រមាណជាង ២.៧០០ លានដុល្លារអាមេរិក ដែលក្នុងនោះការវិនិយោគផ្ទាល់ពីបរទេស(Foreign Direct Investment) គ្របដណ្តប់ប្រមាណ៩៩% រួមជាមួយនឹងទឹកប្រាក់នាំចេញសរុបមានជាង១.៥ ពាន់លានដុល្លារអាមេរិក។ ជាការពិតណាស់ ក្រុមហ៊ុនចិនត្រូវបានគេដឹងថា បានវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសច្រើនជាងគេបង្អស់ពោលគឺមាន២៩% បន្ទាប់មកគឺក្រុមហ៊ុនជប៉ុនមាន ២៦% ក្រុមហ៊ុនពីបណ្តាប្រទេសអាស៊ានមាន ២៤% ក្រុមហ៊ុនមកពីចិនតៃប៉ិមាន ១១% និងសហរដ្ឋអាមេរិកមានចំនួនត្រឹមតែ៩%តែប៉ុណ្ណោះ។ ក្រុមហ៊ុនចិន បាននិងកំពុងវិនិយោគទៅលើតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាចំនួន៣ខេត្តគឺ៖ ខេត្តព្រះសីហនុ ស្វាយរៀង និងកំពត។[39]

---

[38] អនុក្រឹត្យលេខ១៤៨ អនក្រ.បក «ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា» ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥

[39] ចាន់ មង្គល, «ដើមឆ្នាំ២០១៨នេះតើតំបន់សេដ្ឋកិច្ចទាំង ៣២ មានសន្ទុះអភិវឌ្ឍន៍យ៉ាងដូចម្តេចខ្លះ», *គេហទំព័រខេមបូឌាមីស*, ឆ្នាំ២០១៨

**គ.១ តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ**

តំបន់សេដ្ឋកិច្ចពិសេសនេះមាន ក្រុមហ៊ុនវិនិយោគសរុបចំនួន ១៣៣ក្រុមហ៊ុន និងមានគម្រោងសរុបចំនួន១៣៦ ដែលបាននឹងកំពុងធ្វើប្រតិបត្តិការការងាររបស់ខ្លួន ដោយបានគ្របដណ្តប់រហូតលើផ្ទៃដីសរុបចំនួន១.១១៤ហិកតា ដែលក្នុងនោះក្រុមហ៊ុនចិនមានចំនួនរហូតដល់ទៅ១២១ ដែលស្មើនឹង៩១%នៃចំនួនក្រុមហ៊ុនសរុបទាំងអស់ ជាមួយនឹងទុនសរុបចំនួន ៩៦១លានដុល្លារសហរដ្ឋអាមេរិកដែលបាននិងកំពុងផ្តល់ការងារដល់កម្មករកម្មការីកម្ពុជាប្រមាណ២០.៩៣៧នាក់។

**គ.២. តំបន់សេដ្ឋកិច្ចពិសេសខេត្តស្វាយរៀង**

តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ខេត្តស្វាយរៀង ដែលមានរោងចក្រកំពុងដំណើរការផលិតជាង៣០រោងចក្រ ក្នុងនោះភាគច្រើនជាការវិនិយោគពីក្រៅប្រទេស ប្រមាណជា ៩០ភាគរយគឺមកពីប្រទេសចិន ក្រៅពីនោះមាន វៀតណាម និងសហរដ្ឋអាមេរិកជាដើម បានផ្តល់ឱកាសការងារជូនកម្មករ កម្មការិនីប្រមាណជាង៣ម៉ឺននាក់។

**ឃ. ការវិនិយោគលើវិស័យឧស្សាហកម្ម និងកម្សាន្តសាល**

វិស័យឧស្សាហកម្ម បានដើរតួយ៉ាងសំខាន់ក្នុងការជួយជម្រុញ វិស័យសេដ្ឋកិច្ចអភិវឌ្ឍយ៉ាងឆាប់រហ័ស និងទទួលបានកំណើនប្រចាំឆ្នាំជាមធ្យម៧ភាគរយ ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ។

កន្លងមក រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រាប់ឆ្នាំ២០១៥-២០២៥ ដែលយោងតាមទស្សនវិស័យឆ្នាំ២០៣០ ដើម្បីធ្វើការប្រែក្លាយកម្ពុជា ជាប្រទេសដែលមានប្រាក់ចំណូលកម្រិតកណ្តាលដោយសង្កត់ធ្ងន់លើតួនាទីវិស័យឧស្សាហកម្ម ជាកម្លាំងជម្រុញកំណើនដ៏សំខាន់មួយនៅពេលអនាគត។ នៅក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីនៃប្រទេសចិននៅកម្ពុជាកាលពីឆ្នាំ២០១៦កន្លងទៅនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការជាតិអភិវឌ្ឍន៍និងកំណែទម្រង់នៃប្រទេសចិនបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា ស្តីការជម្រុញគម្រោងកិច្ចសហប្រតិបត្តិការវិនិយោគឧស្សាហកម្មគន្លឹះ ដើម្បីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងវិនិយោគកម្ពុជា-ចិន។

បើក្រឡេកមើលតាមការវិវត្តវិស័យកាត់ដេរ និងដេរស្បែកជើង បានកម្រើកខ្លួនយ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា។ នេះបើគិតចាប់តាំងពីឆ្នាំ ១៩៩៦ មក វិស័យនេះបាន ក្លាយជាវិស័យដំបូងដែលជនជាតិចិនបានបង្កើតទុនវិនិយោគមុនគេ គឺបន្ទាប់ពីកម្ពុជា បានចាប់ផ្តើមរៀបចំប្រទេស ដែលហែកហួរដោយសារសង្គ្រាមឡើងវិញ ដែលគិតចាប់តាំងពីឆ្នាំ១៩៩៤ រហូតមកដល់ខែតុលាឆ្នាំ២០១៦ ប្រទេសចិនបានបោះទុនវិនិយោគនៅក្នុងវិស័យជាមួយនឹងទឹកប្រាក់ជាង៤៣ាន់លានដុល្លារអាមេរិក។ បើយោងតាម សមាគមរោងចក្រកាត់ដេរនៅកម្ពុជា វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ផ្តល់

ការងារដោយផ្ទាល់ដល់ប្រជាពលរដ្ឋប្រមាណ៧០ម៉ឺននាក់ ដែលជាង៨៥%ជាស្ត្រី មកពីបណ្តាខេត្តនានា ហើយនិងមានប្រជាពលរដ្ឋខ្មែរប្រមាណ២លាននាក់ដទៃទៀត ក្នុងចំណោមប្រជាពលរដ្ឋសរុប១៦លាននាក់គឺបាន និងកំពុងពឹងផ្អែកលើវិស័យនេះ។[40]

ម្យ៉ាងទៀត វិស័យរុករករ៉ែនៅកម្ពុជា នាពេលបច្ចុប្បន្ននេះ គឺកំពុងមានការកើនឡើងផងដែរ។ ក្នុងចំណោមក្រុមហ៊ុនចំនួន២៣ ដែលបានចាប់ដំណើរការចុះសិក្សា និងរុករករ៉ែតាមរយៈការផ្តល់អាជ្ញាបណ្ណ ដោយក្រសួងរ៉ែ និងថាមពល ជាក់ស្តែងក្នុងនោះមានក្រុមហ៊ុនចិនចំនួន ១០ បានធ្វើការសិក្សាលើគម្រោងរ៉ែដែក មាស ទង់ដែង ត្បូងថ្ម ខ្សាច់ស៊ីលីកា បុកស៊ីតជាដើម។

**៣. វិស័យសង្គមកិច្ច**

តាមរយៈកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនោះ ប្រទេសចិន ត្រូវបានគេមើលឃើញថា គឺជាដៃគូយ៉ាងសំខាន់បំផុតរបស់កម្ពុជា ដែលមិនមែនត្រឹមតែជាដៃគូលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងនយោបាយការទូតនោះទេ ពោលគឺប្រទេសចិន ក៏បាននិងកំពុងជម្រុញកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកម្ពុជាទៅលើវិស័យសង្គមកិច្ចតាមរយៈ កិច្ចការងារមនុស្សធម៌ និងហិរញ្ញប្បទានឥតសំណងផ្សេងៗ ដែលផ្តល់ឲ្យប្រទេសកម្ពុជា ក្នុងន័យអភិវឌ្ឍន៍ទៅលើការងារក្នុងវិស័យសង្គមកិច្ចនានា គឺធ្វើយ៉ាងណាឲ្យប្រជាជននៃប្រទេសទាំងពីរយល់ចិត្តគ្នាបន្តិចម្តងៗ។

ជាក់ស្តែងប្រទេសចិនរីករាយរួមគ្នាជាផ្លូវមួយជាមួយកម្ពុជាក្នុ ងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ ទេសចរណ៍ បរិស្ថាន សុខាភិបាល និងអប់រំ តាមរយៈវិទ្យាស្ថានភាសាចិន ខុងជឺ និងផ្ទះវប្បធម៌(ភ្នំពេញ) ដើម្បីបង្កើនមនោសញ្ចេតនាមិត្តភាព និងស្វែងយល់ពីគ្នាទៅវិញទៅមករវាងប្រជាជននៃប្រទេសទាំងពីរ ជាពិសេសគឺយុវជននៃប្រទេសទាំងពីរ ដើម្បីធ្វើឲ្យមិត្តភាពចិន-កម្ពុជាកាន់តែមានលក្ខណៈប្រសើរឡើង ហើយនឹងស្ថិតស្ថេរជាដរាប និងអមតៈ។

**ក. វិស័យអប់រំ**

តាមរយៈកិច្ចទំនាក់ទំនងដ៏ស្អិតរមួតរវាងប្រទេសកម្ពុជា និងចិន ភាគទាំងពីរបានខិតខំបង្កើត និងបង្កើនកិច្ចសហប្រតិបត្តិការរវាងគ្នានឹងគ្នាទៅលើវិស័យអប់រំតាមរយៈការផ្តល់អាហារូបករណ៍ដល់និស្សិតទាំងពីរប្រទេស ហើយភាគីចិនតែងតែផ្តល់ឲ្យនូវជំនួយឥតសំណងជាច្រើនទាក់ទងទៅនឹងការសាងសង់សាលារៀន សម្ភារៈបរិក្ខារក្នុងសាលារៀន ក៏ដូចជាសម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការរបស់សិស្សជាដើម។

**ក.១ ការផ្លាស់ប្តូរអាហារូបករណ៍ដល់និស្សិតរវាងប្រទេសទាំងពីរ**

**អាហារូបករណ៍ដែលចិនផ្តល់ឲ្យនិស្សិតកម្ពុជា៖**

---

40 កែវ សុខា ,«រោងចក្របង្កើតថ្មីជិត ១៤០ បើករយៈពេល ១០ខែខណៈរោងចក្រ ៥០ត្រូវបានបិទ», *ព័ត៌មានថ្មីៗ*, ២០១៨

រាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនតែងតែផ្តល់អាហារូបករណ៍ដល់និស្សិតខ្មែរ ឲ្យបន្តការសិក្សាក្នុងថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិត ដែលក្នុងនោះកាលពីឆ្នាំ៖

២០១៦៖ ប្រទេសចិនបានផ្តល់អាហារូបករណ៍សរុប ចំនួន ១២១កន្លែង ជាប្រភេទអាហារូបករណ៍ក្នុងក្របខណ្ឌទ្វេភាគី-អាស៊ាននិងបណ្តាប្រទេសសាកលវិទ្យាល័យនៃប្រទេសចិន។

២០១៧៖ ប្រទេសចិនបានផ្តល់អាហារូបករណ៍សរុប ចំនួន ១៨១កន្លែង ជាប្រភេទអាហារូបករណ៍ក្នុងក្របខណ្ឌទ្វេភាគី-អាស៊ាននិងបណ្តាប្រទេសសាកលវិទ្យាល័យនៃប្រទេសចិន។

២០១៨៖ ប្រទេសចិនបានផ្តល់អាហារូបករណ៍សរុប ៣៣៨ កន្លែង (១៩១ កន្លែងដល់និស្សិតថ្មី និង ១៤៧កន្លែងដល់និស្សិតកំពុងសិក្សានៅប្រទេសចិន ដែលមានបំណងស្នើសុំបន្តក្នុងការសិក្សាបន្ថែមទៀត)។

ប្រទេសចិន ក៏បានសន្យាផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាចំនួន ៥០០នាក់ បន្ថែមពីលើអាហារូបករណ៍ដែលមានស្រាប់ និងជួយបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនកម្ពុជា ចំនួន១០០នាក់ សម្រាប់រយៈពេល ៥ឆ្នាំខាងមុខ។ បច្ចុប្បន្ន និស្សិតកម្ពុជាទាំងអស់ដែលកំពុងសិក្សានៅប្រទេសចិន មានចំនួន ១៥៩០នាក់ (នារីចំនួន ៥៨៥នាក់) ដោយឡែកនិស្សិតរៀននៅទីក្រុងប៉េកាំងមានចំនួន ២១៣នាក់ (នារី ៥៦នាក់)។[41]

**អាហារូបករណ៍ដែលកម្ពុជាផ្តល់ឲ្យនិស្សិតចិន៖**

២០១៧៖ ១៥នាក់ក្នុងមួយឆ្នាំ សិក្សាអក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

២០១៨៖ ១៥នាក់ក្នុងមួយឆ្នាំ សិក្សាអក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ជាមួយគ្នានេះ ដោយមើលឃើញការរីកចម្រើនយ៉ាងឆាប់រហ័សលើវិស័យសេដ្ឋកិច្ច ការងារបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ប្រទេសចិនបានសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជា បានកំណត់យ៉ាងច្បាស់នូវយុទ្ធសាស្ត្រ ធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ចិន ក៏ដូចជាក្រុមហ៊ុនបច្ចេកវិទ្យាល្បីៗរបស់ចិន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំនៅកម្ពុជា ដែលផ្តោតសំខាន់លើផ្នែកមួយចំនួនរួមមាន៖

- ការអភិវឌ្ឍសៀវភៅសិក្សាគោល និងសម្ភារៈឧបទេសឌីជីថលពាក់ព័ន្ធមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងវិទ្យាសាស្ត្រស្របតាមកម្មវិធីសិក្សារបស់ក្រសួង។
- អភិវឌ្ឍ និងអនុវត្តប្រព័ន្ធស្វ័យសិក្សា (MOOCs)។

[41] កិច្ចព្រមព្រៀងក្នុងអំលុងទស្សនកិច្ចនៅកម្ពុជារបស់ឯកឧត្តម **ស៊ី ជីនភីង** ពីថ្ងៃទី១៣ ដល់១៤ ខែតុលា ឆ្នាំ២០១៦

- កសាងមជ្ឈមណ្ឌល ទិន្នន័យអប់រំ និងប្រព័ន្ធសិក្សាតាមអេឡិចត្រូនិច។
- លើកកម្ពស់គម្រោងសាលារៀនជំនាន់ថ្មី។
- ការបោះពុម្ពសៀវភៅសិក្សាគោល។
- ការបណ្តុះបណ្តាលធនធានមនុស្សលើបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

ចំណែកឯគម្រោងមួយទៀតវិញ គឺជាការចុះអនុស្សរណៈនៃការយោគយល់ត្រីភាគីរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយក្រុមហ៊ុន Tianwen Technology (Beijing) និងក្រុមហ៊ុន Huawei (Cambodia) លើការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ នៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ តាមរយៈការធ្វើទំនើបកម្មវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដល់សិស្ស និងសាធារណៈជនឲ្យទទួលបានសេវាអប់រំប្រកបដោយគុណភាព និងធនធានអប់រំសម្បូរបែប បម្រើការបង្រៀន និងរៀនព្រមទាំងការរស់នៅប្រសើរជាងមុន។

### ក.២ ហិរញ្ញប្បទានឥតសំណងលើវិស័យអប់រំ

រដ្ឋាភិបាលចិនបានសម្រេចផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ៩០លានដុល្លារ សម្រាប់អនុវត្តន៍គម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារ អប់រំដល់សាលារៀន និងមជ្ឈមណ្ឌលគរុកោសល្យក្នុងរាជធានី-ខេត្ត ចំនួន១១ ព្រមទាំងបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀននៅកម្ពុជា។ ពិធីចុះហត្ថលេខាលើឯកសារនានា និងប្រកាសបើកជាផ្លូវការ នូវគម្រោងហិរញ្ញប្បទានឥតសំណងសម្រាប់ការកែលម្អបរិស្ថានសាសារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ រវាងប្រទេសទាំងពីរ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨។ គម្រោងនេះ គឺផ្តោតសំខាន់ទៅលើវិទ្យាល័យសំខាន់ៗក្នុងរាជធានី-ខេត្តចំនួន១១ ប៉ុន្តែក្នុងដំណាក់កាលទី១នេះ នឹងចាប់ផ្តើមអនុវត្តចំពោះតែក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ចាម និងខេត្តកណ្តាលតែប៉ុណ្ណោះ ដែលធ្វើការកែសម្រួលសម្ភារៈ បរិក្ខារក្នុងថ្នាក់រៀន ដូចជា តុ កៅអី ក្តារខៀន និងបរិស្ថានក្នុងសាលារៀន ឲ្យក្លាយ
ទៅជាទំនើបកម្ម តាមប្រព័ន្ធបច្ចេកវិទ្យា។[42]

អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះគឺគម្រោងនេះក៏បានផ្តោតសំខាន់ ទៅលើការកែលម្អសាលាគរុកោសល្យភូមិភាគ តាមរាជធានី-ខេត្តនីមួយៗសម្រាប់បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពគ្រូបង្រៀន ការកសាងបន្ទប់សម្រាប់គ្រូ ដើម្បីឲ្យគ្រូមានបន្ទប់ សិក្សាស្រាវជ្រាវ ស្វែងរកវិធីសាស្ត្រល្អៗ ក្នុងការបង្រៀន ជាពិសេសផ្គត់ផ្គង់សម្ភារៈបរិក្ខារសម្រាប់គ្រូឲ្យមានលក្ខណៈទំនើប។

---

[42] លោកបណ្ឌិត ឌី សមស៊ីដេត អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ ក្រសួងអប់រំ យុវជន និងកីឡា,«ក្រសួងអប់រំ ចាប់ផ្តើមអនុវត្តគម្រោងកែលំអបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ», *គេហទំព័រ កម្ពុជាថ្មី, ២០១៩*

ចំណែកឯនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៥ លោកជំទាវ **ពូ ជៀនតូ** អតីតឯកអគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសកម្ពុជា បានផ្ដល់ជំនួយជាកង់ចំនួន ២០០គ្រឿង ដល់សិស្សមធ្យមសិក្សាចំនួន២២ នៅក្នុងខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ហ៊ុន ម៉ានី** ជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ និងលោកគ្រូ-អ្នកគ្រូសរុបជាង១០០នាក់។[43]

ប្រទេសចិន ក៏បានផ្ដល់ជំនួយជូនវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែររួមមានៈ សម្ភារអេឡិចត្រូនិច និងបច្ចេកវិទ្យាព័ត៌មានដែលមានតម្លៃ ៥០០.០០០យ័ន ទទួលបាននៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨។

## ខ. វិស័យវប្បធម៌

ក្នុងនាមជាសម្ព័ន្ធមិត្តដ៏ជិតស្និតរបស់កម្ពុជា រដ្ឋាភិបាលនៃប្រទេសចិន ក៏បានស្នើឲ្យកម្ពុជាដកហិរញ្ញវត្ថុចេញពីហិរញ្ញប្បទានឥតសំណង ដែលចិនបានប្រគល់ឲ្យកម្ពុជាក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ សម្រាប់ធ្វើការអភិរក្ស និងជួសជុលប្រាង្គប្រាសាទបុរាណនៅកម្ពុជា ឬរាជវាំងនៅអង្គរដែលបានរងការបែកបាក់កាលពីពេលកន្លងទៅនេះ។

ប្រទេសទាំងពីរ សុទ្ធតែបានទទួលស្គាល់អំពីតម្លៃនៃវប្បធម៌ ដែលជាស្ពាន និងចំណងសម្រាប់ជំរុញការយោគយល់គ្នា និងការរៀនសូត្រទៅវិញទៅមករវាងប្រទេសទាំងពីរ។ ទន្ទឹមនឹងការរីកចម្រើនកាន់តែស៊ីជម្រៅអំពីទំនាក់ទំនងចិន និងកម្ពុជា ប្រទេសទាំងពីរពិតជាមានការផ្លាស់ប្ដូរច្រើនលើវិស័យវប្បធម៌ តាមរយៈការរៀបចំនូវសកម្មភាពវប្បធម៌ និងសិល្បៈមួយចំនួនធំទាំងក្នុងប្រទេសចិន និងប្រទេសកម្ពុជា ដែលកម្មវិធីទាំងនោះមានដូចជា "សប្ដាហ៍សិល្បៈចិនបច្ចុប្បន្ន" "ពិព័រណ៍ស្នាមញញឹមអង្គរ" "កម្មវិធីសម្ដែងល្ខោនអាយ៉ង" និង "កម្មវិធីសម្ដែងសិល្បៈបុរាណប្រពៃណីចិនដ៏សប្បាយរីករាយ" ជាដើម។ មិនតែប៉ុណ្ណោះទេ ប្រទេសចិននិងកម្ពុជាក៏បានរៀបចំសកម្មភាពវប្បធម៌ និងសិល្បៈមួយចំនួនទៀតលើវិស័យបណ្ដុះបណ្ដាល ការផ្លាស់ប្ដូរ និងពង្រឹងសមត្ថភាពធនធានមនុស្ស ហើយបានទទួលសមិទ្ធផលគួរឲ្យកត់សម្គាល់ផងដែរ។

ជាក់ស្ដែង កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ លោកជំទាវ **ពូ ជៀនតូ** អតីតឯកអគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសកម្ពុជាបានផ្ដល់ជាជំនួយដល់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជារួមមាន រថយន្តកុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនបោះពុម្ពនិងសម្ភារៈធ្វើការងារផ្សេងៗទៀត ដើម្បីបម្រើដល់ការងារជាប្រចាំនៅក្នុងក្រសួងផ្ទាល់។

បន្ថែមលើនេះទៀត ប្រទេសទាំងពីរបានកំណត់យកឆ្នាំ២០១៩នេះ ជាឆ្នាំពង្រឹង និងពង្រីកកិច្ច

43 «អត្ថបទពិសេសប្រចាំខែធ្នូ ឆ្នាំ២០១៥», *ទស្សនាវដ្ដី សេដ្ឋកិច្ចខ្មែរ*, ២០១៥

សហប្រតិបត្តិការរួមគ្នាលើវិស័យទេសចរណ៍ និងវប្បធម៌ ដែលប្រទេសទាំងពីរបានឲ្យឈ្មោះថា «ឆ្នាំវប្បធម៌ និងទេសចរណ៍កម្ពុជា-ចិន»។

ពិសេសទៅទៀតនោះ ដើម្បីជាការឆ្លើយតបទៅនឹងការប្រារព្ធខួបលើកទី ៦០ នៃកិច្ចទំនាក់ទំនងការទូតកម្ពុជា-ចិនក្នុងឆ្នាំ២០១៨ ក្រុមហ៊ុនចិនYunnan Cultural Industry Investment Holding Group បានបណ្តាក់ទុនជាង ៧០លានដុល្លារ ដើម្បីសាងសង់ឧទ្យានច្នៃប្រឌិតវប្បធម៌ប្រទេសកម្ពុជា-ចិន ដ៏ធំមួយនៅក្នុងក្រុងអង្គរ ខេត្តសៀមរាប។ គម្រោងនេះមានទីតាំងស្ថិតនៅជិតសណ្ឋាគារសុខាសៀមរាប និងគ្រោងនឹងបើកជាសាធារណៈនៅដើមឆ្នាំ២០២០។ មជ្ឈមណ្ឌលវប្បធម៌ដ៏ធំសម្បើមមួយនេះ កំពុងសាងសង់លើផ្ទៃដីសរុបប្រមាណ ៣.៣ ហិកតា ដែលក្រោយពេលសាងសង់រួច ឧទ្យាននេះនឹងក្លាយជាបណ្តុំតំបន់ទេសចរណ៍បែបវប្បធម៌រួមមាន៖ រោងមហោស្រពញញឹមអង្គរ សារមន្ទីរ Zhou Daguan មជ្ឈមណ្ឌលវប្បធម៌សម័យចេនឡា មជ្ឈមណ្ឌលផ្លាស់ប្តូរវប្បធម៌កម្ពុជា-ចិន មជ្ឈមណ្ឌលពិព័រណ៍ផលិតផលវប្បធម៌ និងភោជនីយដ្ឋានជាដើម។[44]

## គ. វិស័យសុខាភិបាល

ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា បាន និងកំពុងខិតខំបង្កើតនិងបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាប្រទេសដទៃៗទៀត ដើម្បីឲ្យកិច្ចការងារសុខាភិបាលកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។ក្នុងនោះយើងឃើញថា ក្រសួងសុខាភិបាលកម្ពុជាបានចុះអនុស្សារណៈនៃការយោគយល់ ក៏ដូចជាកិច្ចព្រមព្រៀង ជាមួយនឹងប្រទេសចិន លើផ្នែកសុខាភិបាលនេះ តាមរយៈការចុះជួយព្យាបាលប្រជាពលរដ្ឋកម្ពុជាដោយឥតគិតថ្លៃ និងតែងតែផ្គត់ផ្គង់នូវសម្ភារៈបរិក្ខារផ្សេងៗដើម្បីបម្រើដល់វិស័យសុខាភិបាលនៅក្នុងប្រទេសកម្ពុជា។

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥កន្លងទៅនេះ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លោកជំទាវ **ពូ ជៀនហ្គ័រ** អតីតឯកអគ្គរដ្ឋទូតចិនប្រចាំប្រទេសកម្ពុជា បានផ្តល់រថយន្តសង្គ្រោះបន្ទាន់ចំនួន ២០០គ្រឿង ដែលជារថយន្តមានបំពាក់បរិក្ខារពេទ្យរួចជាស្រេច ដែលមានបច្ចេកទេសពេញលេញ និងគុណភាពល្អ ដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងចែកចាយទៅមន្ទីរពេទ្យដែលត្រូវការបំផុតនៅតាមបណ្តារាជធានីខេត្តទាំង២៥ ទូទាំងប្រទេសកម្ពុជា។ ការផ្តល់ជំនួយនេះ គឺក្រោយពីប្រទេស ចិនបានស្វែងយល់ឃើញថាមន្ទីរពេទ្យច្រើននៅកម្ពុជា ជាពិសេសមន្ទីរពេទ្យដែលនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ខ្វះខាតរថយន្តសង្គ្រោះ ដែលត្រូវការដឹកជញ្ជូនអ្នកជំងឺ ហើយមានអ្នកជំងឺមួយចំនួនដែលត្រូវការសង្គ្រោះបន្ទាន់ បានខកខានរយៈពេលព្យាបាលដោយមានប្រសិទ្ធភាព

---

44 ប្រភពគេហទំព័រ Smile of Angkor ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨

ព្រោះតែរថយន្តសង្គ្រោះមិនទាន់មានគ្រប់គ្រាន់។[45]

បន្ថែមលើនេះទៀត ក្រសួងសុខាភិបាលកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការលុបបំបាត់ភាពងងឹតភ្នែក ដោយសារជំងឺភ្នែកឡើងបាយ ជាមួយអង្គការ Asian Foundation for Prevention of Blindness និង Belt and Road Hong Kong Center Company Limited របស់ប្រទេសចិន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងហុងកុង ប្រទេសចិន។

តាមរយៈអនុស្សារណៈនៃការយោគយល់នេះ ក្រសួងសុខាភិបាលបានទទួលនូវរថយន្តគ្លីនិកចល័ត សម្រាប់វះកាត់ភ្នែកឡើងបាយ ចំនួន២គ្រឿង ដែលគិតជាទឹកប្រាក់សរុប៩០ម៉ឺនដុល្លារអាមេរិក និងរថយន្តក្រុងសម្រាប់ដឹកអ្នកជំងឺចំនួន១គ្រឿង ដែលមានតម្លៃជាទឹកប្រាក់សរុប៩ម៉ឺនដុល្លារ។

បើយោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ កន្លងទៅនេះ ប្រទេសចិនបានព្រមព្រៀងផ្តល់គ្លីនិកចល័តចំនួន៤០គ្រឿង និងឡជីវឧស្ម័នចំនួន ១៥០០ឡដល់កម្ពុជា ក្នុងក្របខណ្ឌជំនួយឥតសំណង។ រថយន្តគ្លីនិកចល័តចំនួន៤០គ្រឿង និងសម្ភារបរិក្ខារ នឹងត្រូវយកទៅផ្គត់ផ្គង់តាមរាជធានី ខេត្តទាំង ២៥ ដែលនឹងបង្កិតសេវាសុខាភិបាលកាន់តែជិត និងមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋតាមទីដាច់ស្រយាល។ រីឯ ជំនួយឡជីវឧស្ម័ន ១៥០០ ឡ នឹងត្រូវធ្វើការសាងសង់នៅខេត្តចំនួន៦ រួមមាន៖ ខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តពោធិ៍សាត់ ដែលនឹងជួយដល់ប្រជាកសិករក្នុងការបំប្លែងឧស្ម័នពីលាមកសត្វយកមកចំអិនអាហារ ហើយកាកសំណល់ក្នុងឡក៏អាចធ្វើជាជីសម្រាប់ដំណាំផងដែរ។ ជំនួយឥតសំណងនេះនឹងធ្វើការប្រគល់ជូនកម្ពុជាជាបីដំណាក់កាលគឺ៖

- ដំណាក់កាលទី១ គឺប្រគល់ជូន ឡជីវឧស្ម័នចំនួន១៥០០ឡ ជូនរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ១០ ខែវិច្ឆិកា ២០១៧ គឺនៅថ្ងៃដែលលិខិតប្តូរសារត្រូវបានចុះថ្ងៃ
- ដំណាក់កាលទី២ គឺពិធីប្រគល់ និងទទួល រថយន្តគ្លីនិកចល័តចំនួន២០គ្រឿង នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨។
- ដំណាក់កាលទី៣ ដែលជាដំណាក់កាលចុងក្រោយគឺ រថយន្តគ្លីនិកចល័ត ២០គ្រឿងទៀត បានប្រគល់ជូននៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨។[46]

រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិនក៏បានបង្កើតនូវគម្រោងមួយដែលមានឈ្មោះថា "ដំណើរនៃក្តីស្រឡាញ់ពីបេះដូង" ក្នុងគោលបំណងធ្វើការព្យាបាលវះកាត់ដល់អ្នកមានជំងឺបេះដូងនៅកម្ពុជា ដែលគម្រោងនេះនឹងត្រូវធ្វើការអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៨ ដល់ខែធ្នូ ឆ្នាំ២០២០ ដែលនៅ

45 ប្រសាសន៍អ្នកស្រី **ព្រៀង ហ្វ័រ** អតីតឯកអគ្គរដ្ឋទូតចិនប្រចាំប្រទេសកម្ពុជា

46 សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧

ក្នុងកិច្ចព្រមព្រៀងនះបានចែងនូវចំណុចរួមមួយចំនួនដែលមានដូចជាៈ

- ផ្តល់ការវះកាត់ជំងឺបេះដូងដោយឥតគិតថ្លៃដល់អ្នកជម្ងឺកម្ពុជាចំនួន១០នាក់
- ផ្តល់ការបណ្តុះបណ្តាលពិសេសដល់បុគ្គលិកពេទ្យកម្ពុជា នៅប្រទេសចិន
- បញ្ជូនក្រុមអ្នកជំនាញវះកាត់ជំងឺបេះដូងមកកម្ពុជា និង
- បង្កើតមជ្ឈមណ្ឌលមិត្តភាពជំងឺបេះដូងកម្ពុជា-ចិន នៅកម្ពុជា។

**ឃ. វិស័យបរិស្ថាន**

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងបរិស្ថាន ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានអនុញ្ញាតឲ្យឯកឧត្តមបណ្ឌិត ZHAO Yingmin អនុរដ្ឋមន្ត្រីនៃក្រសួងអេកូឡូស៊ី និងបរិស្ថាន នៃប្រទេសចិន ជួបសំដែងការគួសម ក្នុងដំណើរទស្សនកិច្ចក្នុងប្រទេសកម្ពុជា។

នៅក្នុងជំនួបនេះ ឯកឧត្តមទាំងពីរ បានចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួន០៣ ស្តីពីៈ

១.ការបង្កើតការិយាល័យរៀបចំបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានកម្ពុជា-ចិន

២.កិច្ចសហប្រតិបត្តិការអភិរក្សជីវៈចម្រុះ កម្ពុជា-ចិន

៣.គម្រោងឧបត្ថម្ភម៉ាស៊ីនសំអាតទឹកកខ្វក់។

ឯកឧត្តមទាំងពីរ ក៏បានចូលរួមសម្ពោធក្នុងការដាក់ឱ្យប្រើប្រាស់នូវ "ការិយាល័យ រៀបចំបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានរវាងកម្ពុជា-ចិន ដែលមានទីតាំងស្ថិតនៅក្នុងទីស្តីការរបស់ក្រសួងបរិស្ថានផ្ទាល់ ដែលការសម្ពោធនេះគឺធ្វើឡើងក្រោយពីមជ្ឈមណ្ឌលនេះត្រូវបានគ្រោងក្នុងការសាងសង់កាលពីឆ្នាំ២០១៥កន្លងទៅ តាមរយៈការចុះអនុស្សារណៈនៃការយោគយល់រវាងភាគីទាំងពីរ។[47]

អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៦ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភាជាតិកម្ពុជា ដែលដឹកនាំដោយ **ឯកឧត្តម ឈាង វុន** រួមនឹងគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ដឹកនាំដោយ **ឯកឧត្តម ប៉ុល ហំម** បានជួបពិភាក្សា ការងារជាមួយ **ឯកឧត្តម លូ ហាវ** ប្រធានគណៈកម្មាធិការការពារបរិស្ថាន និងធនធានទឹកនៃសភាប្រជាជនចិន ដែលបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា -ចិន លើកិច្ចការការពារបរិស្ថានក្នុងប្រទេសទាំងពីរ និងក៏ដើម្បីបង្កើនកិច្ចសហប្រតិបត្តិ

47 «ការិយាល័យរៀបចំបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថាន កម្ពុជា-ចិន» ,*ក្រសួងបរិស្ថាន*, ឆ្នាំ២០១៨

រវាងសភាប្រទេសទាំង២។[48]

កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨នេះ ឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការនៃក្រសួងបរិស្ថាន បានទទួលជួបសំណេះសំណាលជាមួយក្រុមជំនាញការចិនចំនួន៥រូប ដឹកនាំដោយលោកសាស្ត្រាចារ្យ បណ្ឌិត Wang Dongsheg នាយករងវិទ្យាស្ថានស្រាវជ្រាវ ការពារសារធាតុគីមី និង ក្រុមការងារវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រអេកូស៊ីបរិស្ថាន នៃរាជបណ្ឌិតសភាវិទ្យាសាស្ត្រយោធាចិន និងក្រុមការងារក្រសួងបរិស្ថាន មកពីនាយកដ្ឋានគ្រប់គ្រងគុណភាពទឹក នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ និងមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃទីស្ដីការ ក្រសួងបរិស្ថាន ។ ក្នុងអំឡុងកិច្ចពិភាក្សានេះ ប្រទេសចិនដែលតំណាងឲ្យរាជបណ្ឌិតសភាវិទ្យាសាស្ត្រយោធាចិន បាននាំមកនូវជំនួយបច្ចេកទេស និងថវិកា ក្នុងនោះរួមមានឧបករណ៍ពិសោធន៍ ដែលមានតម្លៃប្រហែលមួយលានដុល្លារសហរដ្ឋអាមេរិក សម្រាប់វិភាគគុណភាពទឹក និង បរិស្ថាននៅក្នុងកម្ពុជា ជាពិសេសបង្កើនសមត្ថភាពមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

## ង. កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងលើវិស័យផ្សេងៗ

### ង.១ ក្រុងសម្ព័ន្ធមេត្រីភាព

នាពេលបច្ចុប្បន្ននេះ រាជធានីភ្នំពេញ និងខេត្តនៃព្រះរាជាណាចក្រកម្ពុជាសរុបចំនួន២០ បានចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត និងក្រុងរបស់សាធារណរដ្ឋប្រជាមានិតចិនសរុបចំនួន៤១។ ក្នុងនោះរដ្ឋាភិបាលនៃខេត្តក្វាងស៊ី នៃប្រទេសចិនតែងតែផ្ដល់ជំនួយដល់កម្ពុជាជារឿយៗ។

ឆ្នាំ២០១៥៖ អំណោយអភិបាលខេត្តក្វាងស៊ី ជូនសម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលក្នុងនោះរួមមានគ្រឿងយន្តចំនួន៦០គ្រឿង (Walking Tractor ៤០គ្រឿង Forklift ១០គ្រឿង និង Wheel Loader ១០គ្រឿង)។

ឆ្នាំ២០១៦៖ លេខាបក្សខេត្តក្វាងស៊ីផ្ដល់អំណោយជាអង្ករចំនួន ១.១៦០តោន (ទិញអង្ករនៅកម្ពុជា) ដែលមានទឹកប្រាក់សរុបចំនួន ១លានដុល្លារសហរដ្ឋអាមេរិក នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៦ ក្នុងជំនួបជាមួយសម្ដេចនាយករដ្ឋមន្ត្រី។

ឆ្នាំ២០១៧៖ អភិបាលខេត្តក្វាងស៊ីផ្ដល់អំណោយជាកុំព្យូទ័រយួរដៃចំនួន ៨០០គ្រឿង និងអង្ករក្រអូបលេខ១ ចំនួន ៨៤០តោន ដែលមានទឹកប្រាក់សរុប ១លានដុល្លារសហរដ្ឋអាមេរិក។ (ក្នុងជំនួបជាមួយសម្ដេចតេជោនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧។)

ឆ្នាំ២០១៨ ៖ អភិបាលខេត្តក្វាងស៊ីផ្ដល់អំណោយជាអង្ករចំនួន ១៦០តោន ដែលមានតម្លៃ១លាន

[48] ព័ត៌មានប្រចាំថ្ងៃ ពីគេហទំព័រផ្លូវការរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩

យ័ន (ក្នុងជំនួបជាមួយសម្តេចតេជោ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ នៅភ្នំពេញ) និង លេខាបក្សខេត្តក្វាងស៊ីក៏បានផ្តល់អំណោយជាអង្ករ ដែលមានតម្លៃ ១លានដុល្លារ) (ក្នុងជំនួបជាមួយសម្តេចតេជោ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងណាននីង) ។

**ង.២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន**

១. ជំនួយជូនអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន រួមមាន ម៉ូតូ៥០គ្រឿង កុំព្យូទ័រយួរដៃ១៨គ្រឿង កុំព្យូទ័រលើតុ០២គ្រឿង អាយផេត១០គ្រឿង តង់កៅស៊ូ៣៥០តង់ រទេះរុញសម្រាប់ជនពិការ១២០០គ្រឿង ម៉ាស៊ីនរាវរកដែក១៨គ្រឿង ម៉ាស៊ីនកម្ទេចគ្រាប់១៨គ្រឿង សំលៀកបំពាក់ការពារពេលដោះមីន១៨កំប្លេ និងឧបករណ៍បោសសម្អាតមីន ១៨គ្រឿង ទទួលបាននៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។

២. ហិរញ្ញប្បទានឥតសំណង ២.៥០០.០០០ដុល្លារអាមេរិក ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សម្រាប់ធ្វើការអនុវត្តគម្រោងប្រតិបត្តិការសកម្មភាពមីនមនុស្សធម៌។

**ង.៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

១. ជំនួយជាសម្ភារៈបរិក្ខារចំនួន ៣០មុខ ដល់គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ (យោងសេចក្តីប្រកាសព័ត៌មានរបស់គ.ជ.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧)។

២. បរិក្ខារមួយកញ្ចប់មានទឹកប្រាក់សរុបចំនួន ៥០.០០០.០០០ យ័ន (ប្រមាណ៧.៨លានដុល្លារសហរដ្ឋអាមេរិក) សម្រាប់ការបោះឆ្នោតសាកល ឆ្នាំ២០១៨(បានចុះហត្ថលេខានៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ នឹងត្រូវដកចេញពីហិរញ្ញប្បទានឥតសំណង ដែលមានចែងក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥)។

៣. រដ្ឋាភិបាលចិនបានចាត់បញ្ជូនអ្នកសង្កេតការណ៍ចំនួន១១នាក់មកពីស្ថានទូតចិននៅភ្នំពេញមកសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ឆ្នាំ២០១៨នៅកម្ពុជា។

**ង.៤ ជំរឿនប្រជាជន**

រដ្ឋាភិបាលចិនក៏បានផ្តល់បរិក្ខារមួយកញ្ចប់ដែលមានដូចជា៖ កុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃ និងសម្ភារៈផ្សេងទៀត ដើម្បីគាំទ្រគម្រោងជំរឿនប្រជាជនកម្ពុជាក្នុងឆ្នាំ២០១៩ ដែលត្រូវចំណាយប្រាក់សរុបចំនួន ១៥.០០០.០០០យ័ន នឹងត្រូវដកពីហិរញ្ញប្បទានឥតសំណងដែលមានចែងក្នុងកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣។

ជាចុងក្រោយ យើងសង្កេតឃើញថា តាមរយៈការឆ្លងកាត់នូវសកម្មភាពនៃការគាំទ្រកន្លងមកការវិនិយោគ ការធ្វើពាណិជ្ជកម្ម និងការផ្តល់ជាហិរញ្ញប្បទានឥតសំណងមកកាន់រដ្ឋាភិបាលកម្ពុជា

ក្នុងន័យអភិវឌ្ឍន៍ប្រទេសជាតិនេះ គឺពិតជាបានឆ្លុះបញ្ចាំងឲ្យយើងបានឃើញយ៉ាងកាន់តែច្បាស់អំពីកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្ររបស់សម្ព័ន្ធមិត្តដ៏ជិតស្និទ្ធ ដែលមិនងាយបំបែកបាននេះ បាននិងកំពុងដើរទៅរកមាគ៌ានៃការសម្រេចបានប្រយោជន៍ជារួម តាមរយៈការព្យាយាមបង្កើននិងបង្កើតថ្មីនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីធ្វើយ៉ាងណា ធានាឲ្យបានថាកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែមានប្រសិទ្ធិភាពនិងគង់វង្សយូរអង្វែង៕

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីអំពី «កិច្ចទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន»រួចមក យើងសង្កេតឃើញថា សម្ព័ន្ធមិត្តនៃប្រទេសទាំងពីរបានចាប់ផ្តើមមានទំនាក់ទំនងជាមួយគ្នាតាំងពីជាង២០០០ឆ្នាំមុនមកម្ល៉េះ នេះបើយោងទៅលើភស្តុតាងបុរាណវត្ថុវិទ្យា ចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាឧទាហរណ៍ ដែលបានពិពណ៌នាអំពីរូបទាហានចិន នៅក្នុងប្រទេសខ្មែរកាលពីសម័យនោះ រួមនឹងឯកសារបរទេសផ្សេងៗទៀត។ ប៉ុន្តែអ្វីដែលជាការពិតដែលមិនអាចប្រកែកបាននោះគឺ ក្នុងអំលុងឆ្នាំ២៣០ នៃសតវត្សទី៣ ដែលកាលនោះបេសកជនការទូតចិនគឺលោក **កាំង ថៃ** ឬ **ខាង ថាយ** និងលោក **ជូ លីង** ឬ **ជូ អ៊ីង** បានមកដល់នគរខ្មែរដែលពេលនោះអ្នកការទូតទាំងពីរបានហៅប្រទេសខ្មែរថា ហ្វូណន។

ក្នុងអំលុងពេលនោះ ក៏ជាពេលដែលមានលំហូរចូលនៃជនជាតិភាគតិចចិនមកកាន់កម្ពុជាផងដែរពោលគឺពួកគេទាំងនោះ ធ្វើដំណើរផ្សងព្រេងតាមសមុទ្រទាំងប្រថុយប្រថានជាទីបំផុត ដើម្បីគេចចេញពីសង្គ្រាមស៊ីវិលនៅប្រទេសចិន ការបង្ខិតបង្ខំលក់កម្លាំងពលកម្ម និងគេចពីកាតព្វកិច្ចយោធាដែលប្រជាជនខ្មែរយើងហៅជនជាតិចិនទាំងអស់នោះថា **ចិនឆៅ** ។

ប្រទេសកម្ពុជា និងប្រទេសចិនបានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយគ្នាតាំងពីពេលនោះមកពោលគឺតាមរយៈផ្លូវសូត្រលើសមុទ្រ ដែលទំនិញមួយចំនួនដូចជា គ្រឿងធ្វើពីព័រសឺឡែន គ្រឿងក្រអូប និងក្រមួនរបស់កម្ពុជាត្រូវបានបញ្ជូនដល់ដៃប្រជាជនប្រទេសទាំងពីរជាបន្តបន្ទាប់ ឥតឈប់ឈរនៅក្នុងប្រវត្តិសាស្ត្រ។ កិច្ចទំនាក់ទំនងដ៏ល្អនេះចេះតែរំកិលទៅមុខពីមួយសម័យកាល ទៅមួយសម័យកាល ពោលគឺមេដឹកនាំនៃប្រទេសទាំងពីរជានិច្ចកាលតែងតែបញ្ជូនអ្នកការទូតរបស់ខ្លួន និងតែងតែពាំនាំនូវសម្ភារៈថ្វាយ និងជូនទៅគ្នាទៅវិញទៅមកឥតឈប់ឈរ ក្នុងន័យបំពេញតម្លៃនៃភាពជាការទូត និងក៏ដើម្បីពង្រឹងទំនាក់ទំនងការទូតនេះឲ្យកាន់តែប្រសើរឡើង។

ឈានដល់ចុងសម័យអាណាព្យាបាលបារាំង មកលើប្រទេសកម្ពុជាគឺនៅពេលដែលប្រទេសកម្ពុជាកំពុងមានចលនាជាតិនិយមយ៉ាងខ្លាំង ដើម្បីធ្វើការទាមទារនូវឯករាជ្យភាពពីបារាំងមកវិញ ក្នុងនាមជាមិត្តដ៏ល្អ ប្រទេសចិនក៏បានចូលរួមយ៉ាងខ្លាំងក្លានៅលើឆាកអន្តរជាតិ ក្នុងការទាមទារឯករាជ្យជាតិឲ្យកម្ពុជា ដោយបានរាំងខ្ទប់នូវមហិច្ឆិតានយោបាយរបស់ប្រទេសដទៃ និងបានគាំទ្រតែគោលនយោបាយរបស់ **សម្តេចព្រះបាទនរោត្តម សីហនុ** តែមួយគត់ ដែលជាផ្នែកដ៏សំខាន់មួយជួយឲ្យប្រទេសកម្ពុជាសម្រេចបាននូវ ឯករាជ្យជាតិពេញសិទ្ធិនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ស្របពេលដែលប្រទេសទាំងពីរក៏បានចុះហត្ថលេខា តភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨។

បន្ទាប់ពីទំនាក់ទំនងការទូតត្រូវបានតភ្ជាប់ ប្រទេសទាំងពីរបានបង្កើត និងបង្កើននូវកិច្ចទំនាក់ទំនងកាន់តែខ្លាំងឡើងៗ ដែលភាគច្រើនផ្តោតសំខាន់ទៅលើវិស័យការទូត និងសេដ្ឋកិច្ចអភិវឌ្ឍន៍ តាមរយៈការធ្វើពាណិជ្ជកម្មរួមគ្នា ការផ្តល់ជំនួយដល់កម្ពុជា ការជួយសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធមួយចំនួនផងដែរ។ ចំណែកវិស័យការទូតវិញ ថ្នាក់ដឹកនាំទាំងពីរនៃប្រទេសទាំងពីរតែងតែផ្លាស់ប្តូរទស្សនកិច្ចផ្លូវការទៅវិញទៅមកជាច្រើនលើកច្រើនសារ ស្របពេលដែលព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ក៏ធ្លាប់បានយាងទៅបំពេញទស្សនកិច្ចនៅប្រទេសចិនសរុបចំនួន ៦លើកផងដែរ ផងដែរក្នុងអំលុងទសវត្សទី៧-៨ នៃសតវត្សរ៍មុន ព្រះអង្គក៏បានការទាមទារឯករាជ្យជាតិ និងរំដោះជាតិនៅប្រទេសចិនចំនួន២លើក ដោយជាលទ្ធផលគឺទ្រង់បានទទួលការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជន និងសំណាក់រដ្ឋាភិបាលចិនផងដែរ។

ការប្រកាន់ខ្ជាប់ជានិច្ចនូវការកសាងជំនឿជឿជាក់ ទំនុកចិត្តគ្នាឲ្យកាន់តែស៊ីជម្រៅ ប្រទេសទាំងពីរក៏បានប្រែក្លាយពីកិច្ចទំនាក់ទំនងមិត្តភាព ដោយធ្វើការចាប់ដៃគ្នា បង្កើតនូវកិច្ចសហប្រតិបត្តិការទ្វេភាគីចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១០។ ឈានដល់សម័យកាលនោះ កិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរកាន់តែមានលក្ខណៈជិតស្និទ្ធ ប្រៀបដូចបងប្អូននឹងគ្នា ព្រោះជានិច្ចកាលរដ្ឋាភិបាលនៃប្រទេសចិនតែងតែធ្វើទស្សនកិច្ចការទូតជាមួយគ្នា ការពារផលប្រយោជន៍ជារួមនៃប្រទេសទាំងពីរ ជួយកសាងហេដ្ឋារចនាសម្ព័ន្ធ ការធ្វើពាណិជ្ជកម្មរួមគ្នា បង្កើនទំហំវិនិយោគ ការផ្តល់ហិរញ្ញប្បទាន និងឥណទានមួយចំនួនដល់កម្ពុជាក្នុងការអភិវឌ្ឍន៍ប្រទេសជាតិផងដែរ។

នាពេលបច្ចុប្បន្ននេះ បើយើងក្រឡេកមើលអំពីទំនាក់ទំនងរវាងប្រទេសទាំងពីរ គឺបានឈានដល់ កិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយ ដែលនេះជាកិច្ចទំនាក់ទំនងកម្រិតកំពូលមួយមិនធ្លាប់មានក្នុងប្រវត្តិសាស្រ្តនៃប្រទេសទាំងពីរ ពោលគឺកម្ពុជាមានតែចិន និងចិនមានតែកម្ពុជា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះគឺប្រទេសទាំងពីរបានឯកភាពគ្នាក្នុងការជួយជ្រោមជ្រែងគ្នាទៅវិញទៅមកលើគ្រប់វិស័យទាំងអស់ដែលមានដូចជាវិស័នយោបាយ ការទូត យោធា សេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគ ហិរញ្ញប្បទាន ឥណទានផ្សេងៗ និងក្នុងវិស័យសង្គមកិច្ចរួមមានដូចជា បរិស្ថាន សុខភាព ការអប់រំ ប្រពៃណីសាសនា និងវិស័យនានាជាច្រើនទៀត ដែលការជួយជ្រោមជ្រែងនេះគឺកើតឡើងតាមរយៈការចុះអនុស្សារណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតប្តូរសារជាច្រើនទៀត។

ជារួមសេចក្តីផង តាមរយៈកិច្ចទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនតាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាលមក យើងសង្កេតឃើញថា វាពិតជាបានផ្តល់នូវផលប្រយោជន៍ជាច្រើនមកដល់ប្រទេសកម្ពុជា។ ក្នុងពេលអតីតកាល ប្រទេសចិនបានជួយ

កម្ពុជាឲ្យគេចផុតពីការឈ្លានពានរបស់ប្រទេសជិតខាង និងគាំទ្រការទាមទារឯករាជ្យឲ្យកម្ពុជា ស្របពេលដែលប្រទេសទាំងពីរបានជួយលើកមុខលើកមាត់គ្នានៅលើឆាកអន្តរជាតិជារឿយៗ។

ចំណែកឯបច្ចុប្បន្នកាលនេះវិញ កម្ពុជាគឺពិតណាស់បានទទួលផលប្រយោជន៍ជាច្រើនក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ ព្រោះថាចិនគឺជាម្ចាស់ជំនួយដ៏ធំជាងគេរបស់កម្ពុជា ដែលសរុបតាំងពីការចាប់ផ្តើមកិច្ចទំនាក់ទំនងមកប្រទេសចិនបានផ្តល់ជំនួយ ជាហិរញ្ញប្បទានឥតសំណងដល់កម្ពុជាលើសពី ១០ពាន់លានដុល្លារសហរដ្ឋអាមេរិកទៅទៀត។ ចំណែកឯវិស័យពាណិជ្ជកម្មវិញ ប្រទេសចិនគឺជាដៃគូពាណិជ្ជកម្មដ៏ចម្បងរបស់កម្ពុជា ទំហំពាណិជ្ជកម្មទ្វេភាគីគឺមានចំនួន ៥.៥៧៧ លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៧ និងប្តេជ្ញាឯកភាពគ្នាជំរុញឲ្យកើនឡើងដល់៦.០០០លានដុល្លារនៅត្រឹមឆ្នាំ២០២០។ បើយើងបន្តទៅមើលវិស័យវិនិយោគវិញ បើគិតត្រឹមខែមិថុនា ឆ្នាំ២០១៨ប្រទេសចិនបានបង្កើននូវទំហំទុនវិនិយោគសរុបប្រមាណ ២៨២២ លានដុល្លារសហរដ្ឋអាមេរិក ដែលធ្វើឲ្យប្រទេសចិនក្លាយជាដៃគូវិនិយោគដ៏ធំជាងគេបង្អស់នៅកម្ពុជា គឺឈរនៅលំដាប់លេខ១ នេះបើធៀបទៅនឹងទំហំវិនិយោគទុនពីប្រទេសដទៃទៀត ដែលភាគច្រើនប្រទេសចិនវិនិយោគទៅលើវិស័យដូចជា វិស័យវារីអគ្គិសនី វិស័យកសិ-ឧស្សាហាកម្ម វិស័យឧស្សាហាកម្ម (ឧស្សាហាកម្មវាយនភ័ណ្ឌកាត់ដេររោងចក្រកិនស្រូវ កសិឧស្សាហាកម្មកៅស៊ូ និងជី រ៉ែ និងថាមពល រោចក្រឥដ្ឋក្បឿងថ្ម) និងវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធជាដើម។

ចំពោះវិស័យទេសចរណ៍វិញ ប្រទេសចិនក៏ឈរនៅចំណាត់ថ្នាក់លេខមួយផងដែរ ដែលមានភ្ញៀវទេសចរចិនមកកាន់ប្រទេសកម្ពុជាច្រើនជាងគេបង្អស់រយៈពេល២ឆ្នាំជាប់គ្នា ពោលគឺមានចំនួន ៥.៦០២.១៥៧នាក់នៅឆ្នាំ២០១៧ និង៦.២០០.០០០នាក់នៅឆ្នាំ២០១៨។ ចំណែកឯវិស័យអាកាសចរណ៍វិញ បច្ចុប្បន្នមានក្រុមហ៊ុនអាកាសចរចិន មានចំនួនសរុប១១ ដែលបាននិងកំពុងហោះតភ្ជាប់ពីប្រទេសចិន មកកម្ពុជា ដែលក្នុងនោះជើងហោះហើរពីបណ្តាខេត្តមួយចំនួននៃប្រទេសចិនមកភ្នំពេញមានចំនួន ៨៨ជើងក្នុងមួយសប្តាហ៍ មកពីសៀមរាបមានចំនួន ៥០ជើងក្នុងមួយសប្តាហ៍ និងមកពីក្រុងព្រះសីហនុមានចំនួន ៥ជើងក្នុងមួយសប្តាហ៍។ ចំណែកឯវិស័យយោធា ប្រទេសទាំងពីរក៏បានចុះកិច្ចព្រមព្រៀង និងពិធិសារជាច្រើនទាក់ទងទៅនឹងការផ្តល់ជំនួយឧបត្ថម្ភដល់កម្ពុជាក្នុងការពង្រឹងវិស័យការពារជាតិរបស់ខ្លួន រួមទាំងបានសម្រេចនូវសមយុទ្ធយោធានាគមាសចំនួន៣លើករួចមកហើយ។

ចំណែកឯចំណុចពិសេសចុងក្រោយ ដែលប្រទេសទាំងពីរអាចរក្សាគោលជំហរក្នុងកិច្ចទំនាក់ទំនងបានជាង២ទសវត្សរ៍មកនេះ គឺគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ការគោរពនូវអធិបតេយ្យភាព បូរណភាពទឹកដី និងសេចក្តីថ្លៃថ្នូររបស់ប្រទេសនីមួយៗ ដែលនេះជាចំណុចដ៏ល្អបំផុតមួយក្នុងន័យគោរពដល់ភាពជាម្ចាស់ផ្ទះ ភាពជាម្ចាស់ប្រទេសនៃដៃគូទំនាក់ទំនងដ៏ស្អិតរមួតនេះ

ជាចុងក្រោយ តាមរយៈការបកស្រាយពីខាងលើនេះ យើងពិតជាបានឃើញយ៉ាងច្បាស់អំពីផលប្រយោជន៍ជាច្រើនដែលកម្ពុជាក្នុងនាមប្រទេសកំពុងអភិវឌ្ឍន៍ទទួលបាន ចេញពីកិច្ចទំនាក់ទំនងជាមួយប្រទេសចិនលើគ្រប់វិស័យទាំងអស់ ទាំងវិស័យនយោបាយ ការទូត យោធា សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងការអភិវឌ្ឍន៍លើវិស័យផ្សេងៗជាច្រើនទៀត៕

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ វិភាគ វែកញែកក្នុងរយៈពេលកន្លងមកនេះ ទៅលើប្រធានបទស្តីពី «កិច្ចទំនាក់ទំនងមិត្តភាពព្រះរាជាណាចក្រកម្ពុជា-សាធារណរដ្ឋប្រជាមានិតចិន» ដោយរួមបញ្ចូលតាំងពីទំនាក់ទំនងពីអតីតកាល គឺគិតចាប់ពីសតវត្សទី១ ឆ្លងកាត់ពេលវេលាជាច្រើន រហូតមកដល់បច្ចុប្បន្នកាល ដែលជាសតវត្សទី២១ ក្នុងឆ្នាំ២០១៩នេះ ខ្ញុំបានសង្កេតឃើញនូវចំណុចសំខាន់ៗជាច្រើនដែលកម្ពុជាបានទទួល និងសម្រេចបានចេញពីកិច្ចទំនាក់ទំនងដ៏ស្អិតរមួតមួយនេះដូចដែលបានរៀបរាប់នៅទំព័រមុនៗជាពិសេសគឺនៅក្នុងសេចក្តីសន្និដ្ឋានតែម្តង។

ទោះបីជាយ៉ាងនេះក្តី ការរួមសុខរួមទុក្ខជាមួយគ្នា ប្រៀបដូចជាបងប្អូនដែលតែងតែនៅកៀកស្មាគ្នា និងជួយយកអាសារគ្នាទៅវិញទៅមក គឺច្បាស់ណាស់ភាពខ្វះខាតមួយចំនួនតែងតែកើតមានដែលជារឿងសាមញ្ញ និងទូទៅដែលមិនអាចនឹងចៀសផុតឡើយ ប្រៀបដូចជាចានដែលតំរៀបបក្នុងទូរក្បែរៗគ្នា គឺតែងតែប៉ះគ្នា លឺសូរសម្លេង ហើយមិនយូរនោះទេក៏ស្ងប់ស្ងាត់ទៅវិញ។ ប្រៀបដូចជាកិច្ចទំនាក់ទំនងនៃប្រទេសទាំងពីរផងដែរ បើទោះបីជាទទួលបាននូវអត្ថប្រយោជន៍ជាច្រើនក៏ពិតមែនក៏ប៉ុន្តែក៏នៅមានចំនុចសំខាន់ផ្សេងៗទៀតដែលប្រទេសទាំងពីរ គួរបង្កើនការយកចិត្តទុកដាក់ក្នុងការបំពេញបន្ថែម ដែលនេះមិនមែនជាចំណុចអវិជ្ជមាននោះទេ ប៉ុន្តែទន្ទឹមនឹងនេះទៅវិញគឺជាចំនុចខ្វះខាតដែលប្រទេសទាំងពីរ គួរតែបំពេញបន្ថែម ដើម្បីឲ្យប្រសិទ្ធភាពនៃកិច្ចទំនាក់ទំនងនេះកាន់តែមានលក្ខណៈប្រសើរឡើងថែមមួយកម្រិតទៀត។

ជាការពិតណាស់ ជាតិសាសន៍ណា ក៏ដូចជាតិសាសន៍ណាដែរ មានអ្នកខ្លះល្អ មានអ្នកខ្លះមិនសូវជាល្អ ដែលតែងតែប្រព្រឹត្តនូវអំពីអសកម្មនៅក្នុងសង្គមជាតិជារឿយៗ។ បច្ចុប្បន្ននេះ មានជនជាតិចិនដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាចំនួនប្រមាណ២១ម៉ឺននាក់ក្នុងនោះ មានចំនួនជាង ៧ម៉ឺននាក់កំពុងតែរស់នៅខេត្តព្រះសីហនុ។ ជាក់ស្តែង ជនជាតិចិនមួយចំនួនបាននិងកំពុងធ្វើការវិនិយោគសាងសង់ ដើម្បីចូលរួមចំណែកកសាងនូវសង្គមជាតិនេះឲ្យកាន់តែប្រសើរឡើង។ ស្របពេលជាមួយគ្នានេះ ក៏មានជនជាតិចិនមួយចំនួនទៀត តែងតែបង្កបទល្មើសផ្សេងៗជាបន្តបន្ទាប់ដែលមានដូចជាគ្រឿងញៀន បទល្មើសឆបោក គំរាមកំហែង និងជម្រិតទារប្រាក់តាមអ៊ិនធើណែត ដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋខ្មែរមានសេចក្តីបារម្ភ ភ័យខ្លាច រហូតអាចក្លាយជាជម្ងឺស្អប់ខ្ពើមជាតិសាសន៍ ការរើសអើងគ្នា ដែលវាអាចប៉ះពាល់ដល់ គោលនយោបាយកិច្ចសហប្រតិបត្តិការនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ របស់ប្រទេសទាំងពីរផងដែរ។

ដូចនេះ ខ្ញុំបាទរកឃើញថា បច្ចុប្បន្ននេះមានបញ្ហាធំៗចំនួន៣ ដែលបង្កឡើងដោយជនជាតិចិនមួយចំនួនក្នុងប្រទេសកម្ពុជា ដែលក្នុងនាមជានិស្សិត ខ្ញុំបាទសូមធ្វើការអំពាវនាវ និងចូលរួម

ចំណែកផ្តល់ជាអនុសាសន៍មួយចំនួន ដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដោះស្រាយទៅនឹងបញ្ហាទាំងអស់នោះឲ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀតដែលរួមមានៈ

១. ខ្ញុំបាទ សូមធ្វើការសំណូមពរដល់រាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ មេត្តាយកចិត្តទុកដាក់បន្ថែមទៀតលើករណី ការនាំចូលលុយ ដែលគ្មានប្រភពច្បាស់លាស់ចូលមកប្រទេសកម្ពុជា ឬហៅដោយសាមញ្ញថា «ការលាងលុយខ្មៅ ឬលុយកង្វក់» តាមរយៈការនាំចូលដោយផ្ទាល់ ឬបច្ចេកវិទ្យាទំនើបហិរញ្ញវត្ថុ ឬតាមរយៈធនាគារ។ ប្រសិនបើបញ្ហានេះ យើងមិនបានធ្វើការទប់ស្កាត់ឲ្យបានទាន់ពេលវេលានោះទេ គឺប្រាកដណាស់នឹងបង្កបញ្ហាដល់វិស័យធនាគារយ៉ាងធ្ងន់ធ្ងរនាពេលដ៏ខ្លីខាងមុខដែលបណ្តាលឲ្យសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះ តាមរយៈការប្រកួតប្រជែងមិនស្មើភាពគ្នាលើវិស័យវិនិយោគ ហើយអត្រានៃការប្រព្រឹត្តអំពើពុករលួយ បញ្ហាអសន្តិសុខក្នុងប្រទេសនឹងកើនឡើង។

២. ចំណុចទី២ ដែលខ្ញុំបាទមើលឃើញទៀតនោះគឺ បញ្ហាអសន្តិសុខ តាមរយៈការប្រព្រឹត្តបទល្មើសនានាដូចជា ការចាប់ជំរិតតាមប្រព័ន្ធអ៊ីនធើណែត ឈ្លោះប្រកែកវាយកាប់ចាក់គ្នា ដោយសារគំនុំសងសឹកដណ្តើមស្រី ឬដោយឥទ្ធិពលគ្រឿងញៀន និងបញ្ហាសណ្តាប់ធ្នាប់ក្នុងការរស់នៅដូចជាការបើកបរក្នុងល្បឿនលឿនមិនគោរពច្បាប់ចរាចរណ៍ បញ្ហាសំរាម និងកាកសំណល់ពាសវាលពាសកាល ដែលធ្វើឲ្យបាត់បង់នូវសោភណ្ឌភាពទីក្រុង និងរបៀបរៀបរយក្នុងការរស់នៅផងដែរ ដែលធ្វើឲ្យជនជាតិខ្មែរមានភាពខ្លាចរអា មិនហ៊ានទៅជិត ឬរស់នៅជាមួយនឹងជនជាតិចិនទាំងអស់នោះ បើទោះបីខ្លួនជាម្ចាស់ប្រទេសក៏ដោយ។ ដូចនេះ ខ្ញុំបាទសូមធ្វើការសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាបង្កើនការរឹតបន្តឹងផ្នែកច្បាប់ ដើម្បីឲ្យជនជាតិចិនទាំងអស់នោះ មានភាពខ្លាររអា ញញើតទៅនឹងការអនុវត្តច្បាប់របស់ប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា មេត្តាធ្វើការអប់រំផ្នែកច្បាប់ដល់ម្ចាស់អាជីវកម្មបដិសណ្ឋារកិច្ច និង ភោជនីយដ្ឋានគ្រប់ប្រភេទនៅពេលពួកគាត់ទទួលបម្រើជនជាតិចិន ក៏អាចផ្តល់ការណែនាំបន្តដល់ជនជាតិទាំងនោះបាន និងលើកទឹកចិត្តឲ្យម្ចាស់អាជីវកម្មទាំងអស់នោះ បិទស្លាកសញ្ញាផ្សេងៗ ដែលរៀបរាប់អំពីទង្វើ ដែលផ្ទុយទៅនឹងច្បាប់របស់ប្រទេសកម្ពុជា នូវរាល់កន្លែងសំខាន់ៗ ដែលងាយស្រួលមើល និងឆាប់មើលឃើញ ព្រោះថាប្រសិនបើបញ្ហានេះមិនត្រូវបានយកចិត្តទុកដាក់ឲ្យបានល្អិតល្អន់ យើងមិនអាចដឹងមុនបានទេថានៅថ្ងៃខានមុខ ជនជាតិចិនទាំងនោះអាចប្រមូលផ្តុំគ្នាកាន់តែច្រើនឡើងៗ បង្កើតជាក្រុមបងតូចបងធំ ឬសម្ព័ន្ធជនអន្ធពាល ដែលនឹងធ្វើឲ្យបញ្ហាកាន់តែពិបាកក្នុងការដោះស្រាយ និងទប់ស្កាត់។

៣. ចំណុចទី៣ ជាចំណុចចុងក្រោយនោះគឺ ការប្រើប្រាស់ស្លាកយីហោរបស់ជនជាតិចិនដែលសរសេរអក្សរខ្មែរមិនត្រូវអក្ខរាវិរុទ្ធ រហូតដល់ថ្នាក់អានមិនដាច់ ដោយសារពួកគេមិនចេះអក្សរខ្មែរនិងប្រើប្រាស់កម្មវិធីបកប្រែរបស់ **ហ្គូហ្គល** ដែលវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តម្លៃនៃវប្បធម៌ដ៏ឧត្តុង

ឧត្តមរបស់ខ្មែរយើង ដែលមានតាំងពីបុរាណកាលមក។ តាមន័យនេះ ខ្ញុំបាទសូមធ្វើការអំពាវនាវដល់រដ្ឋបាលគ្រប់ជាន់ថ្នាក់ ជាពិសេសរដ្ឋបាលដែនដី មេត្តាបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការត្រួតពិនិត្យអក្ខរាវិរុទ្ធខ្មែរឲ្យបានច្បាស់លាស់ មុនពេលប្រគល់បណ្ណអនុញ្ញាតអាជីវកម្មឲ្យជនជាតិចិនទាំងអស់នោះ ពេលពួកគេមកសុំសិទ្ធិធ្វើអាជីវកម្ម ព្រោះនេះក៏បង្ហាញអំពីចំនុចខ្វះខាតក្នុងការដឹកនាំកិច្ចការងាររបស់រដ្ឋបាលដែនដីផងដែរ។

ជារួម ក្នុងនាមខ្ញុំបាទជានិស្សិត ក៏ជាជនជាតិខ្មែរមួយរូបផងដែរ ខ្ញុំបាទសូមលំអោនកាយគោរព អំពាវនាវដល់បងប្អូនជនរួមជាតិខ្មែរទាំងអស់គ្នា មេត្តាប្រកាន់ជំហរមួយថា គ្មានកិច្ចទំនាក់ទំនងពីប្រទេសមួយ ទៅប្រទេសមួយណា ដែលល្អឥតខ្ចោះនោះទេ នៅក្នុងសកលលោកយើងនេះ។ ដូច្នេះ សូមមេត្តាចាត់ទុកថានេះជាបញ្ហាមួយដែលមិនងាយនឹងចៀសផុត ប៉ុន្តែអាចដោះស្រាយផុតបានដោយងាយស្រួល ប្រសិនបើយើងជាម្ចាស់ប្រទេសចេះសាមគ្គីគ្នា ហើយចាត់ទុកថានេះជាកិច្ចការងាររួម ដែលវាមិនមែនជាអម្រែករបស់តែរដ្ឋាភិបាល ឬបុគ្គលណាម្នាក់នោះទេ គឺធ្វើយ៉ាងណាខិតខំ ក្នុងការស្វែងរកដំណោះស្រាយជាវិជ្ជមានទៅនឹងឥរិយាបថ ឬសកម្មភាពអវិជ្ជមានដែលបង្កឡើងដោយជនជាតិចិនមួយចំនួននោះ ក៏ដូចជាជនជាតិបរទេសដទៃនានានៅកម្ពុជាផងដែរ និងសូមបញ្ចៀសឲ្យផុត និងឲ្យបានពីការស្អប់ខ្ពើម និងការរើសអើងជាតិសាសន៍ ដែលនាំឲ្យបន្ទុកនៃបញ្ហាកាន់តែមានការប៉ះពាល់ធ្ងន់ធ្ងរហួតកាន់តែពិបាកដោះស្រាយ និងអាចបាត់បង់នូវតម្លៃ សេចក្ដីថ្លៃថ្នូរនៃវប្បធម៌ និងសង្គមជាតិខ្មែរដ៏បរិបូរណ៍នេះផងដែរ។

ចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទសូមសំណូមពរថា មេត្តាបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការការពារតម្លៃនៃសង្គមជាតិខ្មែរយើង តាមរយៈការអប់រំ ទូន្មានប្រៀនប្រដៅ និងចាត់វិធានការណ៍យ៉ាងតឹងរឹងបំផុតចំពោះជនជាតិបរទេសណាដែលធ្វើសកម្មភាពប្រាសចាកទៅនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើង៕

# ឯកសារយោង / គន្ថនិទ្ទេស


I. **លិខិតបទដ្ឋានគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមាននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ព្រះរាជក្រមលេខ ០៣ នស.៩៤ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។
- អនុក្រឹត្យ លេខ ១១១អនក្រ.បក ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិនិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។
- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រងក្របខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន ចូលជាធរមាននៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០
- សេចក្តីសម្រេចបង្កើតក្រុមការងារផ្លូវសូត្រ និងផ្លូវសមុទ្រសតវត្សទី២១
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២
- អនុសញ្ញាទីក្រុងវីយ៉េនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ១៩៦៣

II. **សៀវភៅស្នាដៃនិពន្ធ**

- វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ឆ្នាំ១៩៦៨ ដោយពុទ្ធសាសនបណ្ឌិត្យ
- សៀវភៅរបស់អ្នកប្រាជ្ញចិន លាង ស្ហួ ,»សៀវភៅលាងស្ហួ» ,ឆ្នាំ៦៣៦
- សៀវភៅ ទំនាក់ទំនងអន្តរជាតិ របស់លោកសាស្ត្រាចារ្យ ដុំ អ៊ឹម បោះពុម្ពលើកទី២
- សៀវភៅរបស់លោកសាស្ត្រាចារ្យ អ៊ែល ប្រាំផ្ត ជនជាតិបារាំង, «ប្រវត្តិសាស្ត្រខ្មែរសម័យនគរភ្នំ (ហ្វូណន) គ.ស ៥២-៦២៧», *Sakhan*, ឆ្នាំ២០១៧
- សៀវភៅលោកសាស្ត្រចារ្យជនជាតិបារាំង George Coedes, «inscriptions du Cambodge», vols. 1-7 vol.1
- សៀវភៅរបស់អ្នកវិទ្យាសាស្ត្រជនជាតិបារាំងឈ្មោះ Jean Boisselier, «LE Cambodge», ឆ្នាំ១៩៦៦, Edition A et P.Picard,
- សៀវភៅអ្នកវិទ្យាសាស្ត្រចិនកាត់ខ្មែរឈ្មោះ លី ធាមតេង, «កំណត់ហេតុជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា», *មូលនិធិខ្មែរសម្រាប់ការសិក្សា*, បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៣
- សៀវភៅអ្នកវិទ្យាសាស្ត្រអាមរិកឈ្មោះ William Willmot, «The Political Structure of the Chinese Community in Cambodia», *Berg Publisher*, ឆ្នាំ១៩៧០

- សៀវភៅណែនាំអំពីការវិនិយោគនៅកម្ពុជា ចេញផ្សាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១២
- សៀវភៅអំពីក្រសួងការពារជាតិ ប្រចាំឆ្នាំ២០១៦
- សៀវភៅរបាយការណ៍ប្រចាំខែមេសា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សៀវភៅណែនាំអំពីការវិនិយោគនៅកម្ពុជា, *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* ,ឆ្នាំ២០១
- សៀវភៅផែនការយុទ្ធសាស្ត្រសុខាភិបាល របស់ក្រសួងសុខាភិបាល ឆ្នាំ២០១៦-២០២០
- «សៀវភៅអំពីបច្ចុប្បន្នភាពនៃជនជាតិចិនរស់នៅក្នុងប្រទេសកម្ពុជា» ,*រាជបណ្ឌិត្យសភាកម្ពុជា,*

### III. របាយការណ៍ ទស្សនាវដ្ដី សារព័ត៌មាន និងគេហទំព័រនានា

- របាយការណ៍របស់, *Cambodian Development Effectiveness Report*, ឆ្នាំ២០១១
- របាយការណ៍របស់ ,*ធនាគារអាស៊ីអភិវឌ្ឍន៍*, ឆ្នាំ២០១១
- របាយការណ៍របស់, *ក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទ,* អំពីទំហំប្រាក់កម្ចីរបស់កម្ពុជា ឆ្នាំ២០១២
- របាយការណ៍របស់, *គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា,* ឆ្នាំ២០១៨
- «របាយការណ៍នាំចេញស្រូវអង្ករកម្ពុជា», *សហព័ន្ធស្រូវអង្ករកម្ពុជា*, ឆ្នាំ២០១៨
- «អំពីកម្ពុជា», *ទស្សនាវដ្ដីខ្មែរហ្វាលខឹង,* ចុះផ្សាយប្រចាំខែតុលា ឆ្នាំ២០១៦ លេខទី៥៦
- «អត្ថបទពិសេសប្រចាំខែធ្នូ ឆ្នាំ២០១៥», *ទស្សនាវដ្ដី សេដ្ឋកិច្ចខ្មែរ*, ឆ្នាំ២០១៥
- *ទស្សនាវដ្ដីចំណាប់អារម្មណ៍ពីអាស៊ាន,* ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦
- www.chinadaily.com «កិច្ចទំនាក់ទំនងកម្ពុជា-ចិន», *កាសែត China Daily* ,ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤
- www.bbc.com «China gives Cambodia 600$m in aid»,*សារព័ត៌មាន BBC*, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៦
- www.politico360.com ឃុន ប៊ុននី, «ស្ដីពីនយោបាយ-សេដ្ឋកិច្ចកម្ពុជា», *គេហទំព័រ POLITICO360* ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩
- www.voacambodia.com ចិនប្រកាសគាំទ្រការបោះឆ្នោតនៅកម្ពុជា»,*វិទ្យុសម្លេងអាមេរិក* ចេញផ្សាយថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨
- www.km.rfi.fr/rfi_news វណ្ណ សុគន្ធា, «ចិនប្រកាសជំហរជួយដល់កម្ពុជាទប់ទល់នឹងសម្ពាធពីអឺរ៉ុបរឿងEBA», *វិទ្យុបារាំងអន្តរជាតិ*, ២០១៩
- www.cnc.com.kh អត្ថបទពីលោក សៀម ប៊ុនធី, «អ្វីទៅជាគំនិតផ្ដួចផ្ដើម ខ្សែក្រវ៉ាត់មួយផ្លូវមួយ», *សារព័ត៌មាន ស៊ីអិនស៊ី*, ឆ្នាំ២០១៨
- www.kohsantepheapdaily.com.kh «ស្ដីពីកម្ពុជា-ចិនប្រកាសគាំទ្រគ្នាលើវេទិកាជាតិ និងអន្តរជាតិ» ,*កាសែតកោះសន្តិភាព*, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨

- www.national-assembly.org.kh ព័ត៌មានប្រចាំថ្ងៃ ពីគេហទំព័រផ្លូវការរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩
- www.kh.china-embassy.org គេហទំព័រផ្លូវការរបស់ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនអចិន្ត្រៃយ៍នៅកម្ពុជា
- www.cca.org.kh សមាគមអ្នកសាងសង់កម្ពុជា «ការវិនិយោគលើវិស័យសំណង់នៅកម្ពុជា» *Cambodia Construction Property,* ២០១៧
- Holding Balance Between Two Superpowers: Cambodia´s Strategic Choices For Foreign And Development Policy (កម្ពុជាជាជម្រើសយុទ្ធសាស្ត្ររបស់បរទេស និងគោលនយោបាយក្នុងការអភិវឌ្ឍន៍របស់បរទេស) – Analysis. (2016, July 27). Retrieved from https://www.eurasiareview.com/27072016-holding-balance-between-two-superpowers-cambodias-strategic-choices-for-foreign-and-development-policy-analysis/
- Phea, K., & Sros, H. (ទំនាក់ទំនងកម្ពុជា-ចិនលើផ្នែកវប្បធម៌) Retrieved from http://iric.gov.kh/wp-content/uploads/2018/09/Cambodia-China-Relations_Cultural-Front.pdf
- Times, A. (n.d.). Search (ទំនាក់ទំនងកម្ពុជា-ចិន). Retrieved from https://www.asiatimes.com/search/?q=CambodiaChina
- ប្រវត្តិសាស្ត្រកម្ពុជា (2013, June 25). Retrieved from https://choukhmer.wordpress.com/history-of-cambodia/histoire-du-cambodge-par-adhemard-leclere/book-1-chapter-8/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ផ្នែកទី១៖ ប្រវត្តិនៃទំនាក់ទំនងសម័យបុរាណ

រូបភាព និងឯកសារភស្តុតាងដែលជាសវតានៃការទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជា

## ផ្នែកទី២៖ ប្រវត្តិនៃទំនាក់ទំនងសម័យសង្គមរាស្ត្រនិយម

រូបភាពនៃការបង្កើតទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជា

## ផ្នែកទី៣៖ ទំនាក់ទំនងកម្ពុជា-ចិនសម័យបច្ចុប្បន្ន ១៩៩៣-២០១៩

១. ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់

២.តារាងស្តីពីពាណិជ្ជកម្មទ្វេភាគី

៣.តារាងស្តីពីទំហំវិនិយោគ

៤.ទស្សនកិច្ចផ្លូវការរវាងមេដឹកនាំប្រទេសទាំងពីរ

## ផ្នែកទី១៖ ប្រវត្តិនៃទំនាក់ទំនងសម័យបុរាណ

រូបភាព និងឯកសារភស្តុតាងដែលជាសក្ខីភាពនៃការទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជា





ផ្ទាំងចម្លាក់លើជញ្ជាំងរោងទងប្រាសាទបាយ័នបង្ហាញអំពីកងទ័ពជនជាតិភាគតិចចិនចេញទៅធ្វើចម្បាំងជាមួយកងទ័ពខ្មែរ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧








ផ្ទាំងចម្លាក់លើជញ្ជាំងរោងទងប្រាសាទបាយ័ន បង្ហាញអំពីស្ត្រីជនជាតិភាគតិចចិន បានយកជង្ហាយទៅថ្វាយស្ត្រីក្នុងរាជវង្ស ឬស្ត្រីជាភរិយាមន្ត្រីជាន់ខ្ពស់ខ្មែរ។ ចម្លាក់ទាំងនេះបានបញ្ជាក់ឱ្យយើងយល់ពីភាពបត់បែន ការសម្រប ការបញ្ជ្រាបខ្លួន និងការទំនាក់ទំនងដ៏ឈ្លាសវៃនៃជនជាតិភាគតិចចិនជាស្ត្រី ឬបុរស តាំងពីសម័យបុរាណកាល។ ឥរិយាបថទន់ភ្លន់បែបនេះបានឱ្យពួកគេអាច រួមរស់នៅលើទឹកដីកម្ពុជាប្រកបដោយសុខដុមរមនា ហើយវប្បធម៌បែបនេះក៏នៅតែបន្តរហូតបច្ចុប្បន្ន។

រូបភាព និងឯកសារភស្តុតាងដែលជាសវតានៃការទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជា






## ផ្នែកទី២៖ ប្រវត្តិនៃទំនាក់ទំនងសម័យសង្គមរាស្ត្រនិយម

រូបភាពនៃការបង្កើតទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជា



សម្តេចព្រះ នរោត្តម សីហនុ និងលោក ឈិន អ៊ី អតីតនាយករដ្ឋមន្ត្រីចិន



សម្តេចព្រះ នរោត្តម សីហនុ និងលោក ជូ អេនឡាយ



សម្តេចព្រះ នរោត្តម សីហនុ និងលោក ជូ អេនឡាយ អតីតនាយករដ្ឋមន្ត្រីចិន







## ផ្នែកទី៣៖ ទំនាក់ទំនងកម្ពុជា-ចិនសម័យបច្ចុប្បន្ន ១៩៩៣-២០១៩

### ១. ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់




នៅក្នុងអំលុងទស្សនកិច្ចការងារកាលថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើសេចក្ដីប្រកាសព័ត៌មានរួមស្ដីពីដំណើរទស្សនកិច្ចផ្លូវការមួយនេះ ដែលមានខ្លឹមសារដូចតទៅ៖

- ភាគីទាំងពីរឯកភាពគ្នាថា មិត្តភាពជាប្រពៃណីចិន-កម្ពុជា គឺជាសម្បត្តិដ៏មានតម្លៃនៃប្រជាជនយើងទាំងពីរហើយចាំបាច់ត្រូវពង្រឹង និងលើកកម្ពស់បន្ថែមទៀត។
- ឯកភាពគ្នារក្សាការប្រាស្រ័យទាក់ទងកម្រិតខ្ពស់ តាមរយៈមធ្យោបាយនានានិងរក្សាការទាក់ទងជាយុទ្ធសាស្ត្រឲ្យបានទាន់ពេលវេលា ចំពោះទំនាក់ទំនងទ្វេភាគីនិងបញ្ហាសំខាន់ៗ
- ឯកភាពគ្នាបង្កើនការផ្លាស់ប្ដូរទស្សនកិច្ច ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីលើការអភិវឌ្ឍគ្រប់វិស័យទាំងអស់។
- ឯកភាពគ្នាប្រើប្រាស់ឲ្យបានល្អ នូវគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលរវាងកម្ពុជា និងចិន ព្រមទាំងសម្របសម្រួល និងជម្រុញកិច្ចសហប្រតិបត្តិការជាក់ស្ដែងលើវិស័យទាំងអស់
- បន្តបង្កើនការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការលើកិច្ចការ ការបរទេស ការពារជាតិ ព្រមទាំងការអនុវត្តច្បាប់ និងសន្តិសុខ។
- បង្កើនវិសាលភាព និងកម្រិតនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីឈានទៅសម្រេចទំហំពាណិជ្ជកម្មទ្វេភាគីឲ្យបាន ៦ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២០។
- ពង្រឹងកិច្ចសហប្រតិបត្តិលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន កសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នាវាចរណ៍ និងទេសចរណ៍ឲ្យកាន់តែស៊ីជម្រៅ។
- ភាគីចិនបានបញ្ជាក់សារជាថ្មីនូវការគាំទ្រយ៉ាងមុឹងម៉ាត់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពារអធិបតេយ្យភាព ឯករាជ្យភាព និងរក្សាស្ថិរភាពនយោបាយរបស់ខ្លួន
- ភាគីកម្ពុជាបានបញ្ជាក់សាជាថ្មីនូវការប្ដេជ្ញាចិត្តរបស់ខ្លួនចំពោះគោលនយោបាយចិនតែមួយ។
- ថ្នាក់ដឹកនាំទាំងពីរបានធ្វើជាសាក្សី ក្នុងការចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការចំនួន ១៣។



ក្នុងអំឡុងពេលឯកឧត្តម **ស៊ី ជីនភីង** បំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា កម្ពុជា និងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងពិធីសាររវាងរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលចិន និងរវាងវិស័យឯកជនកម្ពុជា និងវិស័យឯកជនចិន សរុបចំនួន៣១ ដែលក្នុងនោះរួមមាន

1. កិច្ចព្រមព្រៀង ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងដំណាក់កាលថ្មី
2. អនុស្សរណៈយោគយល់គ្នា ស្តីពីការរៀបចំចំណុចនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវស្រុក និង កិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១
3. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសស្តីពីការផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន ១,២ប៊ីលានយ័ន ប្រមាណជា ១៧៦លានដុល្លារសហរដ្ឋអាមេរិក
4. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការសមុទ្រ
5. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យវិទ្យុនិងទូរទស្សន៍
6. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអធិការកិច្ច
7. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកម្មវិធីផ្លាស់ប្តូរទស្សនកិច្ចអ្នកវិទ្យាសាស្ត្រ
8. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា
9. លិខិតប្តូរសារស្តីពីគម្រោងសាងសង់អគារពេទ្យមិត្តភាពកម្ពុជា-ចិន
10. ពិធីសារស្តីពីការលុបឥណទានឥតការប្រាក់
11. កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទានសម្បទានជាប្រាក់យ័នចិនសម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធពាក់សាស្ត្រវៃកូជំហានទី២
12. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសជាឥណទានឥតការប្រាក់សម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធពាក់សាស្ត្រវៃកូជំហានទី២
13. កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទានសម្បទានជាប្រាក់យ័នសម្រាប់គម្រោងសាងសង់ផ្លូវជាតិលេខ៥១
14. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសជាឥណទានឥតការប្រាក់សម្រាប់គម្រោងសាងសង់ផ្លូវជាតិលេខ៥១
15. កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីការសន្យាផ្តល់ឥណទានសម្បទានជាប្រាក់យ័នចិនសម្រាប់គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី២
16. អនុស្សរណៈនៃការយោគយល់គ្នាសម្រាប់សិក្សាប្លង់មេស្តីពីផែនការគម្រោងធនធានទឹកនៅកម្ពុជា និងគម្រោងរៀបចំនិងការគាំទ្រសម្ភារៈដល់គម្រោងវិទ្យាស្ថានធនធានទឹក។
17. លិខិតប្តូរសារស្តីពីប្រព្រឹត្តកម្មមិនជាប់ពន្ធគយចំនួន ៩៧%នៃមុខទំនិញសរុប
18. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជំរុញគម្រោងកិច្ចសហប្រតិបត្តិការវិនិយោគនស្សាហកម្មគន្លឹះ



19. អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីដំណើរការកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានចារកម្មលើវិស័យអនុវត្តច្បាប់សន្តិសុខផ្ទៃប្រទេស
20. កិច្ចព្រមព្រៀងស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនចិន
21. កិច្ចព្រមព្រៀងសម្បទានសម្រាប់ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ
22. កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិនសម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូដំបានទី២
23. កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិនសម្រាប់គម្រោងសាងសង់ផ្លូវជាតិលេខ៥១
24. កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិនសម្រាប់សាងសង់ផ្លូវក្រវ៉ាត់ក្រុងទី២
25. កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់ដុល្លារអាមេរិកសម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីជនបទដំបានទី៥ និង ទី៦
26. កិច្ចសន្យាសាងសង់ផ្លូវជាតិលេខ១១ អ្នកលឿង-ថ្នល់ទទឹង
27. អនុស្សារណៈយោគយល់គ្នារវាងក្រុមហ៊ុន Green Trade កម្ពុជា និងក្រុមហ៊ុន COFCO ចិនស្តីពីការនាំអង្ករ ២០០ ០០០តោនទៅប្រទេសចិន
28. កិច្ចសន្យាសាងសង់នៃគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ាត់ដំបានទី២ រវាងវិស័យឯកជនកម្ពុជា និងវិស័យឯកជនចិន។
29. អនុស្សារណៈយោគយល់គ្នាស្តីពីការវិនិយោគ និងអភិវឌ្ឍន៍ខ្សែបណ្តាញអគ្គិសនីជាតិ
30. កិច្ចព្រមព្រៀងពិធីសារសម្រាប់គម្រោងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ៩៥០គីឡូវ៉ាត់នៅខេត្តព្រះសីហនុ។

កិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី ៩០០លានយ័ន ប្រមាណ៥៨លានដុល្លារសហរដ្ឋអាមេរិក។




ឯកឧត្តម **លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន បានធ្វើទស្សនកិច្ចផ្លូវរដ្ឋមកកាន់ប្រទេសកម្ពុជាកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ ស្របពេលដែលវាជាពេលវេលាដែលព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនក៏បានចុះហត្ថលេខាលើឯកសារចំនួនសរុប១៩ ដែលក្នុងនោះមានកិច្ចព្រមព្រៀងចំនួន៩ អនុស្សរណៈនៃការយោគយល់ចំនួន៧ លិខិតប្តូរសារចំនួន២ និងកិច្ចសន្យាចំនួន១ រួមមាន៖

១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការលើកកម្ពស់បន្ថែមការអភិវឌ្ឍមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាកម្ពុជា-ចិន។
២. អនុស្សរណៈនៃការយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ គុណភាពផលិតផល។
៣. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស។
៤. លិខិតប្តូរសារស្តីពីគម្រោងផ្គត់ផ្គង់សម្ភារៈ។
៥. លិខិតប្តូរសារស្តីពីការផ្តល់ជូនបរិក្ខារមួយបាច់។
៦. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីគម្រោង «ដំណើរនៃក្តីស្រលាញ់ពីបេះដូង» នៅកម្ពុជា។
៧. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីផែនការរួមលើការអភិវឌ្ឍកសិកម្មទំនើបនៅកម្ពុជា។
៨. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវដំណាំស្រូវ។
៩. កិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោង «ការបង្កើតមជ្ឈមណ្ឌលបង្កាត់និងអភិរក្សពូជឈើមានតម្លៃនៅកម្ពុជា»។
១០. កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងសាងសង់ខ្សែអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុលដំណាក់កាលទី ២។
១១. កិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងពង្រីក និងលើកកម្រិតផ្លូវជាតិលេខ៣ (ចោមចៅ-បែកត្នូត-ក្រុងកំពត)។
១២. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទៅវិញទៅមក។
១៣. កិច្ចព្រមព្រៀងសម្បទានសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ។
១៤. កិច្ចព្រមព្រៀងស្តីពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
១៥. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីពាណិជ្ជកម្មអង្ករ។
១៦. កិច្ចសន្យាសម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុលជាផ្លិចខ្នងសម្រាប់បណ្តាញជាតិ និងភ្ជាប់អនុតំបន់។
១៧. កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានសម្រាប់គម្រោងអាកាសយានដ្ឋានភ្នំពេញថ្មី ប្រទេសកម្ពុជា។
១៨. កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីគម្រោងបាញ់បង្ហោះផ្កាយរណប «តេជោ ១»។
១៩. កិច្ចព្រមព្រៀងស្តីពីគម្រោងវិនិយោគលើការសាងសង់ និងប្រតិបត្តិការកំពង់ផែស្ទឹងហាវ។

## ២.តារាងស្ដីពីពាណិជ្ជកម្មទ្វេភាគី

### ក. ការនាំចេញរបស់កម្ពុជាទៅប្រទេសចិន(២០០០-២០០៥)៖

| **វាយមុខផលិតផល** | **ការនាំចេញរបស់កម្ពុជាទៅប្រទេសចិន(លានដុល្លារ)** | | | | | |
|---|---|---|---|---|---|---|
| | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** |
| ឈើ និងផលិតផលធ្វើពីឈើ | ៥០.២៧ | ២៧.០៣ | ១៥.១២ | ១៣.៦៤ | ១៥.០៦ | ១១.១ |
| កប្បាស | - | ០.៥៥ | ០.១ | ៣.១៥ | ៨.៨៥ | ៧.៥៦ |
| កៅស៊ូ និងផលិតផលធ្វើពីកៅស៊ូ | ៥.៤១ | ៥.៧១ | ៧.៤៨ | ៧.៦៨ | ២.៥៣ | ៣.១៣ |
| ត្រី បង្គា និងសិប្បិសត្វ | ១.០៧ | ០.៩៣ | ១.២៨ | ១.១៣ | ១.២៨ | ០.៧៣ |
| សំលៀកបំពាក់ និងបំណែកបន្ថែម | ២.៥ | ០.០៨ | ០.០៤ | ០.០៤ | ០.៦៨ | ១.៧៩ |
| ប្រេងរុក្ខជាតិ ទឹកអប់ គ្រឿងក្រអូប | - | - | - | ០.០៩ | ០.០៦ | ១.០៨ |
| សត្វរស់ | ០.២១ | ០.២៤ | ០.៣២ | ០.០៦ | ០.០៤ | ០.២៤ |
| **សរុបតម្លៃផលិតផលទាំងអស់** | **៥៩.៤៩** | **៣៤.៨** | **២៤.៥៥** | **២៦.១៧** | **២៩.៥៦** | **២៧.៣** |

### ខ. ការនាំចូលរបស់កម្ពុជាពីប្រទេសចិន(២០០០-២០០៥)៖

| **វាយមុខផលិតផល** | **ការនាំចូលរបស់កម្ពុជាពីប្រទេសចិន (លានដុល្លារ)** | | | | | |
|---|---|---|---|---|---|---|
| | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** |
| កប្បាស | ៧៨.៥៤ | ១០៩.៩៤ | ១៥៤.១១ | ២០៥.៧៧ | ២៩៧.៤៥ | ៣៦៤.៧៤ |
| សរសៃអំបោះសិប្បនិម្មិត | ៨.៥ | ១១.០៣ | ១៧.៣២ | ១៥.៨៨ | ៣២.១៧ | ៣៨.៥១ |

| | | | | | | |
|---|---|---|---|---|---|---|
| សរសៃឆ្មារសំយោគ | ៩.២៧ | ៦.១៥ | ៨.១២ | ១២.៦៤ | ២០.៤២ | ២៤.៤៤ |
| ក្រណាត់តម្បាញពិសេស | ៣.២៧ | ៣.៣១ | ១០.៨២ | ១១.៧ | ២១.០៨ | ២០.១៧ |
| ផលិតផលបានមកពីការចាក់ដោយម្ហុល | ២១.៦៧ | ៣០.៣៨ | ៤៤.៤៤ | ៧០.៨៥ | ៨៥.៩៨ | ១២៣.៥៤ |
| សំលៀកបំពាក់ និងបំពែកសម្រាប់បន្ថែមបានមកពីការចាក់ដោយម្ហុល | ៦.៣៨ | ៦.៨២ | ៦.៦ | ៩.៣៧ | ៨.៩៧ | ២០.៨៤ |
| **វាយនភណ្ឌ និង សំលៀកបំពាក់** | **៧៨.៥៤** | **១០៩.៩៤** | **១៥៤.១១** | **២០៥.៧៧** | **២៩៧.៤៥** | **៣៦៤.៧៤** |
| ម៉ាស៊ីន និង បរិធានមេកានិក | ១១.១៣ | ១១.៧៩ | ២០.១២ | ១៤.៣២ | ២២.០២ | ៣៤.២៨ |
| សម្ភារៈអគ្គិសនី និង អេឡិចត្រូនិក | ១៣.៩៥ | ១៤.៦៣ | ១០.៦២ | ៧.៩ | ១៥.៥២៧ | ១៨.៣៣ |
| **ឧបករណ៍អគ្គិសនី និង គ្រឿងម៉ាស៊ីន** | **២៥.០៨** | **២៦.៤២** | **៣០.៧៤** | **២២.២២** | **៣៧.៥៥** | **៥២.៦១** |
| **ផលិតផលផ្សេងៗទៀត** | | | | | | |
| សាច់ត្រី និងគ្រឿងសមុទ្ររៀបចំហើយ | - | - | - | - | ១៩.៦៧ | ១៤.៣១ |
| ដែក និងដែកថែប | ១២.០១ | ៨.៤៨ | ៦.២៧ | ៩.០១ | ១៤.០៣ | ៩.៨៤ |
| ផលិតផលសេរ៉ាមិក | ៣.២៦ | ៤.៨៧ | ៧.៥២ | ១០.៣៤ | ១៣.៨៨ | ២២.៥៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ឧបករណ៍ធ្វើពីដែក ឬដែកថែប | ៤.១៨ | ៧.៣៥ | ១៣.៤៥ | ០.៩៥ | ៩.១៣ | ៥.៨៥ |
| យានយន្តក្រៅពីរថភ្លើង រថអគ្គិសនី | ៣.៦១ | ៣.២៥ | ៣.២៧ | ១០.៧៨ | ៦.៧១ | ៧.៣៨ |
| **សរុបតម្លៃផលិតផលទាំងអស់** | **១៦៤.១** | **២០៥.៥៨** | **២៥១.៨** | **២៩៤.៥៩** | **៤៥២.៣៣** | **៥៣៦.១១** |

**គ. សរុបការធ្វើពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសចិន(២០០០-២០០៥)៖**

| | |
|---|---|
| ប្រទេសកម្ពុជានាំចេញទៅប្រទេសចិន | ១៩០៤.៥១ លានដុល្លារសហរដ្ឋអាមេរិក |
| ប្រទេសកម្ពុជានាំចូលពីប្រទេសចិន | ២០១.៨៧ លានដុល្លារសហរដ្ឋអាមេរិក |
| សរុបទំហំពាណិជ្ជកម្ម(២០០០-២០០៥) | ២១០៦.៣៨ លានដុល្លារសហរដ្ឋអាមេរិក |

**ឃ.តារាងស្តីពីពាណិជ្ជកម្មទ្វេភាគី(២០១៣-២០១៧)**[49]

| ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងកម្ពុជា-ចិន | | | |
|---|---|---|---|
| ឆ្នាំ | នាំចូលពីចិន | នាំចេញពីកម្ពុជា | សរុប |
| ២០១៣ | ២៩៩២ លានដុល្លារ | ២៦២ លានដុល្លារ | ៣២៥៨ លានដុល្លារ |
| ២០១៤ | ៣៧១០ លានដុល្លារ | ៣៥៦ លានដុល្លារ | ៤០៦៦ លានដុល្លារ |
| ២០១៥ | ៤៥៥០ លានដុល្លារ | ៤០៥ លានដុល្លារ | ៤៣៣១ លានដុល្លារ |
| ២០១៦ | ៤៥៥១ លានដុល្លារ | ៦០៩ លានដុល្លារ | ៥១៦០ លានដុល្លារ |
| ២០១៧ | ៤៨១៦ លានដុល្លារ | ៧៦១លានដុល្លារ | ៥៥៧៧ លានដុល្លារ |

**ង.ការនាំចេញអង្ករ(២០១៥-២០១៩)៖**[50]

| ខ្នាតគិតជាតោន | | | | |
|---|---|---|---|---|
| ២០១៥ | ២០១៦ | ២០១៧ | ឆ្នាំ២០១៨ | (មករា-មេសា)២០១៩ |
| ១១៦.៦៣៦ តោន | ១២៨.០០០ តោន | ២១៥.១៥៥ តោន | ១៧០.១៥៤ តោន | ៩៥.០៦៦ តោន |

49«ព្រឹត្តិការណ៍ប្រចាំសប្តាហ៍ ព័ត៌មានពាណិជ្ជកម្ម» ,*ក្រសួងពាណិជ្ជកម្ម*, ឆ្នាំ២០១៨
50 «របាយការណ៍នាំចេញស្រូវអង្ករកម្ពុជា», *សហព័ន្ធស្រូវអង្ករកម្ពុជា*, ២០១៨

# ៣.តារាងស្តីពីទំហំវិនិយោគ

## ក.វិនិយោគលើវារីអគ្គិសនី(មកទល់បច្ចុប្បន្ន)

| ល.រ | ទីតាំងវារីអគ្គិសនី | ទំហំ (មេកាវ៉ាត់) | ទឹកប្រាក់ (លានដុល្លារ) | ឆ្នាំកសាង |
|---|---|---|---|---|
| ១ | គីរីរម្យទី១ (ខេត្តកំពង់ស្ពឺ) | ១២ | ២៦ | ២០០២ |
| ២ | គីរីរម្យទី៣ (ខេត្តកោះកុង) | ១៨ | ៤៧.១ | ២០១២ |
| ៣ | កំចាយ (ខេត្តកំពត) | ១៩៤.១ | ២៨០.៥៤ | ២០១១ |
| ៤ | អាតៃ (ខេត្តពោធិ៍សាត់) | ១២០ | ១៩៩.៩៧ | ២០១៣ |
| ៥ | ស្ទឹងឫស្សីជ្រុំ (ខេត្តកោះកុង) | ៣៣៨ | ៤៨៥.៧៦ | ២០១៣ |
| ៦ | តាតៃ (ខេត្តកោះកុង) | ២៤៦ | ៥៤០ | ២០១៣ |
| ៧ | សេសានក្រោម២ (ស្ទឹងត្រែង) | ៤០០ | ៧៨១.៥២ | ២០១៧ |
| សរុប | | ១៣២៨.១ | ២៣៧០.៨៩ | |

## ខ.វិនិយោគលើវិស័យកសិកម្ម និងវិស័យកសិ-ឧស្សាហកម្ម(២០១៣-២០១៨)

| ២០១៣ | ២០១៤ | ២០១៥ | សរុប(លានដុល្លារ) |
|---|---|---|---|
| ២១២.៥៤៤.៦៨១ | ១៤១.១៦១.៦០៤ | ៦៣.៤៣៤.៧៣៨ | គិតចាប់ពីឆ្នាំ២០១៣-(មករា-កក្កដា)២០១៨ ១.០៩៩.៩០២.៧០៣ |
| ២០១៦ | ២០១៧ | (មករា-កក្កដា)២០១៨ | |
| ៣០៣.៥០៥.១៩៣ | ២០៥.៥៥១.៥០០ | ១៧៣.៧០៤.៩៨៧ | |

### គ.វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេវាកម្ម(២០១៣-២០១៨)

| ២០១៣ | ២០១៤ | ២០១៥ | សរុប(លានដុល្លារ) |
|---|---|---|---|
| ៧១០.៤៤៤.០១៧ | ៨៨៤.៤៧៥.១៨៩ | ៧៧៩.២១៤.៧៥០ | គិតចាប់ពីឆ្នាំ២០១៣-(មករា-កក្កដា)២០១៨ ៧.៨៧៨.៧៣៣.៣៤២ |
| ២០១៦ | ២០១៧ | (មករា-កក្កដា)២០១៨ | |
| ៩៨៥.៧៩៨.២១៩ | ១.៦៥៦.១៤៦.៩៤៤ | ២.៨៦៣.០៥៤.២២៤ | |

### ឃ.វិនិយោគលើវិស័យឧស្សាហកម្ម និងកម្សាន្តសាល(២០១៣-២០១៨)

| ២០១៣ | ២០១៤ | ២០១៥ | សរុប(លានដុល្លារ) |
|---|---|---|---|
| ៤៨៩.៥៧៤.៣៣៦ | ៥៣៧.១២០.៧០៤ | ៣១៥.៧៨០.០១២ | គិតចាប់ពីឆ្នាំ២០១៣-(មករា-កក្កដា)២០១៨ ២.៩៨៥.០១២.៩៨២ |
| ២០១៦ | ២០១៧ | (មករា-កក្កដា)២០១៨ | |
| ៤៥២.៩០២.៣០១ | ៤៨៨.៥៧៥.៤៤៤ | ៧០១.០៦០.១៨៥ | |

### ង. សរុបទំហំវិនិយោគពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ២០១០៖[51]

| ទំហំវិនិយោគពី ប្រទេសចិនមកកម្ពុជា | ឆ្នាំ(លានដុល្លារ) | | | | | |
|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | សរុបពីឆ្នាំ ១៩៩៤-២០១០ |
| | ៧១៧ | ១៨០ | ៤៣៧១ | ៨៩៣ | ៦៩៤ | ៧៧១៩ |

### ច.ភ្ញៀវទេសចរចិនមកកម្ពុជា(២០១០-២០១៨)

| ឆ្នាំ | ចំនួនទេសចរសរុប | ចំនួនទេសចរចិន | | | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ(%) | កំណើន(%) | |
| ២០១០ | ២.៥០៨.២៨៩ | ១៧៧.៦៣៦ | ៧.១ | ៣៨.៦ | ៣ |
| ២០១១ | ២.៧០៦.៧៤៣ | ២៤៧.១៩៧ | ៩.១ | ៣៩.២ | ៣ |
| ២០១២ | ៣.២០១.៩៨១ | ៣៣៣.៨៩៤ | ១០.៤ | ៣៥.១ | ៣ |
| ២០១៣ | ៤.៥០២.២៣១ | ៤៦៣.១២៣ | ១១.០ | ៣៨.៧ | ២ |
| ២០១៤ | ៤.៥០២.៧៧៥ | ៥៦០.៣៣៥ | ១២.៤ | ២១.០ | ២ |
| ២០១៥ | ៤.៧៧៤.២៣១ | ៦៩៤.៧១២ | ១៤.៥ | ២៤.០ | ២ |
| ២០១៦ | ៥.០១១.៧១២ | ៨៣០.០០៣ | ១៦.៦ | ១៩.៥ | ២ |
| ២០១៧ | ៥.៦០២.១៥៧ | ១.២១០.៧៨២ | ២១.៦ | ៤៩.៩០ | ១ |
| ២០១៨ | ៦.២០០.០០០ | ១.៩០០.០០០ | ៣១.០ | ៧០ | ១ |

[51] ទិន្នន័យដកស្រង់ពីសៀវភៅណែនាំអំពីការវិនិយោគនៅកម្ពុជា ចេញផ្សាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១២

## ៤. តារាងស្ដីពីទស្សនកិច្ចផ្លូវការរវាងមេដឹកនាំប្រទេសទាំងពីរ

## ក.ទស្សនកិច្ចរបស់មេដឹកនាំប្រទេសចិនអំឡុងសម័យសង្គមរាស្ត្រនិយម ដល់ខែតុលា ឆ្នាំ២០១៦៖[52]

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍សំខាន់ៗ |
|---|---|
| អំឡុងសម័យ សង្គមរាស្ត្រនិយម | លោកនាយករដ្ឋមន្ត្រីចិន **ជូ អេនឡាយ** (Zhou Enlai) និងលោកប្រធានាធិបតីចិន **លីវ សាវឈី** (Liu Sao Chi) បានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅកម្ពុជាជាច្រើនលើក។ |
| ខែវិច្ឆិកា ឆ្នាំ២០០០ | លោកប្រធានាធិបតីចិន **ជាំង ជឺមីន**(Jiang Zemin) មកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា ភាគីទាំងសងខាងបានចុះហត្ថលេខាលើ "សេចក្ដីថ្លែងការណ៍រួមស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន។" |
| ខែវិច្ឆិកា ឆ្នាំ២០០២ | លោកនាយករដ្ឋមន្ត្រី **ជូ យ៉ុងជី** (Zhu Rongji) មកបំពេញទស្សនកិច្ចនៅកម្ពុជា មេដឹកនាំប្រទេសទាំងពីរកម្ពុជា-ចិន បានឯកភាពគ្នាដោយចាត់ទុកវិស័យកសិកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការបណ្ដុះបណ្ដាលធនធានមនុស្សជាវិស័យសហប្រតិបត្តិការសំខាន់នៃប្រទេសទាំងពីរ ភាគីចិនថែមទាំងប្រកាសលុបចោលនូវបំណុលដែលដល់ពេលកំណត់ទាំងអស់ដែលកម្ពុជាធ្លាប់បានជំពាក់ចិន។ |
| ខែមេសា ឆ្នាំ២០០៦ | លោកនាយករដ្ឋមន្ត្រីចិន **វេន ជាប៉ាវ** (Wen Jiabao) មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ភាគីទាំងសងខាងបានចេញ "សេចក្ដីថ្លែងការណ៍រួម" ប្រកាសបង្កើតទំនាក់ទំនងដៃគូសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ |
| ខែមីនា ឆ្នាំ២០១២ | លោកប្រធានាធិបតី **ហ៊ូ ជីនថាវ** (Hu Jintao) មកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា ដោយភាគីទាំងសងខាងបានចេញ "សេចក្ដីថ្លែងការណ៍រួម"។ |
| ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ | ព្រះករុណា ព្រះបាទសម្ដេច ព្រះ**នរោត្តម សីហនុ** បានសោយទិវង្គតនៅរដ្ឋធានីប៉េកាំង។ ភាគីចិនបានប្រើយន្តហោះពិសេសក្នុងការដង្ហែព្រះមញ្ជូសា(មឈូស) របស់ព្រះអង្គត្រឡប់មករាជធានីភ្នំពេញ។ សមាជិកក្រុមប្រឹក្សារដ្ឋលោក **តៃ ពីងគួ** (Dai Bingguo) ធ្វើជាតំណាងរ |

[52] ទស្សនាវដ្ដី ខ្មែរហួលឌីង លេខទី៥៦ ទំព័រទី២០ ចុះផ្សាយប្រចាំខែតុលា ឆ្នាំ២០១៦

| | |
|---|---|
| | ដ្ឋាភិបាលចិនក្នុងការដង្ហែព្រះបរមសពតាមយន្តហោះពិសេសមួយនោះ។ |
| ខែកុម្ភៈ ឆ្នាំ២០១៣ | សមាជិកអចិន្ត្រៃយ៍ផ្នែកនយោបាយមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាប្រធានក្រុមប្រឹក្សានយោបាយទូទាំងប្រទេស លោក **ជា ឈីងលីន** (Jia Qinglin) មកប្រទេសកម្ពុជាចូលរួមព្រះរាជពិធីថ្វាយព្រះភ្លើងដល់ព្រះបរមសព ព្រះករុណា ព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ។ |
| ខែតុលា ឆ្នាំ២០១៦ | លោកប្រធានាធិបតីចិន **ស៊ី ជីនភីង** (Xi Jinping) បានបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជាជាលើកដំបូងក្នុងនាមលោកជាប្រធានាធិបតី។ ក្នុងដំណើរទស្សនកិច្ចនេះ ភាគីទាំងពីរគឺកម្ពុជា-ចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងពិធីសារសរុបចំនួន ៣១។ ផងដែរ លោកប្រធានាធិបតីចិន **ស៊ី ជីនភីង** និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានរួមគ្នាក្នុងការសម្ពោធបើកស្លាក "មជ្ឈមណ្ឌលវប្បធម៌ចិន" ដែលមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ |

**ខ.ព្រះរាជទស្សនកិច្ចរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា(២០០៥-២០១៩)**

ព្រះករុណា ព្រះបាទ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានយាងទស្សនកិច្ចទៅកាន់ប្រទេសចិនសរុបចំនួន ១២លើក៖

១. ថ្ងៃទី១០ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៥
២. ថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦
៣. ថ្ងៃទី០១ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨ ព្រះមហាក្សត្រយាងចូលរួមក្នុងពិធីបើកការប្រកួតកីឡាអូឡាំពិកនៅរដ្ឋធានីប៉េកាំង។
៤. ថ្ងៃទី២២ ខែកុម្ភៈ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន
៥. ថ្ងៃទី២៧ ខែកញ្ញា ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន
៦. ថ្ងៃទី០២ ដល់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ព្រះមហាក្សត្រយាងទៅបំពេញទស្សនកិច្ចផ្លូវរដ្ឋតបតាមការអញ្ជើញរបស់ ឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីនៃប្រទេសចិន។
៧. ថ្ងៃទី០៥ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន។
៨. ថ្ងៃទី០៣ ខែមីនា ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន

៩. ថ្ងៃទី២៣ ខែកក្កដា ដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន
១០. ថ្ងៃទី២២ ខែកុម្ភៈ ដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន
១១. ថ្ងៃទី១០ ខែកញ្ញា ដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៨ ព្រះមហាក្សត្រយាងទៅពិនិត្យព្រះរាជសុខភាពនៅទីក្រុងប៉េកាំង ប្រទេសចិន
១២. ថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ក្នុងកម្មវិធីអរិយធម៌អាស៊ីលើកទី១ នៅទីក្រុងប៉េកាំង ប្រទេសចិន៕

**គ.ទស្សនកិច្ចរបស់សម្តេចនាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញធ្វើទស្សនកិច្ចទៅកាន់ប្រទេសចិនសរុបចំនួន ១១លើក ដែលក្នុងនោះ ទស្សនកិច្ចផ្លូវការចំនួន៦លើក និងទស្សនកិច្ចផ្លូវរដ្ឋចំនួន៥លើក(១៩៩៩-២០១៩)។

**ទស្សនកិច្ចផ្លូវការចំនួន៦លើក**

១-ចាប់ពីថ្ងៃទី០៩-១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ សម្តេចតេជោ ហ៊ុន សែន បំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសចិន ដោយកាលណោះ កម្ពុជាទទួលបានប្រាក់កម្ចីសម្បទានពីចិន ២០០លានដុល្លារ ហើយចិន ក៏បានផ្តល់ជំនួយបន្ថែមដល់កម្ពុជា ១៨,៣ លានដុល្លារថែមទៀត។

២-កាលពីថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០០៤ សម្តេចតេជោ ហ៊ុន សែន បានបំពេញទស្សនកិច្ចទៅកាន់ប្រទេសចិន ដោយសម្តេច បានជួបពិភាក្សាការងារជាមួយប្រធានាធិបតីចិន លោក ហ៊ូ ជិនតាវ ក្នុងពេលសម្តេច ចូលរួមវេទិកាសេដ្ឋកិច្ច Boao។ កម្ពុជា-ចិន បានចុះកិច្ចព្រមព្រៀងទ្វេភាគីចំនួន ១៦។

៣-ចាប់ពីថ្ងៃទី១៣-១៧ ខែធ្នូ ឆ្នាំ២០១០ ដោយសម្តេចតេជោ ហ៊ុន សែន បានបំពេញទស្សនកិច្ច នៅទីក្រុងប៉េកាំង ដោយសម្តេចបានជួបពិភាក្សាការងារជាមួយនាយករដ្ឋមន្ត្រីចិន លោក Wen Jaibao។សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន ដើម្បីប្រែក្លាយទំនាក់ទំនងនៃប្រទេសទាំងពីរ ក្លាយទៅជាទំនាក់ទំនងដៃគូសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ មេដឹកនាំទាំង២ បានឯកភាពជំរុញពាណិជ្ជកម្មទ្វេភាគី ដល់ ២៥០០ លានដុល្លារ នៅត្រឹមឆ្នាំ ២០១៥។ ចិន ក៏បានប្រកាសត្រៀមខ្លួនពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងហិរញ្ញវត្ថុ និងការបន្តផ្តល់ជំនួយមកកម្ពុជា។

៤-ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ សម្តេចតេជោ ហ៊ុន សែន បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ដោយសម្តេចបានជួបទ្វេភាគីជាមួយនាយករដ្ឋមន្ត្រីចិន លោក លី ខឺឈាង ( Li Keqiang) បន្ទាប់ពីសម្តេច ចូលរួមវេទិកា Boao សម្រាប់សន្និសីទតំបន់អាស៊ីប្រចាំឆ្នាំ២០១៣ នៅខេត្តហៃណាន់។ មេដឹកនាំកម្ពុជា-ចិន បានជំរុញពាណិជ្ជកម្មប្រទេសទាំងពីរឱ្យបាន ៥០០០ លានដុល្លារ នៅត្រឹមឆ្នាំ២០១៧។

៥-កាលពីថ្ងៃទី១៣-១៧ ខែឧសភា ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន បានអញ្ជើញទៅកាន់ប្រទេសចិន ដោយជួបលោក លី ខឺឈាង ( Li Keqiang) នាយករដ្ឋមន្ត្រីចិន ក្នុងអំឡុងពេលសម្តេច ចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងកិច្ចពិភាក្សាការងារ នៅក្រុងប៉េកាំង មេដឹកនាំទាំង២ ក៏បានធ្វើជាអធិបតី ក្នុងពិធីចុះហត្ថលេខាលើឯកសារអនុស្សារណៈ និងកិច្ចព្រមព្រៀងសំខាន់ៗជាច្រើន។

៦-កាលពីថ្ងៃទី២០ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសចិន ដើម្បីចូលរួមការតាំងពិព័រណ៍ខួបអនុស្សាវរីយ៍ លើកទី៤០ នៃ «កំណែទម្រង់ និងការបើកទូលាយ» ប្រទេសចិន អញ្ជើញចូលរួមជាអធិបតី ក្នុងពិធីបើកវេទិកាសេដ្ឋកិច្ច និងពាណិជ្ជកម្ម កម្ពុជា-ចិន ឆ្នាំ២០១៩ និងជួបសំណេះសំណាល ជាមួយនិស្សិតកម្ពុជា ដែលកំពុងសិក្សានៅប្រទេសចិន ផងដែរ។ ជាលទ្ធផល នៃដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោ ហ៊ុន សែន នៅប្រទេសចិន កាលពីខែមករា ឆ្នាំ២០១៩ គឺចិនបានផ្តល់ជំនួយជិត ៦០០ លានដុល្លារដល់កម្ពុជា និងសន្យាទិញអង្ករ ៤០ម៉ឺនតោនពីកម្ពុជា នៅឆ្នាំ២០១៩ នេះ។

**ទស្សនកិច្ចការងារចំនួន៥លើក**

១-នៅក្នុងខែតុលា ឆ្នាំ២០១៥ សម្តេច ហ៊ុន សែន អញ្ជើញទៅបំពេញទស្សនកិច្ច នៅចិន ដោយសម្តេច បានជួបពិភាក្សាជាមួយប្រធានាធិបតីចិន លោក ស៊ី ជិនពីង ក្នុងអំឡុងពេលសម្តេច ចូលរួមវេទិកាសេដ្ឋកិច្ចទេសចរណ៍សកល នៅប្រទេសចិន។ ក្នុងជំនួបនោះ ភាគីចិន បានសន្យានាំចូលអង្ករ ១០ម៉ឺនតោន ក្នុងមួយឆ្នាំពីកម្ពុជា និងផ្តល់ជំនួយជាង ១៥៧លានដុល្លារ មកកម្ពុជា។

២-សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅប្រទេសចិន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦នេះ ដើម្បីចូលរួមប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី១ នៅទីក្រុងសាន់យ៉ា និងសន្និសីទប្រចាំឆ្នាំនៃវេទិកាបូអាវ នៅទីក្រុងបូអាវ នៅខេត្តហៃណាន ក្នុងសាធារណរដ្ឋប្រជាមានិតចិន។

៣-ថ្ងៃទី១១-១៣ ខែកញ្ញា ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន អញ្ជើញទៅចូលរួមពិធីតាំងពិព័រណ៍ចិន-អាស៊ាន លើកទី១៤ នៅទីក្រុងណាននីង ខេត្តក្វាងស៊ី ប្រទេសចិន។

៤-ថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន បានដឹកនាំគណប្រតិភូជាន់ខ្ពស់របស់កម្ពុជាអញ្ជើញទៅចូលរួមកិច្ចសន្ទនាកម្រិតខ្ពស់រវាង គណបក្សកុម្មុយនីស្តចិន ជាមួយគណបក្សនយោបាយមកពីជុំវិញពិភពលោក។

៥-ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងវេទិកាខ្សែក្រវ៉ាត់ និងផ្លូវ លើកទី២ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ» និងកិច្ចប្រជុំសំខាន់ៗផ្សេងទៀត នៅទីក្រុងប៉េកាំង ប្រទេសចិន។